ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 17-Jan-2012, 15:50
CMS/CFO: Kauv Keoratanak

## កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃសវនាការ ផ្ទាល់មាត់លើឯកសារនានា

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២**

**ម៉ោង ០៩:០២ នាទី**

**សវនាការលើកទី១៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍ *(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោកស្រី សារ៉ា អេនឌ្រូ *(Ms. Sarah Andrews)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន *(Mr. Michiel PESTMAN)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី *(Mr. Andrew IANUZZI)*

លោក ហ្សាស្មី ប៉ៅ

*(Mr. Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ហុង គឹមសួន

លោកស្រី ស៊ីន សុវ៉ន

លោក វ៉េន ពៅ

លោក សំ សុគង់

លោកស្រី ទី ស្រ៊ីនណា

លោក ឡៅ ជុនធី

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍ *(Ms.Phillipine SUTZ)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ហ្សាស្តើ ប៉ៅ | អង់គ្លេស |
| លោក អេនឌ្រូ អ៊ីនូហ្ស៊ី | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក ខៀវ សំផន | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:៣៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅ--

សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ជាដំបូងនេះ ខ្ញុំបាទសុំការអនុញ្ញាតពីលោកប្រធានដើម្បីឲ្យលោក ខៀវ សំផន បានឡើងបញ្ជាក់ពីជំហររបស់លោកទាក់ទងនឹងការឆ្លើយចំពោះការតាំងសំណួរផ្សេងៗពីចៅក្រម ក៏ដូចជាភាគី បញ្ជាក់ទៅលើជំហរដែលលោកបានឆ្លើយពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុន។ ការថ្លែងនេះប្រហែលជាខ្លីទេ ត្រឹមប្រាំនាទីទេ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ ហើយចាំពេលណាមួយដែលសមស្រប ដើម្បីធ្វើកិច្ចការនោះ មិនចេះតែធ្វើទេ ដោយផែនការនៃសវនាការសប្តាហ៍នេះ អង្គជំនុំជម្រះបានជម្រាបភាគី និងសាធារណជនរួចហើយអំពីផែនការនៅក្នុងការកំណត់ការធ្វើសវនាការដេញដោលលើឯកសារដែលត្រូវធ្វើពីថ្ងៃនេះទៅ រហូតដល់ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២ នេះ។

នៅថ្ងៃនេះ អង្គជំនុំជម្រះនឹងមិនធ្វើសវនាការដើម្បីស្តាប់សក្ខីកម្មសាក្សី ឬជនជាប់ចោទណាម្នាក់ឡើយ ដូចដែលអង្គជំនុំជម្រះបានបញ្ជាក់ប្រាប់តាមរយៈអនុស្សរណៈ E159 របស់ខ្លួនរួចហើយ។ សប្តាហ៍នេះ គឺសម្រាប់សវនាការលើការជំទាស់របស់ភាគីនានា ពាក់ព័ន្ធនឹងឯកសារជាក់លាក់មួយចំនួន ឬប្រភេទឯកសារដែលត្រូវដាក់ចំពោះមុខអង្គជំនុំជម្រះ។ ឯកសារនានា គឺជាផ្នែកមួយដ៏សំខាន់នៃភស្តុតាងនៃសំណុំរឿងលេខ០០២ នេះ ភាគីនានាបានជម្រាបមកអង្គជំនុំជម្រះអំពីការជំទាស់លើឯកសារជាក់លាក់ជាច្រើន។

យោងតាមខ្លឹមសារនៃអនុស្សរណៈ E159 អង្គជំនុំជម្រះនឹងស្តាប់ការជំទាស់នានាពាក់ព័ន្ធនឹងឯកសារដែលអង្គជំនុំជម្រះធ្លាប់បានដាក់ លេខសម្គាល់ E3។

[០៩:០៦:០២]

កាលពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ អនុលោមតាមអនុស្សរណ: E141 ឯកសារទាំងអស់ត្រូវបាន លើកនៅត្រង់ជើងទំព័រនៃកថាខណ្ឌពាក់ព័ន្ធ និងប្រវត្តិនៅក្នុងដីកាដំណោះស្រាយ ត្រូវបានចាត់ថ្នាក់ជា ប្រភេទឯកសារ E3 ហើយត្រូវបានអង្គជំនុំជម្រះចាត់ទុកថា ឯកសារទាំងអស់នោះត្រូវបានដាក់ចំពោះ មុខអង្គជំនុំជម្រះ កថាខណ្ឌ៥ នៃអនុស្សរណៈ។

បន្តទៅនេះអង្គជំនុំជម្រះនឹងស្តាប់ការជំទាស់ផ្ទាល់មាត់ ភាគីនីមួយៗមានរយៈពេលចំនួន៣០នាទី ដើម្បីលើកបញ្ហាភស្តុតាងទូទៅដែលមាននៅក្នុងឯកសារនានាពាក់ព័ន្ធនឹងសវនាការនេះ។ បន្ទាប់មកទៀត មេធាវីការពារក្តីមានរយៈពេលចំនួន៩០នាទី ដើម្បីលើកឡើងសេចក្តីជំទាស់ទៅនឹងឯកសារទាំងឡាយ ដែលអង្គជំនុំជម្រះបានចាត់ថ្នាក់ជាប្រភេទឯកសារ E3 ដោយក្រុមមេធាវីការពារក្តីនីមួយៗមានចំនួន ៣០នាទី លើកលែងតែមានការឯកភាពគ្នាផ្ទុយពីនេះពីសំណាក់ក្រុមមេធាវីការពារក្តីទាំងអស់។ បន្ទាប់ពី នោះ អង្គជំនុំជម្រះទុកពេលមួយម៉ោង សម្រាប់សហព្រះរាជអាជ្ញា និង១៥នាទីសម្រាប់សហមេធាវីនាំ មុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីធ្វើការឆ្លើយតប។ បន្ទាប់មក មេធាវីការពារក្តីទាំងអស់មានរយៈដប់ ប្រាំនាទី ដើម្បីធ្វើការឆ្លើយតបដោយសង្ខេប។

[០៩:០៧:៣៩]

នេះជាគោលបំណង និងការវិភាគនៃកិច្ចដំណើរការសវនាការសម្រាប់ធ្វើសវនាការសម្រាប់ សប្តាហ៍នេះពាក់ព័ន្ធតែនឹងឯកសារដែលភាគីដាក់ចំពោះមុខអង្គជំនុំជម្រះតែប៉ុណ្ណោះ។

ជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅសហព្រះរាជអាជ្ញា ហើយសហព្រះរាជអាជ្ញា មានរយៈពេលចំនួន៣០នាទី សម្រាប់លើកបញ្ហាភស្តុតាងទូទៅដែលមានក្នុងឯកសារនានា ពាក់ព័ន្ធនឹង សវនាការនេះ។

សូមអញ្ជើញសហព្រះរាជអាជ្ញា។ លោក ស្មីត ឈប់សិនលោក ស្មីត អង្គុយសិនចុះ!

សូមអញ្ជើញលោកមេធាវី!

[០៩:០៨:៣០]

**លោក ម៉ៃខល ផេសមិន៖**

សូមអធ្យាស្រ័យដែលខ្ញុំរំខាន។ កូនក្តីរបស់ខ្ញុំសុំការអនុញ្ញាត ដែលថា គាត់សុំស្តាប់សវនាការពី បន្ទប់រង់ចាំខាងក្រោម។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីការពារក្តី នួន ជា តើលោកសុំយ៉ាងម៉េចទៅ? សុំឲ្យច្បាស់លាស់។ សុំនៅពេលណា សម្រាប់ពេលណា ឬក៏សុំនូវពេញនៅក្នុងអំឡុងពេលនៃការពិភាក្សាដេញដោលអំពីបញ្ហាឯកសារ ដែលអង្គជំនុំជម្រះគ្រោងធ្វើពីថ្ងៃនេះដល់ថ្ងៃទី១៩?

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំបានសំណើសុំក្នុងរយៈពេលនេះតែម្តង មិនចង់វិលត្រឡប់ទៅបន្ទប់ឃុំឃាំងទេ អ៊ីចឹងសម្រាប់ព្រឹកនេះ គឺថា ឬក៏សុំទាំងសវនាការទាំងមួយសប្តាហ៍នេះតែម្តង ដោយសារគាត់មិនអាចចូលរួមនៅក្នុងទីនេះបាន សុំនៅខាងក្រោមនេះតែម្តង។

[០៩:១០:២៨]

**ប្រធានអង្គជំនុំ៖**

បានស្តាប់សំណើសុំរបស់មេធាវីការពារក្តីជនជាប់ចោទ នួន ជា ដែលបានស្នើសុំឲ្យកូនក្តីរបស់លោកឈ្មោះ នួន ជា អាចចាកចេញពីបន្ទប់សវនាការនេះ ទៅបន្តស្តាប់ដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍នៅបន្ទប់ខាងក្រោមនៃសាលសវនាការនេះ។ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទដែលបានស្នើសុំតាមរយៈមេធាវីរបស់ខ្លួន។ ដោយតម្រូវឲ្យជនជាប់ចោទទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ដែលបានរៀបចំនូវឧបករណ៍សោតទស្សន៍នៅពីខាងក្រោមបន្ទប់សវនាការនេះពេញមួយក្នុងកិច្ចដំណើរការសវនាការសម្រាប់សប្តាហ៍នេះ ពីថ្ងៃទី១៦ រហូតដល់ថ្ងៃទី១៩ តែម្តង។ ប៉ុន្តែ ក្រុមមេធាវីការពារក្តីត្រូវប្រគល់ជូនមកជំនុំជម្រះភ្លាមៗនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ដោយចុះហត្ថលេខា ឬផ្តិតមេដៃយ៉ាងជាក់ច្បាស់របស់ជនជាប់ចោទផង ហើយសូមជម្រាបជូនមេធាវី នួន ជា ថាសូមរៀបចំនូវលិខិតលះបង់សិទ្ធិហ្នឹងឲ្យបានច្បាស់លាស់ ឲ្យបានក្បោះក្បាយមិនអាចធ្វើមួយបន្ទាត់ដូចសព្វដងបានទេ។

[០៩:១២:០៧]

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់-- អ៎ ជនជាប់ចោទ នួន ជា ទៅកាន់បន្ទប់ខាងក្រោមដែលបានរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍ សម្រាប់ជនជាប់ចោទឲ្យចូលរួម និងតាមដានសវនាការពីចម្ងាយ។ ហើយបង្គប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ គឺក្នុងរយៈពេលបួន

ថ្ងៃគឺពីថ្ងៃនេះទៅ រហូតដល់ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២។

សូមនាំទៅចុះ!

សូមអញ្ជើញលោកសហព្រះរាជអាជ្ញា!

**លោក វីណ្ឌៀម ស្មីត៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម។ ជម្រាបសួរសហការីដើមបណ្តឹងរដ្ឋប្បវេណី។ ក្រាបថ្វាយបង្គំព្រះតេជគុណ ព្រះថេរៈគ្រប់ព្រះអង្គ និងសាធារណជនទាំងអស់។

ដំបូងខ្ញុំសូមអរគុណដល់អង្គជំនុំជម្រះអនុញ្ញាតឲ្យខ្ញុំពិភាក្សាទៅលើបញ្ហាឯកសារនេះ នៅក្នុងសវនាការនាព្រឹកនេះ។ បញ្ហាដែលយើងចង់លើកឡើងនោះគឺថា នៅចំពោះមុខអង្គជំនុំជម្រះគឺមានសារៈសំខាន់ណាស់ ដើម្បីឲ្យអង្គជំនុំជម្រះមានលទ្ធភាពពិចារណាស្វែងរកការពិត និងទាក់ទងទៅនឹងបទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ យើងខ្ញុំសូមយល់ឃើញ-- សូមលើកឡើងនូវអ្វីដែលភាគីយល់ឃើញថា ឯកសារគួរតែទទួលយក ឬមិនទទួលយកនោះ។ ដោយសារឯកសារ ប្រសិនណាជាឯកសារទាំងអស់នោះ គឺថាមានបទដ្ឋានមួយខ្ពស់គឺនោះនឹងត្រូវទទួលយកដាក់ទៅក្នុងសំណុំរឿង។

[០៩:១៣:៥៤]

ហើយនៅរសៀលនេះ សហការីរបស់ខ្ញុំ លោក តារាស្មី នឹងលើកឡើងអំពីការជំទាស់ទាក់ទងទៅនឹងផ្នែកមួយនៃដីកាដំណោះស្រាយពាក់ព័ន្ធទៅនឹងប្រវត្តិសាវតារ ទាក់ទងទៅនឹងជនជាប់ចោទទាំងបីនាក់នេះ។

លោក លោកស្រីចៅក្រម ខ្ញុំមានចំណុចបួនដែលត្រូវលើកឡើងនៅព្រឹកនេះ គឺមួយ សារៈសំខាន់នៃឯកសារភស្តុតាងដែលដាក់បញ្ចូលនៅក្នុងសំណុំរឿង។ និងទីពីរ គឺលក្ខខណ្ឌគតិយុត្តិដែលត្រូវយកមកអនុវត្ត។ ទីបី ភាពដែលអាចគួរឲ្យជឿជាក់បាន ដែលយើងខ្ញុំសូមលើកឡើងថា ដែលត្រូវយកមកប្រើប្រាស់ថាតើឯកសារទាំងឡាយនោះ គឺថាអាចជឿជាក់បានឬក៏អត់? ហើយចុងក្រោយទីប្រាំគឺភាពទទួលយកបាន ក៏ដូចជាទម្ងន់នៃឯកសារដែលត្រូវទទួលយកធ្វើជាភស្តុតាង។

[០៩:១៤:៤៥]

ហេតុអ្វីបានជាឯកសារទាំងនេះ វាសំខាន់សម្រាប់តុលាការនោះ គឺដោយសារវាពាក់ព័ន្ធទៅនឹងបទចោទដ៏ធំធេងដើម្បីសម្រេចស្វែងរកការពិត។ ហើយបញ្ហាខ្លះគឺថា ឯកសារខ្លះវាមានទម្ងន់ស្រាលទាក់ទងទៅនឹងការទទួលយកនូវឯកសារទាំងអស់នេះ ដូចជាឱកាសផ្សេងៗគ្នាដែលបុគ្គលម្នាក់ៗមាន

ដែលត្រូវបុគ្គលម្នាក់ៗអាចនឹងជឿជាក់ទៅលើឯកសារទាំង នេះហើយមួយទៀតគឺដើម្បីឲ្យប្រជាជនទាំងអស់បានស្តាប់អំពីព្រឹត្តិការណ៍នៃឧបទ្ទវហេតុទាំងអស់នេះ ហើយមួយទៀតគឺទាក់ទងទៅនឹងសក្ខីកម្មដែលយើងត្រូវបង្ហាញឡើង បន្ទាប់ពីបទល្មើសនោះបានកើតឡើងរយៈពេល៣០ ឬក៏ជាង៣០ឆ្នាំមកហើយនេះ។ ហើយនិងមួយទៀត គឺទាក់ទងទៅនឹងទំនាក់ទំនងជាមួយនឹងជនជាប់ចោទ ក៏ដូចជាការដាក់សម្ពាធនៅក្នុងសវនាការសាធារណៈនេះ។ ហើយក្នុងនេះគឺថាខ្ញុំក៏សូមសំណូមពរថា ជួនកាលពេលខ្លះគឺព័ត៌មាននោះអាចវាជាការមិនពិតទាំងស្រុង ជាការបំផ្លើស ឬជាការបំភ្លៃសក្ខីកម្មដែលបានផ្តល់នោះ។ ដូច្នេះ នៅពេលដែលអង្គជំនុំជម្រះស្តាប់បាននូវសក្ខីកម្មរបស់បុគ្គលម្នាក់ៗ ហើយនឹងត្រូវយកមកថ្លឹងថ្លែង ហើយឯកសារដែលបានបង្កើតឡើងគឺថា នៅក្នុងអំឡុងនៃពេលនោះគឺ ដូចជារូបថតគឺថាវាមិនមែនជាភស្តុតាងក្លែងក្លាយទេ ហើយក្រោយមក នៅពេលដែលឯកសារទាំងអស់នោះត្រូវដាក់ជាភស្តុតាងជូនតុលាការ ជួនកាលមិនអាចមានការលើកឡើង មានការបំផ្លើស ឬក៏លើសខ្វះដោយសារតែឯកសារទាំងអស់នេះមិនបានកត់ត្រាឲ្យបានត្រឹមត្រូវនោះទេ។

[០៩:១៦:៤២]

ទាក់ទងទៅនឹងឯកសារមួយចំនួនដែលខ្ញុំលើកឡើងថា ក៏វាជួយទៅដល់ការវាយតម្លៃក្នុងការស្វែងរកភស្តុតាងដែរ ហើយឯកសារដែលផ្តល់ដោយអ្នកជំនាញយ៉ាងលម្អិតក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ក៏ដូចជាចម្លើយរបស់សាក្សីដែលជាជនរងគ្រោះពីបទល្មើសទាំងអស់នោះ គឺជាការបង្កលក្ខណៈឲ្យអង្គជំនុំជម្រះស្វែងយល់អំពីភាពពិតនៃឯកសារទាំងអស់នេះ។ ហើយទាក់ទងទៅនឹងការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរនៅទូទាំងប្រទេសដែលពិតជាយូរណាស់មកហើយ ដូចជាគោលនយោបាយរបស់រដ្ឋាភិបាល គឺយើងត្រូវតែផ្តល់ជុំវិញបរិបទនោះឲ្យបានល្អិតល្អន់ ទាក់ទងទៅនឹងបទចោទទាំងឡាយដែលយើងយល់ថាឯកសារទាំងអស់នោះមានសារៈសំខាន់បំផុត ហើយក៏វាអនុញ្ញាតឲ្យអង្គជំនុំជម្រះបានពិនិត្យមើលនូវទិដ្ឋភាពទាំងស្រុងតែម្តង ទាក់ទងទៅនឹងបរិបទឯកសារទាំងអស់នេះនៅក្នុងសវនាការនេះ។

[០៩:១៧:៥២]

ការអនុវត្តនៅតុលាការអន្តរជាតិ ដូចជាលក្ខខណ្ឌជាក់លាក់មួយចំនួន គឺថាចៅក្រមអាសនៈគឺនឹងធ្វើការពិចារណាក្រោយពីការស្វែងយល់ ភស្តុតាងពាក់ព័ន្ធបានយ៉ាងច្បាស់លាស់រួចហើយនេះ ហើយជាពិសេសឯកសារទាក់ទងទៅនឹងជនរងគ្រោះទាំងឡាយពីបទល្មើសទាំងនោះ។ ហើយនៅក្នុងការដែលធ្វើដូច្នេះ គឺតុលាការអាចនឹងមានលទ្ធភាពថ្លឹងថ្លែងរវាងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការ

ជំនុំជម្រះដោយយុត្តិធម៌នោះ។

[០៩:១៨:៣២]

សារៈសំខាន់មួយទៀតទៅលើឯកសារទាំងអស់នេះ គឺថានៅចំពោះមុខតុលាការអន្តរជាតិឃើញថាមានឯកសារជាច្រើនត្រូវបានអង្គជំនុំជម្រះទទួលយកមកធ្វើជាភស្តុតាង ដូចជានៅក្នុងករណីរបស់ ភឺឡិច*(Perlec)* គឺឯកសារ IT40474 ដែលជនជាប់ចោទចំនួន៦នាក់ ក្នុងនោះគឺផ្អែក-- អង្គជំនុំជម្រះសាលាដំបូងនៅនោះគឺបានទទួលយកឯកសារមួយសែនសន្លឹក-- មួយសែនច្បាប់មកធ្វើជាភស្តុតាងនៅក្នុង IT0690 គឺថា ទាក់ទងទៅនឹងជនជាប់ចោទបីនាក់ដែលទទួលឯកសារ៤.០០០ ច្បាប់ មកធ្វើជាឯកសារ។

[០៩:១៩:១៨]

លោក លោកស្រីចៅក្រមជាទីគោរព! ប្រហែលជាឯកសារជាងមួយពាន់របស់ ឌុច នេះ ជារឿងក្តីមួយចាត់ទុកថាតូច ទាក់ទងតែនឹងមន្ទីរសន្តិសុខមួយតែប៉ុណ្ណោះ ក៏ប៉ុន្តែដោយសារមានបទចោទទាក់ទងទៅនឹងការរំលោភធ្ងន់ធ្ងរ ហើយក៏ដូចជាទាក់ទងទៅនឹងតួនាទីរបស់ជនជាប់ចោទ ទើបឯកសារដ៏ច្រើនត្រូវបានទទួលយកនៅក្នុងសំណុំរឿងរបស់ ឌុច។

នៅក្នុងករណីនេះ ពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនដោយបង្ខំ ប្រជាជនកម្ពុជាដោយបង្ខំនៅទូទាំងប្រទេស។ នេះគឺជាស្ថានភាពកំពុងដោះស្រាយគ្នាចំពោះមុននេះ ហើយលើសពីនេះទៅទៀត គឺ ថាវាទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាលស៊ីវិល ក៏ដូចជារចនាសម្ព័ន្ធយោធានៅក្នុងរបបនោះផងដែរ។ ហើយបទចោទនៅក្នុងដីកាបញ្ជូនទៅជម្រះគឺថា វាមានលក្ខណៈទូលំទូលាយដូចនៅចំពោះមុខតុលាការអន្តរ-ជាតិ។ ដូច្នេះជាផលវិបាកគឺ ឯកសារទាំងអស់នេះគឺត្រូវតែយកមកពិចារណា រួមទាំងភស្តុតាងផ្ទាល់មាត់ផង។

[០៩:២០:៣៤]

ហើយលក្ខណៈគតិយុត្តិទាក់ទៅនឹងឯកសារទាំងអស់នេះ គឺវិធាន៨៧(១) គឺទាក់ទងទៅនឹងលើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុង រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក។ ហើយនេះក៏ត្រូវអនុវត្តទៅតាមប្រព័ន្ធនៃច្បាប់បារាំង ដែលត្រូវបានយកមកអនុវត្តនៅក្នុងប្រព័ន្ធច្បាប់ព្រហ្មទណ្ឌនៅក្នុងប្រទេសកម្ពុជា។ ហើយប្រសិនណាជា គឺថា ចៅក្រមត្រូវស្វែងរក អង្គជំនុំជម្រះត្រូវមានជំនឿដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ហើយមុននឹងឈានទៅដល់ការផ្តន្ទាទោសជនជាប់

ចោទ។ ដូច្នេះ ចំណុចនេះមានន័យថា ចៅក្រមអាចធ្វើការវាយតម្លៃទៅលើភស្តុតាងទាំងអស់បានដោយសេរី ហើយនេះក៏មានចែងនៅក្នុងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិដែរ នៅក្នុងករណីដែលមានពាក់ព័ន្ធទៅនឹងជនជាប់ចោទមួយចំនួន អង្គជំនុំជម្រះបានដាក់ចេញនូវគោលការណ៍ស្តីអំពីភាពអាចទទួលយកបាននៃឯកសារនៅក្នុងរឿង *ថាលិក* នៅក្នុងឆ្នាំ២០០២ *ស្តាឃិច* នៅក្នុងឆ្នាំ២០០២ ដែរ និងជនជាប់ចោទ *ម៉ាធិក* ក្នុងឆ្នាំ២០០៦។

[០៩:២១:៥៣]

ក្រុមមេធាវីការពារក្តីរបស់ អៀង សារី នៅក្នុងសារណារបស់ខ្លួនកាលពីដើមឆ្នាំនេះគឺ-- ហើយឯកសារនេះគឺជាឯកសារ E59 ដែលជាសារណាទាក់ទងទៅនឹងភាពអាចទទួលយកបាននៃឯកសារដែលចុះថ្ងៃទី២៤ ឆ្នាំ២០១១។ ហើយទាក់ទងទៅនឹងការអនុវត្តជាក់ស្តែងក្នុង-- ទាក់ទងទៅនឹងការទទួលយកបានឯកសារ។ ខ្ញុំសូមដកស្រង់សម្តីគឺថា "ភាគីត្រូវតែចាំរវាងភាពខុសគ្នា រវាងភាពអាចទទួលយកបាននៃភស្តុតាង និងទម្ងន់នៃភស្តុតាងដែលបានផ្តល់ដោយយោងទៅលើគោលការណ៍ នៃការវាយតម្លៃភស្តុតាង និងឯកសារដោយសេរី។ ហេតុដូច្នេះភាគីគឺថា-- សូមបញ្ចប់ការដកស្រង់សម្តី។

[០៩:២២:៤៧]

គោលការណ៍ ដែលអង្គជំនុំជម្រះនៅតុលាការយូហ្គោស្លាវីបានប្រើប្រាស់នោះ គឺសូមមេត្តាចងចាំថា ប្រព័ន្ធច្បាប់នោះគឺថា យោងភាគច្រើនទៅលើប្រព័ន្ធច្បាប់ខំមិនឡ នេះ ដែលអង្គជំនុំជម្រះសាលាដំបូង អាចពិនិត្យមើលភស្តុតាងទាំងអស់ ដោយមានលក្ខខណ្ឌជាក់លាក់តឹងតែងមួយចំនួន។ ដូច្នេះវិធាន ៨៧.១ គឺបង្កើតបាននូវគោលការណ៍នៃភាពអាចទទួលយកបាននៃភស្តុតាងទាំងអស់នេះ ដែលថាភស្តុតាងទាំងអស់ គឺថាអាចនឹងត្រូវវាយតម្លៃដោយសេរី ដើម្បីឱ្យអង្គជំនុំជម្រះមានជំនឿដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។

[០៩:២៣:៣៧]

ហើយវិធាន៨៧(៣) នេះគឺបានចែងថា ដែលថា គឺថា "ភស្តុតាងខ្លះអាចនឹងត្រូវច្រានចោលបានបើសិនណាជាមិនអាចមានភាពអាចឱ្យជឿជាក់បាន បង្ហាញនូវការពិតបានទេ ហើយដែលច្បាប់មិនត្រូវបានអនុញ្ញាត ឬក៏មានគោលបំណងដើម្បីពន្យារនូវដំណើរការនីតិវិធីនោះ"។ នៅក្នុងករណីរបស់ ឌុច គឺនៅក្នុង E188, E176 គឺថាក៏វាពាក់ព័ន្ធទៅនឹងវិធាន៨៧ នេះដែលទាក់ទង។ ខ្ញុំសូមដកស្រង់សម្តីថា "លក្ខខណ្ឌជាក់លាក់មួយចំនួនគឺថា ត្រូវតែមានការវាយតម្លៃឱ្យបានត្រឹមត្រូវ ហើយបទដ្ឋានជា យ៉ាង

ហោចជាអប្បបរមា គឺត្រូវយកអនុវត្តក្នុងការទទួលយកឯកសារ"។ យើងខ្ញុំយល់ឃើញថា វិធីនេះគឺវិធីមួយដែលស្របគ្នាទៅនឹងវិធីដែលត្រូវបានតុលាការអន្តរជាតិសម្រេចយកមកអនុវត្តនៅក្នុង អាយ.ស៊ី.ស៊ី នៃរឿងរបស់ *ប៉ែងហ្កា* នៅក្នុងថ្ងៃទី២០ ខែមករា ឆ្នាំ២០១១ កថាខណ្ឌ២៧ អង្គជំនុំជម្រះបានសម្រេចថា ចំពោះភស្តុតាងពាក់ព័ន្ធត្រូវតែជាភស្តុតាងបឋម ជាឯកសារបឋម ដែលមានគោលបំណងបង្ហាញបញ្ជាក់នូវជំហររបស់ភាគី។ បើសិនណាជាលក្ខខណ្ឌទីមួយនេះអាចទៅបំពេញបាននោះ លក្ខខណ្ឌតម្រូវ គឺវាអាចនឹងឆ្លើយទៅនឹងភាពដែលគួរឲ្យជឿជាក់បាននៃការទទួលយកភស្តុតាងហើយ។ នៅក្នុង អាយ.ស៊ី.ធី.វ៉ាយ ករណីរបស់ *ឡារិច* ដែលចុះថ្ងៃទី០៤ ខែមីនា ១៩៩៨ អង្គជំនុំជម្រះសម្រេចថា សម្រាប់ដើម្បី-- សម្រេចទៅលើភាពទទួលយកបាន គឺភស្តុតាងនោះ គឺត្រូវតែជាឯកសារគួរឲ្យជឿជាក់បានជាបឋម ដើម្បីធ្វើការវាយតម្លៃអាស្រ័យទៅលើកាលៈទេសៈនៃករណីនីមួយៗនោះ។ នៅក្នុងករណី ប៉ែងហ្កា នេះ ក៏ដូចគ្នា ក្នុងកថាខណ្ឌ២៩ នៃរឿងក្តីប៉ែងហ្កា(ស៊ីក)។

[០៩:២៥:៤៥]

ឯកសារតម្រូវឲ្យមានភាពពាក់ព័ន្ធ ដែលធ្វើឲ្យជាក់បានជាបឋមនោះ តើពាក្យថា ភាពឲ្យជឿជាក់ជាបឋមនោះមានន័យយ៉ាងម៉េច? មានន័យថា គឺអាចមើលឃើញដោយមួយក្រឡេកភ្នែក ឬនិយមន័យនៅក្នុងវចនានុក្រម ប្លែកឡ នោះគឺជាកម្មវត្ថុមួយដែលវាអាចបង្កើតបាននូវព័ត៌មាន ឬវចនានុក្រមអុកស្វ៊ីត ក៏និយាយថា គឺជាការឃើញមួយក្រឡេកភ្នែក ដោយមិនចាំបាច់ធ្វើការស៊ើបអង្កេត ដោយគ្រាន់តែថា ធ្វើឲ្យមានចំណាប់អារម្មណ៍ជឿជាក់បានមួយក្រឡេកភ្នែក។ នេះគឺជាបរិបទដែលត្រូវបានប្រើប្រាស់នៅក្នុងឯកសារ។ ដូច្នេះពាក្យថា "ភាពឲ្យជឿជាក់បានបឋម" នេះ គឺវាពាក់ព័ន្ធទៅនឹងភាពទាក់ទង និងភាពឲ្យជឿជាក់បាននៅពេលណាយើងទទួលឯកសារ និងជឿបានក្នុងពេលទទួលឯកសារនោះ ដោយមិនចាំបាច់មានការស៊ើប-- មិនទាន់មានការស៊ើបអង្កេតនៅឡើយនោះ។

[០៩:២៦:៥១]

ដូច្នេះ ការបកស្រាយពាក្យថា "ឯកសារបឋម"នេះ គឺជាវាពាក់ព័ន្ធទៅនឹងភស្តុតាងទាំងឡាយដែលថា នៅណាឯកសារមានការពាក់ព័ន្ធគួរឲ្យជឿជាក់ជាបឋមនោះ ៗមានន័យថា អាស្រ័យទៅលើចំណាប់អារម្មណ៍ជាដំបូងដែលចៅក្រមអាចធ្វើការសន្និតថាឯកសារនេះពាក់ព័ន្ធនិងគួរឲ្យជឿជាក់បាន។

នៅតុលាការពិសេស វិធានស្តីអំពីភស្តុតាង គឺផ្តល់ឲ្យអង្គជំនុំជម្រះ អនុញ្ញាតឲ្យអង្គជំនុំជម្រះប្រសិនណាជាអង្គជំនុំជម្រះចង់ស្វែងរកការពិត ចំពោះយថាភាពនៃការឯកសារទាំងអស់នេះ។ នៅក្នុង

វិធាន៨៩(ង) របស់ អាយ.ស៊ី.ធី.វ៉ាយ និង អាយ.ស៊ី.ធី.អ័រ ៨៩(ភ) វិធានទាំងពីរនេះ គឺជាវិធានមួយ ដែលអនុញ្ញាតឲ្យមានការពិនិត្យភស្តុតាងមិនមែនជាវិធានអាជ្ញាបញ្ញានោះទេ ដែលទាក់ទងឲ្យអង្គជំនុំជម្រះស្វែងរកយថាភាពនៃឯកសារឲ្យលើសពីវិមតិសង្ស័យ។ នៅក្នុងករណីយុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ បានសង្ខេបនូវបញ្ហានៃយថាភាពឯកសារដូចខាងក្រោមនេះ៖

[០៩:២៨:០៨]

នេះគឺរឿងក្តីរបស់ គ្រីស្ទហ្គោ ដែលទាក់ទងទៅនឹងភាពទទួលនៃឯកសារ គឺខ្ញុំសូមយកស្រង់សម្តីចេញពីកថាខណ្ឌ៣៨៧ ទៅដល់៣៨៨ នេះ។ គឺឯកសារនេះត្រូវតែបង្ហាញ ថាតើឯកសារហ្នឹងជាឯកសារមួយដែលគួរឲ្យជឿជាក់បានបំផុត ហើយដែលបង្ហាញអំពីយថាភាពនៃឯកសារនេះ។ ប៉ុន្តែមានចំណុចមិនមានការពាក់ព័ន្ធទៅនឹងចំណុចបច្ចេកទេស ទាក់ទងទៅនឹងយថាភាពនោះទេ។ នេះបើយោងទៅតាមក្នុងស្រុក។ ប៉ុន្តែយថាភាពនៅក្នុងច្បាប់អន្តរជាតិមានន័យថា ឯកសារនេះ គឺជាឯកសារដែលភាគីណាមួយដាក់ជូនតុលាការ ដោយអាស្រ័យទៅលើភាពជឿជាក់បាននៃឯកសារនេះតែម្តង។ ឧទាហរណ៍ ការស្វែងរកយថាភាពដោយតុលាការ ឬក៏មិនមានសាក្សីណាមួយអាចដឹង ហើយមិនបាច់តម្រូវឲ្យបង្ហាញនូវខ្សែសង្វាក់នៃការបញ្ហានោះទេ។ ហើយជាពិសេសទាក់ទងទៅនឹងសក្ខីកម្មដោយផ្ទាល់ ឬក៏ការដាក់សារណាណាមួយ សំណើណាមួយពីសំណាក់អ្នកស៊ើបអង្កេត។

[០៩:២៩:៣២]

ឯកសារ ខ្ញុំសូមដកស្រង់សម្តី៖ ឯកសារទាក់ទងទៅនឹងយថាភាពនៃឯកសារនោះ គឺទាក់ទងទៅនឹងភាពគួរឲ្យជឿជាក់។ ប៉ុន្តែយថាភាពរបស់វាផ្ទាល់នោះ គឺថាអាចនឹងមិនទាន់បង្ហាញបានទេ បើសិនជាមិនទាន់មានការសាកសួរដេញដោលអំពីឯកសារនោះនៅឡើយនោះទេ។ មិនមានលក្ខខណ្ឌណាតម្រូវថា ឯកសារទាំងអស់ត្រូវតែមានយថាភាពគ្រប់ឯកសារទាំងអស់នោះទេ។ តែផ្ទុយទៅវិញ ឯកសារទាំងអស់នេះ បើសិនណាជាឯកសារនោះវាអាចជួយទៅដល់ភាពគួរឲ្យជឿជាក់បានទាំងមូលតែម្តងនោះ។ ទីមួយគឺត្រូវបង្ហាញអំពីប្រភពដើមនៃឯកសារ ក៏ដូចជាការរក្សាទុកនូវឯកសារនោះ ថាតើទុកនៅទីណា ហើយដែលតុលាការអាចនឹងសម្រេចថា ឯកសារទាំងអស់នោះវាអាចជួយទៅដល់ភាពគួរឲ្យជឿជាក់បាន។

លោក លោកស្រីចៅក្រម ច្បាប់របស់ អ.វ.ត.ក យើងហ្នឹងគឺ-- ក៏ប៉ុន្តែតាមការអនុវត្តជាក់ស្តែងនៃច្បាប់-- នៃតុលាការព្រហ្មទណ្ឌអន្តរជាតិហ្នឹងមានករណីមួយចំនួន មានលក្ខណៈស្រដៀងគ្នា

ដោយសារថារឿងក្តីខ្លះគឺថាត្រូវបានអង្គជំនុំជម្រះសាលាដំបូងតុលាការអន្តរជាតិហ្នឹង កាត់បន្ថយច្រានចោលនូវភស្តុតាងខ្លះ ក៏ប៉ុន្តែក៏ត្រូវជួយចំពោះភាពជឿជាក់បានសម្រាប់ឯកសារទាំងអស់នោះផងដែរ។

អ៊ីចឹងបើយើងពិនិត្យមើលទៅលើរឿងក្តីទាំងអស់នេះឃើញថា សហព្រះរាជអាជ្ញាបានបង្ហាញជូន បានធ្វើការបំភ្លឺមួយជូនដល់អង្គជំនុំជម្រះនៅពេលណាពាក់ព័ន្ធទៅនឹងភាពឲ្យជឿជាក់បាននៃឯកសារទាំងអស់នេះ។

[០៩:៣១:២០]

តុលាការត្រូវពិនិត្យមើលកត្តាពីរ ទាក់ទងទៅនឹងភាពឲ្យជឿជាក់បាន គឺនិយាយអំពីចរិតលក្ខណៈខាងក្នុងរបស់ឯកសារនេះ ក៏ដូចជាចរិតលក្ខណៈខាងក្រៅនៃឯកសារនេះ។

ឥឡូវសូមពិនិត្យមើលទៅលើចរិតលក្ខណៈខាងក្រៅនៃឯកសារនេះ។ បើសិនឯកសារនេះវាមានប្រភព ឬក៏មានឈ្មោះអ្នកនិពន្ធត្រឹមត្រូវ អ្នករៀបចំត្រឹមត្រូវ នោះបញ្ជាក់អំពីភាពគួរឲ្យជឿជាក់បានហើយ។ តើឯកសារនេះត្រូវបានចេញឡើងដោយស្ថាប័នសាធារណៈ ឬក៏អង្គភាពសាធារណៈមួយឬក៏អត់នោះ វាកាន់តែបន្ថែមទម្ងន់នៃភាពឲ្យគួរឲ្យជឿជាក់បានទៅទៀតហើយ។ ឯកសារខ្លះវាអាចមិនមានហត្ថលេខា មិនមានត្រា មិនមានស្នាមម្រាមដៃ ឬក៏មិនមានការចារដោយចំណុចណាមួយ ឬក៏មានកំណត់ចំណាំណាមួយនោះ។

[០៩:៣២:០៦]

ដូច្នេះ គេត្រូវពិនិត្យមើលទៅលើទម្រង់នៃឯកសារនេះ តើវាជាប្រភេទឯកសារសរសេរដោយដៃផ្ទាល់ឬក៏ជាឯកសារដែលត្រូវវាយជាអក្សរពុម្ព? ហើយថាតើឯកសារនេះ វាមានប្រភពចេញមកពីណា ឬក៏ចេញមកពីអ្នកនិពន្ធណា? ហើយនិងវាទាក់ទងទៅនឹងទម្រង់ថាតើវាចេញពីប្រភពហ្នឹង ឬក៏ចេញពីអ្នកនិពន្ធណាមួយក្នុងទម្រង់ណាមួយ? កាលបរិច្ឆេទនៃការចេញឯកសារនោះ តើវាចេញជាឯកសារសហការ ចេញក្នុងពេលដំណាលគ្នានោះ ឬក៏យ៉ាងណា?

[០៩:៣២:៤០]

ចំណុចមួយទៀតទាក់ទងទៅនឹងខ្លឹមសារនៃឯកសារ។ តើឯកសារទាំងអស់នោះ វាអាចប្រើជាៗក្រៀមភាសា ឬក៏អាចប្រើជាភាសាអ្វីមួយ ហើយអ្នកដែល-- ទីមួយគឺត្រូវបង្ហាញអំពីប្រភពនៃឯកសារនេះឬក៏អង្គការ ឬស្ថាប័នណាដែលចេញឯកសារនោះ? តើគោលបំណងនៃឯកសារនេះ វាកំណត់នូវអត្តសញ្ញាណណាមួយទេ? បង្ហាញនូវគោលនយោបាយណាមួយដែលគេត្រូវបានគេដឹងឮជាទូទៅទេ?

ឬក៏អ្នកនិពន្ធណាមួយនៅពេលនោះ តើឯកសារនោះមានភាពស៊ីសង្វាក់គ្នាផ្ទៃក្នុងដែរឬទេ?

ប្រសិនណាឯកសារមួយវាមានភាពស៊ីសង្វាក់គ្នានៃផ្ទៃក្នុង ក្នុងលក្ខណៈជាផ្ទៃក្នុងនោះ នោះមានន័យថា វាមានកត្តាខាងក្នុងមួយចំនួនដែលអង្គជំនុំជម្រះត្រូវពិនិត្យមើលដើម្បីពិចារណា ថាតើវាមានភាពឲ្យជឿជាក់បានស៊ីសង្វាក់គ្នាដែរឬក៏យ៉ាងនោះ?

[០៩:៣៣:៤៥]

ទាក់ទងទៅនឹងចរិតលក្ខណៈខាងក្រៅនៃឯកសារនេះ មានកត្តាមួយចំនួនដែលត្រូវយកមកដាក់បញ្ចូលដើម្បីពិចារណា ថាតើឯកសារហ្នឹង វាមានយថាភាពទេ? តើឯកសារមួយ ឬឯកសារច្រើននោះមានលក្ខណៈស្រដៀងគ្នា ដែលត្រូវអាចនឹងបញ្ជាក់អះអាងអំពីយថាភាពរបស់វាតាមរយៈអ្នករៀបចំឯកសារនោះ អ្នកនិពន្ធឯកសារនោះ ឬក៏ដោយអ្នកសាក្សីជំនាញ ឬក៏យ៉ាងម៉េចដែរ?

ទាក់ទងនឹងអត្តសញ្ញាណនៃឯកសារនេះ បើសិនឯកសារមួយ ឬឯកសារច្រើនត្រូវបានអ្នកនិពន្ធ ឬក៏សាក្សីដែលមានការយល់ដឹងត្រឹមត្រូវ ឬអ្នកជំនាញ ហើយមិនមានការជំទាស់តវ៉ាទាក់ទងទៅនឹងយថាភាពទេនោះ វាពាក់ព័ន្ធទៅនឹងបញ្ហាវិមតិសង្ស័យនៃឯកសារទាំងអស់នេះ។

[០៩:៣៤:៣៤]

ហើយភស្តុតាងគឺវាឆ្លើយតបទៅនឹងឯកសារផ្សេងទៀត ឬក៏សក្ខីកម្មផ្សេងទៀតដែរឬទេ ដែលវាពាក់ព័ន្ធទៅនឹងភាពពិតប្រាកដនៃខ្លឹមសាររបស់វា? ថាតើយើងដឹងថាឯកសារនោះបានរកឃើញដោយរបៀបណា? រកឃើញពីទីកន្លែងណា? ហើយវាពាក់ព័ន្ធគ្នាដែរឬទេ?

ឧទាហរណ៍ នៅពេលដែលឯកសារនោះរកឃើញនោះ ថាតើឯកសារទាំងអស់នោះ វារកឃើញនៅទីកន្លែងដែលយើងគិតថា វាគួរជាទីកន្លែងដែលយើងគួរតែរកឃើញឯកសារនោះដែរឬទេ? ឬក៏ទីកន្លែងនោះវាមានជាប់ទាក់ទងទៅនឹងប្រភព ឬក៏អ្នកសរសេរដែរឬទេ?

ចំណុចចុងក្រោយ ការរក្សាទុកឯកសារ។ ថាតើការផ្តល់ឯកសារទាំងអស់នោះ ភាគីនិងចៅក្រមយកវាមកដោយរបៀបណា? តើយើងដឹងថា អ្នកណាជាអ្នករក្សាទុកដែរឬទេ នៅពេលដែលភាគីបង្ហាញភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះនោះ?

លោក លោកស្រីចៅក្រមជាទីគោរព! ទាំងអស់នេះហើយ គឺជាការពិចារណាដ៏ទូលំទូលាយទៅលើកត្តាទាំងអស់នេះ កត្តាមួយចំនួនច្បាស់លាស់ ហើយពេលខ្លះទៅ យើងមិនត្រូវមើលរំលងនោះទេ។ បញ្ហាបច្ចេកទេសដែលយើងត្រូវមើលនោះ គឺលើលក្ខណៈវិនិច្ឆ័យមួយ ឬក៏ពីរ នៅពេលដែលយើង

ពិចារណាទៅលើយថាភាព។

[០៩:៣៥:៥៥]

លោក លោកស្រីចៅក្រមបានសម្រេចរួចហើយថា ភាពដើមនៃឯកសារគឺវាមិនទាមទារដើម្បីអាចទទួលយកឯកសារនៅក្នុងពេលនេះឡើយ។ សាលាក្ដីដទៃៗទៀតគឺគេក៏ប្រើប្រាស់ឯកសារថតចម្លងនេះផងដែរ។

នៅពេលនេះយើងសូមចូលទៅដល់ភាពខុសគ្នារវាងយថាភាព និងតម្លៃនៃភស្ដុតាង។ តម្លៃនៃភស្ដុតាងគឺត្រូវបានរៀបរាប់នៅក្នុងយុត្តិសាស្ត្រអន្តរជាតិ ជាពិសេសនៅក្នុងការសរសេររបស់អ្នកសិក្សាស្រាវជ្រាវដែលវាពាក់ព័ន្ធទៅនឹងភាពពាក់ព័ន្ធនៃឯកសារ។ ដូច្នេះហើយ លក្ខណៈវិនិច្ឆ័យចំពោះភស្ដុតាងដែលមានតម្លៃជាភស្ដុតាង នៅដំណាក់កាលដំបូងគឺអាចបំពេញទៅបាននៅពេលដែលយើងបង្ហាញថាឯកសារទាំងអស់នោះវាពាក់ព័ន្ធជាបឋម ហើយវាមានភាពពាក់ព័ន្ធ។

[០៩:៣៦:៥២]

ចំណុចមួយទៀត តុលាការសៀរ៉ាឡេអូន សាលាដំបូងនៅក្នុងរឿងក្ដីឆាល ថេល័រ (*Charles Taylor*) នៅពេលដែលសម្រេចទៅលើឯកសារដែលពាក់ព័ន្ធនៅក្នុងខែកញ្ញា ឆ្នាំ២០១០ គេសម្រេចថាតម្លៃនៃភស្ដុតាង ឬទម្ងន់នៃភស្ដុតាង គឺវាត្រូវយកមកវាយតម្លៃដោយសាលាដំបូង នៅពេលដែលគេស្ដាប់ទៅលើចម្លើយ និងឯកសារទាំងអស់នោះ។ បន្ទុកនៃការបង្ហាញ គឺត្រូវទៅលើភាគីដែលគាត់ទាមទារឲ្យមានការបង្ហាញទៅលើកម្រិតនៃភាពពាក់ព័ន្ធ និងភាពអាចទុកចិត្តបាននៃឯកសារ។

គឺវាមិនតម្រូវឲ្យភាគីម្ខាងទៀត ជាអ្នកបង្ហាញទៅលើតម្លៃនៃភស្ដុតាងនោះទេ។ ដូចដែលបានកត់សម្គាល់នៅក្នុងសាលាដំបូងនេះ ឬសាលាដំបូងដទៃៗទៀត ការវាយតម្លៃទៅលើតម្លៃនៃភស្ដុតាង ឬក៏ទម្ងន់នៃភស្ដុតាង និងឯកសារ គឺជាលក្ខខណ្ឌមួយដាច់ដោយឡែក។

ដូច្នេះទម្ងន់ទាំងអស់នេះ គឺត្រូវផ្ដល់ជូននៅពេលដែលយើងស្ដាប់ទៅលើចម្លើយ និងឯកសារទាំងអស់នេះ។ ដូចដែលលោកស្រីៗចៅក្រមលើកឡើងនៅក្នុងកថាខណ្ឌ៤២ នៃសាលក្រមរបស់ ឌុច គឺបានលើកឡើងអំពីការសម្រេចទៅលើភស្ដុតាង ថាតើភស្ដុតាងទាំងអស់នោះវាបានបង្ហាញទៅលើការចោទប្រកាន់នៅក្នុងរឿងក្ដីនេះដែរឬទេ?

នៅក្នុងភាពអាចនឹងទទួលយកបាននៅចំពោះមុខៗសាលាដំបូង ថាភស្ដុតាងនោះគឺទាំងមូល ឬក៏វាមួយផ្នែកនៃអង្គជំនុំជម្រះ គឺក្នុងនាមជាចៅក្រមវិជ្ជាជីវៈ គឺត្រូវពិចារណាទៅលើភាពជាក់លាក់នៃ

ភស្តុតាងទាំងអស់នេះ។ ដូច្នេះ ក្នុងនាមជាចៅក្រម និងក្រុមប្រឹក្សាវិនិច្ឆ័យ គឺគេបានសម្រេចនៅក្នុងតុលាការអន្តរជាតិ។

[០៩:៣៨:៥០]

លោក លោកស្រីចៅក្រម ខ្ញុំសូមសន្និដ្ឋានបញ្ចប់ មេធាវីការពារក្ដីលើកឡើងអំពីលក្ខខណ្ឌអប្បបរមា ដែលទាមទារឲ្យសហព្រះរាជអាជ្ញា ឬក៏ភាគីដទៃទៀត បង្ហាញឲ្យបានវិជ្ជមានទៅលើយថាភាពនៃឯកសារ។ យុត្តិសាស្ត្រអន្តរជាតិបានបង្ហាញថា មិនមានបន្ទុកណាមួយដាក់ទៅលើភាគីដូច្នេះនោះទេ គឺចៅក្រមដែលជាអ្នកមានបទពិសោធន៍ និងវិជ្ជាជីវៈ ដែលត្រូវវាយតម្លៃទៅលើលក្ខណៈវិនិច្ឆ័យ ហើយចេញសេចក្ដីសម្រេចទៅលើយថាភាព និងការទទួលយកភស្តុតាង។

[០៩:៣៩:២៩]

ការទទួលយកភស្តុតាងនេះ មិនមែនមានន័យថា យើងត្រូវដកហូតទម្ងន់នៃភស្តុតាងទាំងអស់នោះទេ។ ចៅក្រមត្រូវស្ដាប់ទៅលើភស្តុតាង ហើយនិងផ្ដល់ទម្ងន់ឲ្យបានជាក់លាក់នៅក្នុងកិច្ចដំណើរការនីតិវិធី។ នៅក្នុងរឿងក្ដីជាច្រើន នៅពេលដែលឯកសារមួយចំនួនមិនមាន ឬក៏ប្រភពនៃឯកសារមួយចំនួនមិនអាចបង្ហាញបាននោះ នៅក្នុងយុត្តិសាស្ត្រអន្តរជាតិ មិនមែនថាកង្វះនៃចំណុចទាំងអស់នេះធ្វើឲ្យភស្តុតាងមិនអាចទុកចិត្ត ហើយមិនអាចទទួលយកបាននោះទេ។ នៅគ្រប់ដំណាក់កាលទាំងអស់ គឺគេបើកឲ្យមេធាវីការពារក្ដី និងភាគីទាំងឡាយធ្វើការតវ៉ាទៅលើយថាភាពនៃឯកសារ។ ដូច្នេះ នៅក្នុងច្បាប់គឺមិនមែនមានបទបទប្បញ្ញត្តិចែងជាទូទៅថាភស្តុតាងទាំងអស់មិនអាចទទួលយកបាននោះទេ ហើយទាមទារឲ្យបង្ហាញលក្ខខណ្ឌអតិបរមា ដែលត្រូវតែបង្ហាញនៅយុត្តិសាស្ត្រអន្តរជាតិដូចដែលនៅក្នុងរឿងក្ដីរបស់យើងនេះទេ។ នេះជាគឺសេចក្ដីបញ្ចប់ចុងក្រោយហើយនៃសេចក្ដីសន្និដ្ឋានរបស់យើងខ្ញុំ។

សូមអរគុណលោក លោកស្រីចៅក្រម។

[០៩:៤០:៤៤]

**ប្រធានអង្គជំនុំ៖**

អរគុណតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ហើយជាកិច្ចបន្តនេះអង្គជំនុំជម្រះសូមប្រគល់វេទិកាទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ ដោយសារមេធាវីមានពេលចំនួន៣០នាទីដើម្បីលើកឡើងអំពីបញ្ហាភស្តុតាងទូទៅដែលមានការ-- ឯកសារនានាដែលពាក់ព័ន្ធនឹងសវនាការ។

[០៩:៤១:២២]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម សូមគោរពព្រះសង្ឃ និងសូមគោរពសាធារណជនទាំងអស់។ យើងខ្ញុំមុននឹងឆ្លៀតឱកាសដែលផ្តល់ជូននោះ ក្នុងការផ្តល់ជូននូវការកត់សម្គាល់មួយចំនួនដែលជាលក្ខណៈទូទៅអំពីទស្សនៈរបស់យើងជាដើមបណ្តឹងរដ្ឋប្បវេណី។

ការសង្កេតទាំងអស់នេះនឹងនិយាយអំពីឯកសារដែលមានចែងនៅក្នុងជើងទំព័រ ហើយនិងទៅលើភស្តុតាងផ្សេងទៀតដែលផ្តល់ជូនដោយភាគីផ្សេងៗ។ យើងគិតថា ការសង្កេតនេះគឺជាការបំពេញបន្ថែមទៅនឹងការសង្កេតរបស់សហព្រះរាជអាជ្ញា។ ដូច្នេះ ខ្ញុំនឹងលើកឡើងអំពីការសង្កេតពីរ។

ទីមួយ គឺពាក់ព័ន្ធទៅនឹងភាពអាចទទួលយកបាននៃឯកសារដែលពាក់ព័ន្ធទៅនឹងតួនាទីរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងអង្គជំនុំជម្រះ ហើយនិងទីពីរនឹងពាក់ព័ន្ធទៅនឹងយុត្តិសាស្ត្ររបស់អ.វ.ត.ក។ ប៉ុន្តែជាបឋម ហើយនិងជាដំបូងនេះ ខ្ញុំសូមអនុញ្ញាតលើកឡើងនូវការភ្ញាក់ផ្អើលមួយចំនួននៅពេលដែលអានទៅនឹងឯកសារជំទាស់មួយចំនួនដែលលើកឡើងដោយខាងមេធាវីការពារក្តី។ ហើយឯកសារជាច្រើននៃការជំទាស់នេះ គឺថាត្រូវបានសម្រេចរួចហើយទៅហើយដោយច្បាប់ ហើយនិងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ឬមួយក៏ដោយយុត្តិសាស្ត្ររបស់ អ.វ.ត.ក ហើយនិងស្ថាប័នតុលាការអន្តរជាតិផ្សេងៗទៀត។

[០៩:៤២:៥៥]

ការលើកឡើងនូវការជំទាស់ជាថ្មីម្តងនេះ គឺមិនមែនបានន័យថាមិនដឹងអំពីការអនុវត្តច្បាប់ខាងសហមេធាវីការពារក្តីនោះទេ គឺប្រហែលជាឆន្ទៈក្នុងការបដិសេធច្បាប់ក្នុងការមិនទទួលយកនឹងវិធានផ្ទៃក្នុង ហើយនិងការបដិសេធចោលនូវយុត្តិសាស្ត្រអន្តរជាតិផ្សេងៗ។ ដូច្នេះ គោលជំហរនេះ គឺមិនអាចទទួលយកបានទេ គឺជាការបង្ហិនពេលវេលា ហើយវាអាចប៉ះពាល់ដល់ភាគីផ្សេងទៀត ហើយជាពិសេសប៉ះពាល់ទៅដល់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការទទួលបាននូវសេចក្តីសម្រេចតុលាការក្នុងរយៈពេលមួយសមស្រប។

[០៩:៤៣:៣០]

យើងទាំងអស់គ្នាដឹងហើយថាយើងនៅក្នុងនេះ គឺយើងអនុវត្តច្បាប់ប្រព័ន្ធស៊ីវិលឡ ដែលហើយនិងយកចេញពីច្បាប់កម្ពុជាផងដែរ។ ដូច្នេះ វិធានផ្ទៃក្នុងក៏ធ្វើឡើងនៅក្នុងក្របខ័ណ្ឌនេះ គឺថាវិធានដែលមានជាធរមាន គឺជាវិធានដែលត្រូវអនុវត្តនៅក្នុងតុលាការនេះ។ ដូច្នេះ លោកសហព្រះរាជអាជ្ញាបានលើកឡើងអម្បាញ់មិញនេះហើយ គឺថាភស្តុតាងយើងអាចលើកឡើងដោយសេរីដើម្បីបង្ហាញភស្តុតាង

ហើយតុលាការអាចចេញសេចក្តីសម្រេចទៅលើការជឿជាក់ដោយគ្មានវិមតិសង្ស័យ។ ហើយនៅពេលដែលខ្ញុំនិយាយអំពីចៅក្រមនេះ ខ្ញុំនិយាយអំពីចៅក្រមជំនុំជម្រះ។ ហើយនៅចំពោះមុខចៅក្រមជំនុំជម្រះក៏យើងមានចៅក្រមស៊ើបអង្កេត ហើយយើងមានចៅក្រមនៃអង្គបុរេជំនុំជម្រះផងដែរ។ ឯកសារត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង ហើយឯកសារខ្លះ គឺចេញពីកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត ហើយខ្ញុំនឹងនិយាយនេះនៅពេលក្រោយ ហើយឯកសារផ្សេងទៀតផ្តល់ជូនដោយភាគី។

[០៩:៤៤:៤០]

ដូចលោកសហព្រះរាជអាជ្ញាបញ្ជាក់ជូនអម្បាញ់មិញនេះហើយ គឺតម្លៃភស្តុតាង ឬក៏ទម្ងន់ជាភស្តុតាងនៃឯកសារនឹងត្រូវវាយតម្លៃ ដោយអង្គជំនុំជម្រះដើម្បីបង្ហាញអំពីការជឿជាក់ដោយគ្មានវិមតិសង្ស័យ ហើយនិងបង្ហាញនៃការពិត។ នៅពេលចប់នៅការជំនុំជម្រះ នៅពេលដែលចេញសេចក្តីសម្រេចអង្គជំនុំជម្រះនឹងពិនិត្យមើលថា តើភស្តុតាងទាំងអស់នោះ ដែលត្រូវបានទទួលនោះ គឺថាមានលក្ខណៈគ្រប់គ្រាន់ដើម្បីលាតត្រដាងនូវពិរុទ្ធភាពឲ្យហួសពីវិមតិសង្ស័យរបស់ជនជាប់ចោទក៏ដោយ។ ហើយក៏មានអង្គជំនុំជម្រះ ដែល E59 ដែរ អង្គជំនុំជម្រះបានបញ្ជាក់ថា នៅពេលចុងក្រោយអង្គជំនុំជម្រះនឹងវាយតម្លៃទៅលើតម្លៃជាភស្តុតាងនៃឯកសារ។ ហើយបញ្ហានៃភាពអាចទទួលយកបាននៃឯកសារ គឺបានចោទឡើង គឺថាមិនមែនតាំងពីពេលនេះទេ គឺចោទឡើងតាំងពីដំបូងនៃការស៊ើបអង្កេតនោះម្ល៉េះ គឺនៅចាប់តាំងពីពេលដែលសហចៅក្រមស៊ើបអង្កេត គឺគាត់ទទួលខុសត្រូវក្នុងការបង្កើតនូវសំណុំភស្តុតាង។

[០៩:៤៥:៥៦]

ហើយបញ្ហានៃភាពអាចទទួលយកបាននេះ គឺថាមិនអាចចោទឡើងដដែលៗនៅពេលដែលបញ្ហានោះត្រូវបានដោះស្រាយរួចមកហើយ ដោយវិធានផ្ទៃក្នុង ឬក៏ដោយសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ឬក៏របស់តុលាការ។ ដូច្នេះ យើងមិនអាចចោទឡើងដដែលៗនូវបញ្ហាដែលភាពមិនអាចទទួលនៃឯកសារនេះទេ ពីព្រោះថាយើងស្ថិតនៅក្នុងប្រព័ន្ធរ៉ូម៉ាំងអាល្លឺម៉ង់ គឺច្បាប់ស៊ីវិលឡ ហើយដូច្នេះតម្លៃយុត្តាធិការរបស់សហចៅក្រមស៊ើបអង្កេត គឺថាមិនអាចត្រូវសើរើ ឬក៏ពិនិត្យមើលឡើងវិញបានទេ លើកឡើងតែមានការប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។

[០៩:៤៦:៤១]

អាស្រ័យហេតុនេះហើយ បញ្ហានៃភាពមិនអាចទទួលយកបាននៃឯកសារ គឺយើងអាចពិភាក្សាគ្នាក្នុងកម្រិតមួយដែលមានភាពរឹតត្បិតមែនទែននៅក្នុងវិធាន៨៧ ហើយដូច្នេះគឺថា អ្នកដែលលើកឡើង

នូវការជំទាស់នេះ គឺថាត្រូវតែបង្ហាញមូលលទ្ធភាព-- ហើយជាថ្មីម្តងទៀត លោកសហព្រះរាជអាជ្ញាបានលើកឡើងមកហើយ ប៉ុន្តែខ្ញុំក៏សុំលើកឡើងម្តងទៀត គឺថាត្រូវបែងចែកឲ្យបានច្បាស់ រវាងដំណាក់កាលនៃការទទួលយកឯកសារ ហើយនិងដំណាក់កាលនៃតម្លៃភស្តុតាងដែលជាបញ្ហាសំខាន់ សម្រាប់តុលាការ។

[០៩:៤៧:២១]

អ្វីដែលជាការសង្កេតបឋមរបស់ខ្ញុំជាចុងក្រោយនេះ គឺថា នៅពេលដែលលើកឡើងការជំទាស់នោះ គឺសហមេធាវីការពារក្តីបានលើកឡើងអំពីការជំនុំជម្រះដោយយុត្តិធម៌ ប៉ុន្តែនៅពេលដែលលើកឡើងអំពីការជំទាស់នោះ គឺយើងមានសារៈសំខាន់ត្រូវរំឭកឡើងថា ការជំនុំជម្រះក្តីដោយយុត្តិធម៌នោះមិនមែនជាបុព្វសិទ្ធិរបស់ខាងមេធាវីការពារក្តីនោះទេ។ ហើយដូចគ្នាផងដែរ ខាងមេធាវីការពារក្តី គឺថាបានលើកឡើងអំពីភាពមិនអាចទទួលយកបានដោយផ្នែកដើមបណ្តឹងរដ្ឋប្បវេណីដែលធ្វើឲ្យមានបញ្ហា។ ប៉ុន្តែភាពដោយផ្នែកនោះ គឺថាមិនមែនជាបញ្ហារបស់ដើមបណ្តឹងរដ្ឋប្បវេណីទេ វាជាលក្ខណៈមួយដែលកត់សម្គាល់នូវភាគីទាំងអស់នៅក្នុងរឿងក្តី។ ផ្ទុយទៅវិញ ចៅក្រមទាំងអស់នៅក្នុងគ្រប់ដំណាក់កាលជំនុំជម្រះទាំងអស់ គឺថាគាត់មិនមែនថា គាត់មិនមានភាពលម្អៀងនោះទេ។ ហើយការកត់សម្គាល់របស់ខ្ញុំនេះ គឺពាក់ព័ន្ធនឹងតួនាទីរបស់សហចៅក្រមស៊ើបអង្កេតផងដែរ។

[០៩:៤៨:៣៥]

មេធាវីការពារក្តី គឺគាត់បានយល់ព្រមក្នុងការទទួលយកនូវតួនាទីរបស់សហចៅក្រមស៊ើបអង្កេត ហើយក្នុងឋានៈរបស់គាត់ជាចៅក្រមមួយរូប ជាចៅក្រមដែរ គឺគាត់មានអំណាច មានយុត្តាធិការក្នុងការសម្រេច។ ហើយសេចក្តីរបស់ចៅក្រមស៊ើបអង្កេត កិច្ចស៊ើបសួររបស់គាត់ គឺថាមានតម្លៃជាផ្លូវការគឺដូចជាសេចក្តីសម្រេច ហើយនិងកិច្ច ការបំពេញកិច្ចរបស់អង្គជំនុំជម្រះដែរ របស់ចៅក្រមជំនុំជម្រះដែរ។ ហើយវត្តមានរបស់ក្រឡាបញ្ជីចំពោះៗ នៅអមនឹងចៅក្រមស៊ើបអង្កេតនេះ គឺរបៀបមួយនៃការបញ្ជាក់អំពីយថាភាពនៃការបំពេញកិច្ចរបស់សហចៅក្រមស៊ើប ហើយនិងបញ្ជាក់អំពីកិច្ចឯកសារផ្សេងៗផងដែរ។

[០៩:៤៩:២៩]

ចៅក្រមស៊ើបអង្កេត គាត់ស៊ើបអង្កេតរកភស្តុតាងដោះបន្ទុក និងភស្តុតាងដាក់បន្ទុកទាំងពីរ។ ផលប្រយោជន៍របស់ចៅក្រមស៊ើបអង្កេតនៅក្នុង អ.វ.ត.ក នៅក្នុងដំណាក់កាលនៃការស៊ើបសួរនេះ

គឺថា ផ្តល់ជូននូវអង្គជំនុំជម្រះនូវភស្តុតាងឯកសារគ្រប់គ្រាន់ ហើយប្រាកដប្រជាមានតម្លៃដែលអនុញ្ញាតឲ្យកុំឲ្យអង្គជំនុំជម្រះធ្វើការប្រមូលភស្តុតាងឡើងវិញ។ នៅក្នុងកថាខណ្ឌ១៣២០ ដល់១៣២៤ នៅក្នុងចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា សំណុំឯកសារទាំងអស់ដែលដាក់ចូលទៅក្នុងសំណុំរឿង គឺឯកសារដែលចែងនៅក្នុងជើងទំព័រ។ ឯកសារទាំងអស់នេះ គឺថាត្រូវតែមានតម្លៃជាផ្លូវការច្បាស់លាស់ ហើយគាំទ្រទៅលើបទចោទដើម្បីផ្តល់នូវតម្លៃជាភស្តុតាង ហើយដើម្បីគាំទ្រនូវគោលការណ៍ដែលកំណត់នូវបន្ទុកគ្រប់គ្រាន់ ដែលជាទំនួលខុសត្រូវរបស់ចៅក្រមស៊ើបអង្កេត។

ដូច្នេះ ចៅក្រមស៊ើបអង្កេត គាត់ត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់ទៅលើចំណុចនេះ ហើយអ្វីដែលជាចៅក្រម-- ដែលខាងមេធាវីការពារក្តីសុំឲ្យធ្វើនោះ គឺថាចៅក្រមស៊ើបអង្កេតគាត់បានធ្វើរួចហើយនៅក្នុងក្របខ័ណ្ឌនៃអំណាចយុត្តាធិការ និងអំណាចនៃការសម្រេចរឿងរបស់គាត់។

ដូច្នេះ ខ្ញុំនឹងនិយាយតែអំពីការទទួលយកបាន ហើយខ្ញុំមិននិយាយអំពីតម្លៃជាភស្តុតាង ហើយនិងជាទម្ងន់នៃភស្តុតាងដែលអង្គជំនុំជម្រះនឹងវាយតម្លៃនោះទេ។

[០៩:៥១:២០]

យើងត្រូវរំឭកផងដែរ បើតាមវិធាន៥៥ ទៅដល់វិធាន៦២ នៃវិធានផ្ទៃក្នុង គឺអង្គជំនុំជម្រះ (សុំទោស) ចៅក្រមស៊ើបអង្កេតគាត់ពិនិត្យទៅលើភាពអាចទទួលយកបាន និងភាពជឿជាក់បាននៃឯកសារដែលខ្លួនទទួលបាន ហើយនិងសម្រេចដាក់បញ្ចូលទៅក្នុងសំណុំរឿង។ សូមរំឭកផងដែរថា នៅពេលដែលចៅក្រមស៊ើបអង្កេតធ្វើការស៊ើបសួរ ឬក៏សួរចម្លើយនោះ គឺថាយើងមានកំណត់ច្បាស់លាស់ហើយនៅក្នុងផ្ទៃក្នុង ហើយត្រូវតែមានការបញ្ជាក់ពីយថាភាពដោយក្រឡាបញ្ជី។ យើងត្រូវ សូមរំឭកផងដែរថា កិច្ចឯកសារគឺអាចពិភាក្សា បដិសេធ ឬក៏ប្រឈមមុខដាក់គ្នា ប្រឈមមុខគ្នានៅក្នុងពេលអំឡុងពេលនៃការស៊ើបអង្កេត។

[០៩:៥២:១០]

ហើយការដែលមិនយកឱកាសនេះ ក្នុងការវិភាគនោះ គឺជាវាជាការបង្ហាញមួយពាក់ព័ន្ធទៅនឹងឯកសារពាក់ព័ន្ធ គឺថាវាមិនមានភាពច្បាស់លាស់។ សូមរំឭកផងដែរថា នៅពេលបញ្ចប់ការស៊ើបសួរចៅក្រមស៊ើបអង្កេតធ្វើសេចក្តីសន្និដ្ឋានមួយដែលផ្អែកទៅលើភស្តុតាងទាំងអស់ ដែលដាក់ជូនដោយភាគីហើយនៅពេលនោះ គឺថាមានបើសិទ្ធិឲ្យមានការតវ៉ាមួយទៀតក្នុងរយៈពេលមួយដែលកំណត់ដោយវិធានផ្ទៃក្នុង ហើយនៅក្នុងរយៈពេលនោះ ភាគីទាំងអស់អាចលើកឡើងអំពីការជំទាស់តវ៉ារបស់ខ្លួន។

[០៩:៥២:៥១]

ហើយជាចុងក្រោយ សូមរំឭកផងដែរថា ដីកាដំណោះស្រាយដែលមានបង្ហាញហេតុផលច្បាស់លាស់ គឺថាអាចនឹងធ្វើការប្ដឹងឧទ្ធរណ៍បានចំពោះដីកាដំណោះស្រាយ។ ដូច្នេះ លទ្ធភាពនៃការជំទាស់តវ៉ាទៅនឹងកិច្ចបំពេញស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតនេះ គឺបានបញ្ជាក់ដើម្បីបង្ហាញអំពីថាដើម្បីធ្វើម៉េច ដើម្បីដកចេញនូវបញ្ហានៃភាពអាចទទួលយកបាននេះ។ ហើយជាចុងក្រោយ ដីកាដំណោះស្រាយ នៅពេលដែលផ្អែកទៅលើភស្តុតាងដែលមាននៅក្នុងជើងទំព័រ គឺបង្ហាញអំពីលក្ខណៈច្បាស់លាស់ ភាពពាក់ព័ន្ធ ភាពអាចទទួលយកបាន ហើយនិងយថាភាពជាលក្ខណៈស្ថាពរ ហើយនៅពេលដែលលែងមានការប្ដឹងផ្ដល់អស់ហើយ គឺជាក្នុងករណីសំណុំរឿង០០២ នេះឯងហើយ។

[០៩:៥៣:៤៨]

ភាពអាចទទួលយកបាននៃឯកសារមិនមែនត្រឹមតែពាក់ព័ន្ធទៅនឹងករណីលើកលែង ឬក៏ករណីពិសេសនោះទេ ឬក៏ករណីតែ--។ ហេតុដូច្នេះ ការជំទាស់តវ៉ាណាមួយនោះ គឺត្រូវតែបញ្ជាក់ហេតុផលបញ្ជាក់នូវសំអាងហេតុឲ្យបានច្បាស់លាស់ ចំពោះអ្នកដែលបានលើកនូវការជំទាស់ ដូចយោងតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង។ ហើយលើសពីនេះទៅទៀត ដោយអនុវត្តតាមវិធាន៧៦(៧) នៃវិធានផ្ទៃក្នុង សូមរំឭកថា កិច្ចនីតិវិធីដែលធ្វើឡើងដោយចៅក្រមស៊ើបអង្កេត ហើយនិងឯកសារដែលចេញមកអំពីកិច្ចនីតិវិធីនេះ ដូចជា កំណត់ហេតុសួរចម្លើយជាដើម គឺត្រូវមានគ្របដណ្ដប់ទៅដោយដីកាដំណោះស្រាយមួយ។ ហើយដូច្នេះ មិនអាចលើកអំពីមោឃភាពប្រឆាំងបានឡើយទៅនឹងដីកាដំណោះស្រាយនេះ។ ដូច្នេះគ្មានអ្នកណាមួយជំទាស់ថា យើងមិនអនុវត្តនូវវិធាននេះទេ ហើយវិធាននេះ គឺយ៉ាងថែងយ៉ាងច្បាស់អំពីអំណាចយុត្តាធិការ និងអំណាចសម្រេចរបស់ចៅក្រមស៊ើបអង្កេត។

[០៩:៥៥:០០]

ដូច្នេះ នៅក្នុងក្របខ័ណ្ឌនៃការអង្កេតដំបូងរបស់ខ្ញុំនេះ ខ្ញុំចង់លើកឡើងនូវចំណុចមួយពាក់ព័ន្ធទៅនឹងភាពអាចទទួលយកបាននៃដើមបណ្ដឹងរដ្ឋប្បវេណី។ យោងតាមអំណាចយុត្តាធិការ និងអំណាចសម្រេចរបស់ចៅក្រមស៊ើបអង្កេត គឺមាននៅភាពច្បាស់លាស់មួយទៀត ពាក់ព័ន្ធទៅនឹងការទទួលយកបាននៃដើមបណ្ដឹងរដ្ឋប្បវេណី។ នៅពេលចៅក្រមស៊ើបអង្កេតសម្រេចទៅភាពអាចទទួលយកបាននៃដើមបណ្ដឹងរដ្ឋប្បវេណី ឬក៏នៅពេលដែលអង្គបុរេជំនុំជម្រះប្រកាសសម្រេចនេះ គឺពួកគាត់ផ្អែកទៅលើសេចក្ដីប្រកាសបឋម ការដាក់នូវពាក្យបណ្ដឹង ឬក៏ការសួរចម្លើយ ឬក៏ស្ដាប់ចម្លើយ។ ប៉ុន្តែទោះជាយ៉ាង

ណាក៏ដោយ សេចក្តីសម្រេចរបស់ចៅក្រមស៊ើបអង្កេត គឺថាមានបញ្ជាក់ទៅដោយឯកសារមួយ ឯកសារច្បាស់លាស់ដែលមានសំអាងហេតុត្រឹមត្រូវ។

[០៩:៥៦:០៧]

ហេតុដូច្នេះភាពពាក់ព័ន្ធ ភាពអាចជឿជាក់បានយថាភាពនៃឯកសារទាំងអស់នេះ នៃការសេចក្តីប្រកាសរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺអាចសន្និដ្ឋានថា មានភាពគ្រប់គ្រាន់ដោយចៅក្រមស៊ើបអង្កេត ប្រសិនបើមិនមានការយល់ឃើញនូវលក្ខណៈទាំងអស់នេះទេ ចៅក្រមស៊ើបអង្កេតគឺមិនអាចប្រកាសទទួលស្គាល់នូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានឡើយ។ ផ្ទុយទៅវិញ ចៅក្រមស៊ើបអង្កេតបានប្រកាសទទួលស្គាល់ គឺដើមបណ្តឹងរដ្ឋប្បវេណីជាង៣.០០០នាក់ ត្រូវបានប្រកាសទទួលស្គាល់។ ដូច្នេះ ចៅក្រមស៊ើបអង្កេតបានប្រកាសថា សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី គឺអាចទទួលយកបាន ហើយមានលក្ខណៈសមហេតុផលត្រឹមត្រូវគ្រប់គ្រាន់។

[០៩:៥៧:០០]

ការទទួលយកដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺយើងដឹងអស់ហើយ គឺថាវាស្ថិតនៅលើយុត្តាធិការស្ថិតនៅលើអំណាចនៃស៊ើបអង្កេត ហើយមិនអាចជំទាស់តវ៉ាបានទេលើកលែងតែយើងដកចេញនូវអំណាចសម្រេច ហើយនិងអំណាចយុត្តាធិការរបស់ចៅក្រមស៊ើបអង្កេត។

ដូច្នេះនៅថ្ងៃនេះ បញ្ហានៃការភាពទទួលយកបានហើយនិងការជំទាស់របស់ខាងមេធាវីការពារក្តី យើងត្រូវធ្វើការវិភាគដោយយោងទៅលើសេចក្តីសម្រេច ដែលបានចេញដោយសហចៅក្រមស៊ើបអង្កេត ហើយដែលមានតម្លៃជាស្ថាពរនៅថ្ងៃនេះ ហើយដែលបានសម្រេចទៅលើភាពពាក់ព័ន្ធ ភាពគួរឲ្យជឿជាក់បាន ហើយនិងយថាភាពនៃឯកសារទាំងអស់នោះ។

[០៩:៥៧:៥២]

ការអង្កេតទីពីររបស់ខ្ញុំ គឺពាក់ព័ន្ធទៅនឹងចំណុចថា យើងមិនអាចលើកនូវការជំទាស់ ហើយអង្គជំនុំជម្រះមិនអាចវាយតម្លៃទៅលើការជំទាស់នេះ ដោយមិនគិតទៅលើសេចក្តីសម្រេចដែលបានចេញដោយអង្គជំនុំជម្រះខ្លួនឯងផ្ទាល់នោះទេ។ គឺទាំងនៅក្នុងដំណាក់កាលស៊ើបសួរ ទាំងនៅក្នុងក្របខ័ណ្ឌនៃសំណុំរឿង០០១ ហើយឬក៏នៅក្នុងក្របខ័ណ្ឌនៃសំណុំរឿង០០២នេះ។

ដូច្នេះ ខ្ញុំសូមបញ្ជាក់ថា សេចក្តីជំទាស់ជាច្រើនរបស់មេធាវីការពារក្តី ត្រូវបានសម្រេចរួចមកហើយ ។នៅទីនេះយើងមិនត្រូវលើកឡើងនូវសេចក្តីជំទាស់នេះទេ វាជាការលើកឡើងដើម្បីធ្វើឲ្យខាត

ពេលវេលា។ ខ្ញុំនឹងលើកឡើងនូវសេចក្តីសម្រេចមួយចំនួន ហើយសេចក្តីសម្រេចនេះ គឺមិនមែន-- បញ្ជីនៃសេចក្តីសម្រេចនេះមិនពេញលេញទេ។ ពីព្រោះខ្ញុំគិតថា ការពិភាក្សាអាចនឹងនាំឲ្យយើងពិភាក្សាទៅលើខ្លឹមសារនៃសេចក្តីសម្រេចទាំងអស់នោះទៀត។ ប៉ុន្តែ ខ្ញុំសូមឲ្យយើងអស់គ្នាពិនិត្យមើលឧទាហរណ៍នូវសេចក្តីសម្រេច E43/4 របស់អង្គជំនុំជម្រះនៅថ្ងៃទី២៦ ឧសភា ឆ្នាំ២០០៩ នៅក្នុងសំណុំរឿង០០១ ហើយសេចក្តីសម្រេចបានប្រកាសទៅលើរបៀបវិភាគឯកសារ ដែលទទួលបានដោយតតិយភាគី។

ហើយនៅពេលនោះ គឺអង្គជំនុំជម្រះបែងចែកយ៉ាងច្បាស់អំពីឯកសារដែលពាក់ព័ន្ធទៅនឹងបរិបទប្រវត្តិសាស្ត្រ ឬក៏ឯកសារពាក់ព័ន្ធទៅនឹងអាកប្បកិរិយារបស់ជនជាប់ចោទ។ ហើយនៅក្នុងសេចក្តីដដែលនោះ អង្គជំនុំជម្រះបានវាយតម្លៃទៅលើកិច្ចនីតិវិធីដែលធ្វើឡើងដោយចៅក្រមស៊ើបអង្កេត ហើយនិងឯកសារដែលកើតចេញពីកិច្ចនីតិវិធី គឺឯកសារនោះ គឺថាមិនមានមោឃភាពអ្វីទាំងអស់នៅពេលដែលចេញដីកាដំណោះស្រាយ។

[១០:០០:០០]

ហើយនៅក្នុងដីការដំណោះស្រាយនៅក្នុងសំណុំរឿង០០២ ដែលជាសេចក្តីសម្រេចមួយរបស់តុលាការ ចៅក្រមស៊ើបអង្កេតនៅក្នុងកថាខណ្ឌ១៣២០ ដល់១៣២៤ គឺបានបញ្ជាក់អំពីការសំអាងហេតុនៅក្នុងដីកាដំណោះស្រាយនោះ ដោយផ្អែកទៅលើឯកសារដែលមានតម្លៃជាភស្តុតាងច្បាស់លាស់ ដែលអាចទទួលយកបាន ហើយនៅក្នុងសេចក្តីលេខ E1976 នៅខែកញ្ញា ឆ្នាំ២០០៩ នៅក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះបានរំឮកថា ភាគីដែលមានឱកាសក្នុងការជំទាស់ទៅនឹងភាពទទួលយកបាននៅក្នុងដំណាក់កាលស៊ើបអង្កេត គឺថាគាត់អាចប្រើប្រាស់នៅសិទ្ធិនេះបាន ហើយគាត់មិនអាចតវ៉ាបានទេនៅពេលដែលឯកសារទាំងអស់នោះត្រូវបានចាត់ទុកថា អស់ពេលដែលសម្រាប់តវ៉ាហើយ។ ហើយនៅក្នុងសេចក្តីសម្រេចនៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១០ អង្គជំនុំជម្រះបានលើកឡើងអំពីភាពជឿជាក់ដោយគ្មានវិមតិសង្ស័យ ដើម្បីបញ្ជាក់អំពីភាពស្រដៀងគ្នានៃសញ្ញាណទាំងអស់នេះ។ ហើយនៅក្នុងសេចក្តីសម្រេចដដែលនេះគឺក្នុងកថាខណ្ឌ៥២ ដល់កថាខណ្ឌ៥៣ អង្គជំនុំជម្រះបានសង្កត់ធ្ងន់ទៅលើតម្លៃនៃដើមបណ្តឹងរដ្ឋប្បវេណីដែលគាត់ធ្វើសក្ខីកម្មមិនមែនជាសាក្សីទេ គឺក្នុងនាមជាភាគីនៃរឿងក្តី ដូចជាជនជាប់ចោទដែរ។

[១០:០១:៣៨]

ដូច្នេះសេចក្តីសម្រេចទាំងអស់នេះ គឺជាយុត្តិសាស្ត្ររបស់ អ.វ.ត.ក ហើយយើងមិនអាចធ្វើ

មិនដឹងមិនឮចំពោះយុត្តិសាស្ត្រទាំងអស់នេះទេ គឺយើងត្រូវតែគិតទៅលើសេចក្តីសម្រេចទាំងអស់នេះ។ ដូច្នេះ សេចក្តីជំទាស់ក៏គិតទៅលើសេចក្តីពីមុនៗទាំងអស់នេះដែរ។ ដូច្នេះ សេចក្តីសម្រេចទាំងអស់នេះ គឺខ្ញុំមិនអាចលើកឲ្យបានគ្រប់ទាំងអស់នោះទេ ប៉ុន្តែខ្ញុំគ្រាន់តែចង់បញ្ជាក់ជូនថា យើងមានសេចក្តីសម្រេចមួយចំនួនរួចទៅហើយដែលពាក់ព័ន្ធទៅនឹងការជំទាស់ទាំងអស់នេះ។ ខ្ញុំចង់ធ្វើការកត់សម្គាល់ជាទូទៅផងដែរទៅលើសំអាងហេតុ ដែលនាំឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដាក់នូវពាក្យបណ្តឹងទាំងអស់ ហើយនិងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមិននិយាយលម្អិតឲ្យបានច្បាស់អ្វីនោះទេ ហើយគឺមិននិយាយអំពីមូលហេតុដែលនាំឲ្យយើងធ្វើយ៉ាងដូច្នេះទេ។ គឺខ្ញុំគ្រាន់តែចង់បង្ហាញថា ធាតុផ្សំទាំងអស់នេះ គឺជាមូលដ្ឋាននៃភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី។ ហើយគឺថាមិនអាចជជែកតវ៉ាបានទៀតទេ យើងមិនអាចសើរើឡើងវិញនូវភាពអាចទទួលយកបានទាំងអស់នេះទេ គឺធាតុផ្សំទាំងអស់នេះគឺមានលក្ខណៈសំខាន់ណាស់ ហើយវាមានលក្ខណៈសំខាន់ ជាលក្ខណៈតាមអង្គហេតុ គឺតាមរយៈសេចក្តីលម្អិតដែលបានផ្តល់ជូន និងតាមរយៈបរិមាណនៃសេចក្តីប្រកាស ដែលមានលក្ខណៈដូចគ្នាដែលថាយោងឲ្យឃើញថា តាមរយៈសេចក្តីសម្រេចនេះ យើងមានការឈឺចាប់ មានការអង្គហេតុគឺកើតឡើងដូចគ្នា។

[១០:០៣:១៨]

ដូច្នេះ ឯកសារទាំងអស់នេះ ត្រូវតែរក្សាទុកនៅក្នុងសំណុំរឿង គឺវាមានតម្លៃជាយថាភាព ហើយមានភាពពាក់ព័ន្ធយ៉ាងច្បាស់លាស់ទៅនឹងសំណុំរឿង ដែលបញ្ជាក់អំពីវត្តមាននៃឯកសារទាំងអស់នេះ ហើយដើម្បីលាតត្រដាងនូវពិរុទ្ធភាពរបស់ជនជាប់ចោទ។ ទាំងអស់នេះ គឺជាសេចក្តីសម្គាល់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលចង់ធ្វើឡើងនៅដើមសវនាការនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណ លោកស្រីមេធាវី។ ជាបន្តអង្គជម្រះសូមប្រគល់វេទិកាទៅមេធាវីការពារក្តី នួន ជា មេធាវីមានពេល៣០នាទី សម្រាប់លើកបញ្ហាភស្តុតាងទូទៅ ដែលមាននៅក្នុងឯកសារនានាពាក់ព័ន្ធទៅនឹងសវនាការ។ សូមអញ្ជើញ!

[១០:០៤:០១]

**លោក អេនគ្រូ អ៊ីន្ទូហ្សី៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីទាំងអស់។ ទាក់ទងនឹងបញ្ហា

ទូទៅការកត់សម្គាល់ជាទូទៅនោះគឺថា ខ្ញុំសូមលើកឡើងជាសង្ខេបទេ។ ទីមួយ ទាក់ទងទៅនឹងច្បាប់ដែលយកមកអនុវត្តបាន គឺខ្ញុំចាប់តាំងអំពីដើមដំបូងនៃការកកើត អ.វ.ត.ក ហើយនិងទាក់ទងទៅនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ពាក់ព័ន្ធទៅនឹងការទទួលយកឯកសារនេះ ដែលយើងខ្ញុំបានលើកឡើងជាញឹកញាប់អង្គជំនុំជម្រះមានលទ្ធភាពយ៉ាងធំធេង ក្នុងការពិនិត្យទៅលើឯកសារទាំងអស់នេះ។

ទាក់ទងទៅនឹងសារណាជាក់លាក់មួយចំនួនរបស់ភាគី ក៏ដូចជាឯកសារយោង ក៏ដូចជាយុត្តិ-សាស្ត្រមួយចំនួនគឺថា ឥឡូវហ្នឹងអង្គជំនុំជម្រះស្ថិតនៅក្នុងជំហរមួយ ទាក់ទងទៅនឹងគោលនយោបាយក្នុងការទទួលយកឯកសារយកមកធ្វើការវាយតម្លៃ ដោយអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាក៏ដូចជាការអនុវត្តនៅតុលាការអន្តរជាតិនានា។ ជាពិសេសដើម្បីការពារទៅដល់សិទ្ធិរបស់លោក នួន ជា ក៏ដូចជាជនជាប់ចោទដទៃទៀត។ មិនមានតម្រូវអីដែលថា ត្រូវតែអនុវត្តតាមយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិទាំងអស់នោះទេ។ ដោយផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក នេះត្រូវតែសម្រេចពិចារណាដោយខ្លួនឯង ហើយដោយសារថា អ.វ.ត.ក នេះគឺថាត្រូវដាក់ចេញនូវគោលនយោបាយមួយស្ដីអំពីការទទួលយកឯកសារ ជាពិសេសទាក់ទងទៅនឹងមាត្រា 334 នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ទាក់ទងទៅនឹងការដាក់បង្ហាញឯកសារភស្តុតាងនៅក្នុងសវនាការ។

[១០:០៦:០២]

និយាយឲ្យងាយស្រួលស្ដាប់ទៅ នៅពេលចុងបញ្ចប់នៃសវនាការ ជនជាប់ចោទអាចនឹងដាក់ឯកសារភស្តុតាងទាំងអស់ដែលគាត់យល់ឃើញថា ជាការបង្ហាញនូវការពិតបាននោះ។ ទាក់ទងទៅនឹងការទទួលយកឯកសារនេះ អង្គជំនុំជម្រះបានបញ្ជាក់ច្បាស់ហើយថា តើអង្គជំនុំជម្រះនឹងត្រូវធ្វើទៅតាមគេហៅថាវិធានមួយដែលមានលក្ខណៈពីររបៀបរបស់តុលាការអន្តរជាតិទាក់ទងទៅនឹងលទ្ធភាពនៃការវាយតម្លៃទៅលើភស្តុតាង ក៏ដូចជាការវាយតម្លៃឲ្យបានទូលំទូលាយនៃទម្ងន់នៃភស្តុតាងដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះ។

[១០:០៦:៤១]

នេះគឺជាជំហរមួយច្បាស់លាស់របស់អង្គជំនុំជម្រះ។ យើងខ្ញុំយល់ព្រមទទួលយកនូវជំហរនេះ ក៏ប៉ុន្តែបើយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា គឺយើងខ្ញុំមិនជំទាស់ទៅលើបញ្ហានេះទេ។ ជាវិធីទូទៅគឺថា ការវាយតម្លៃត្រូវតែធ្វើឡើងដោយមានលក្ខណៈបត់បែន ដោយមានលក្ខណៈគួរឲ្យជឿជាក់បាន។

ហើយចំណុចទីបី គឺខ្ញុំយោងទៅលើឯកសារដើម អនុវត្តទៅតាមការអនុវត្តនៅកម្ពុជា។ អនុវត្ត

នៅតាមអន្តរជាតិនឹងត្រូវអាចយកមកដាក់ទីនេះបាន ត្រូវតែស៊ីសង្វាក់គ្នាទៅនឹងការ អនុវត្តជាបទដ្ឋានទូទៅនៅក្នុងប្រទេសកម្ពុជាផងដែរ។

ហើយកាលពីសប្តាហ៍មុន គឺយើងបានលើកឡើងដោយសារតែលោកមេធាវី សុន អរុណ បានលើកឡើងថា គាត់មានបទពិសោធន៍ជិត២០ឆ្នាំ គឺថាភស្តុតាងមួយចំនួនគឺថា មិនត្រូវអង្គជំនុំជម្រះទទួលយកបានទេ ប្រសិនណាមិនអាចបង្ហាញពីយថាភាព ឬក៏ប្រភពដើមនៃឯកសារនេះបានទេ។

[១០:០៧:៣៨]

ខ្ញុំជឿថា អស់លោក លោកស្រីចៅក្រមអាសនៈ ទាំងអស់សមាជិកនៃអង្គជំនុំជម្រះ ក្រុមប្រឹក្សាជំនុំជម្រះនឹងយល់ឃើញ នឹងសម្រេចទៅលើ មុននឹងសម្រេចយកយុត្តិសាស្ត្រអន្តរជាតិយកមកអនុវត្តដើម្បីបង្ហាញទៅដល់ប្រភពដើមនៃឯកសារទាំងអស់នេះ។

សហព្រះរាជអាជ្ញាបានលើឡើងថា គេមិនអាចលើកពីប្រភពដើមនៃឯកសារទាំងអស់នេះជាងរាប់សិបពាន់សន្លឹកនេះបានទេ។ ប៉ុន្តែយ៉ាងហោចណាស់ក៏ត្រូវបង្ហាញប្រភពដើមនៃឯកសារនេះ ឯកសារដើមនេះគឺថាខ្លះៗក្នុងចំណោមឯកសារដែលបានដាក់ជូននេះដែរ ដែលសហព្រះរាជអាជ្ញាបានដាក់ជូននោះ។ ហើយឯកសារទាក់ទងទៅនឹងអំពើរបស់ជនជាប់ចោទ ជាពិសេសទាក់ទងទៅនឹងឯកសារមួយដែលបានបង្ហាញជូនលោក នួន ជា នៅក្នុងតុលាការនេះ គឺថាឯកសារនេះត្រូវតែបង្ហាញជាឯកសារដើម ហើយកាលពីសប្តាហ៍ៗមុនគឺថា យើងខ្ញុំយល់ឃើញថាការជំទាស់មិនលើសពី ១០ឯកសារទេ។

[១០:០៨:៥០]

យើងមានការសួរសក្ខីកម្មពីលោក នួន ជា យើងមានការថតជាសំឡេង មានកំណត់ហេតុមួយចំនួន គឺថា បើឯកសារមួយចំនួនមិនអាចបង្ហាញជាឯកសារដើមបានទេ ហើយសហព្រះរាជអាជ្ញាអន្តរជាតិទទួលស្គាល់ អំពីការបង្ហាញនូវឯកសារដើមនីមួយៗ គឺថាមិនអាចធ្វើបាននោះ គឺថាចំណុចនេះគឺមិនអាចយកមកអនុវត្តបានទេ ពីព្រោះវាប៉ះពាល់ទៅដល់សិទ្ធិក្នុងការជំទាស់ទៅលើឯកសារទាំងអស់នេះពីសំណាក់ជនជាប់ចោទ។

យើងគិតអំពីភាពយុត្តិធម៌ ក៏ដូចជាតុល្យភាពនៃការថ្លឹងថ្លែងទៅលើឯកសារទាំងអស់នេះ។ វាគឺជាបញ្ហាមួយ វាពាក់ព័ន្ធទៅនឹងអំពើរបស់ជនជាប់ចោទ។ ថាតើ-- បើឯកសារទាំងអស់នេះយកមកបង្ហាញអំពីសកម្មភាពរបស់ជនជាប់ចោទ នោះឯកសារដើមត្រូវតែបានយកមកបង្ហាញ។

[១០:០៩:៤៨]

លោក សុន អរុណ បានកេះខ្ញុំហើយថាឲ្យខ្ញុំនិយាយយឺតៗបន្តិច ខ្ញុំនឹងនិយាយយឺតៗបន្តិច។

នេះអ្វី យើងនិយាយអំពីភស្តុតាងពាក់ព័ន្ធទៅនឹងអំពើរបស់ជនជាប់ចោទ ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើង គឺថាយើងយល់ស្រប គឺថាបើឯកសារវាពាក់ព័ន្ធទៅនឹងជនជាប់ចោទ នោះជនជាប់ចោទអាចមានសិទ្ធិជំទាស់តវ៉ាទៅនឹងសេចក្តីថ្លែង ឬឯកសារណាមួយ។ អ៊ីចឹង យើងខ្ញុំយល់ស្របចំពោះការលើកឡើងរបស់សហការីហ្នឹង។

ហើយចំណុចមួយទៀង យើងចង់មកនិយាយនេះ គឺនិយាយអំពីបទដ្ឋានអាទាបបំផុត ឬក៏ថាបទដ្ឋានអប្បបរមាក្នុងការសម្រេចទទួលយកឯកសារមកធ្វើជាភស្តុតាង ទាក់ទងទៅនឹងអំពើរបស់ជនជាប់ចោទនេះ។ ប៉ុន្តែយើងខ្ញុំសូមលើកឡើង ហើយនិងជឿជាក់ថា បទដ្ឋានដែលសហព្រះរាជអាជ្ញាលើកឡើង គឺថាពាក់ព័ន្ធទៅនឹងអំពើជនជាប់ចោទត្រូវអនុវត្តទៅគ្រប់ឯកសារទាំងអស់នៅក្នុងសំណុំរឿង។

ឧទាហរណ៍ ចម្លើយដែលខាងសហព្រះរាជអាជ្ញាបានទទួល ឬក៏ដែលបានចម្លើយដែលសហចៅក្រមស៊ើបអង្កេតបានទទួលត្រូវដាក់ជូនមកជា ដាក់ជូននៅតុលាការ ហើយត្រូវតែប្រឈមមុខទៅនឹងការសួរដេញដោលចំពោះយថាភាពនៃឯកសារនេះ។

[១០:១១:១៥]

ចំណុចទីប្រាំរបស់ខ្ញុំ គឺថាឯកសារមួយចំនួន គឺថាត្រូវបានមានការជំទាស់ដោយតុលាការអន្តរ-ជាតិ ដោយសារឯកសារទាំងនេះមិនអាចទទួលយកបាន គួរឲ្យជឿជាក់បាន។ យើងខ្ញុំយល់ស្របទៅលើការអនុវត្តរបស់តុលាការអន្តរជាតិ និងគួរយកចំណុចនេះយកមកអនុវត្តនៅក្នុងការសម្រេចសេចក្តី និងត្រូវការបង្ហាញ ស្វែងរកឲ្យឃើញនូវការពិតនោះ។ ហើយអង្គជំនុំជម្រះត្រូវកាតព្វកិច្ចមួយ គឺថាត្រូវមានកាតព្វកិច្ចស្វែងយល់ពាក់ព័ន្ធទៅនឹងឯកសារទាំងអស់នេះ ដើម្បីបំពេញនូវតួនាទីរបស់ខ្លួន។

ហើយសហព្រះរាជអាជ្ញាក៏បានលើកឡើងថា ភស្តុតាងមួយក្រឡេកភ្នែក ឬក៏ភស្តុតាងបឋមនេះ គឺថាយើងខ្ញុំយល់ឃើញថា ចៅក្រមគឺថាមិនអាច ឬមិនអាចយកចំណុចនេះមកនេះទេ គឺត្រូវយកគ្រប់ធាតុទាំងអស់យកមកពិចារណា។

បន្ទុកមិនមែនជាមេធាវីការពារក្តីជាអ្នកបង្ហាញទេ។ បន្ទុកនៃការបង្ហាញភស្តុតាងនេះ គឺជាបន្ទុករបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងភស្តុតាងឯកសារមួយចំនួន នោះគឺដោយសារតែអង្គជំនុំជម្រះ គឺអាជ្ញាកណ្តាលមួយ ដែលត្រូវសម្រេចពិចារណាទៅលើចំណុចទាំងអស់នេះ។ នេះគឺមានចែង មាននិយាយនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល។

[១០:១២:៤០]

យើងខ្ញុំទទួលស្គាល់អំពីវិធីសាស្ត្រប្រកបទៅដោយហេតុមួយ ទាក់ទងទៅនឹងភាពអាចទទួលយកបាននៃឯកសារទាំងនេះ។ យើងខ្ញុំបានសរសេរនូវឯកសារទាំងអស់នេះ។ យើងខ្ញុំគិតឃើញថា វាជាគំនិតផ្តួចផ្តើមមួយគួរសមហេតុសមផលណាស់ ក៏ប៉ុន្តែនៅពេលដែលជនជាប់ចោទ ជាពិសេសនៅក្នុងតុលាការនៅក្នុងសវនាការតែម្តងនេះ ប្រសិនណាជាជនជាប់ចោទជំទាស់ទៅនឹងយថាភាពនៃឯកសារណាមួយនោះ យើងខ្ញុំសូមយល់ឃើញថា គឺនោះសហព្រះរាជអាជ្ញា ដែលមានបន្ទុកត្រូវបង្ហាញអំពីប្រភពនៃឯកសារនេះ ជាភាសាទាក់ទងទៅនឹងការទាមទារឲ្យបង្ហាញនូវឯកសារដើម។

[១០:១៣:២៥]

ឯកសារដែលមានយថាភាព ឬក៏មិនមានយថា-- បើមិនមានយថាភាព គឺថាត្រូវតែច្រានចោល។ បើសិនជារកឃើញថា ឯកសារនោះ ជាឯកសារមួយយកមកធ្វើការដាក់បន្ទុកទៅលើជនជាប់ចោទ ប៉ុន្តែមិនបានបង្ហាញប្រភពដើមនោះទេ។ ហើយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏និយាយផងដែរថា គឺថានៅពេលដែលការស៊ើបអង្កេតត្រូវបានបញ្ចប់ហើយនោះ គឺថាគេមិនអាចជំទាស់ទៅនឹងឯកសារទាំងអស់នេះបានទេ។ មិនមានចំណុចណាមួយដែលត្រូវហាមឃាត់មិនឲ្យជំទាស់តវ៉ាទៅលើឯកសារណាមួយទេ លុះណាតែសវនាការត្រូវបានចប់ជាស្ថាពរ។

[១០:១៤:២៩]

ខ្ញុំ យើងខ្ញុំសូមជំទាស់ចំពោះជំហរ ដែលខាងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងនេះ ជាពិតគឺថា យថាភាពគឺជាចំណុចមួយដែលត្រូវតែជំទាស់តវ៉ាគ្មានរហូតដល់ដំណាក់កាលចុងក្រោយនៃសវនាការដែលត្រូវបញ្ចប់ជាស្ថាពរ។ ហើយគឺភាគីទាំងអស់ គ្មានសិទ្ធិជំទាស់តវ៉ាទៅលើឯកសារទាំងអស់រហូតទៅដល់នាទីចុងក្រោយ ការបិទសវនាការជាស្ថាពរតែម្តង។

[១០:១៤:៥១]

អ៊ីចឹង ការជំទាស់តវ៉ាទៅលើឯកសារនៅក្នុងនេះ គឺដែលតម្រូវឲ្យមានការបង្ហាញភស្តុតាងជាបឋមនោះ គឺថាខ្ញុំ យើងខ្ញុំសូមជំទាស់ថាឯកសារដែលបានទទួលទាំងអស់នេះ បើសិនណាជាមិនអាចបង្ហាញនូវភស្តុតាងបានទេ គឺត្រូវតែច្រានចោល។

បញ្ហាទាក់ទងទៅនឹងយថាភាពគឺជាបញ្ហាបើកចំហទូទៅមួយ ដោយអនុញ្ញាតឲ្យមានការសួរដេញដោលគ្មានរហូតទៅដល់ដំណាក់កាលចុងក្រោយ។ ហើយទាក់ទងទៅនឹងការរក្សាទុកឯកសារទាំងនេះគឺ

ថា យើងខ្ញុំស្វាគមន៍ចំពោះគំនិតផ្តួចផ្តើមក្នុងការហៅនូវតំណាងមកពីមជ្ឈមណ្ឌលស្រាវជ្រាវឯកសារកម្ពុជាមកបង្ហាញ ជាពិសេសឯកសារដែលមកពីមជ្ឈមណ្ឌលស្រាវជ្រាវឯកសារកម្ពុជា (ឌី.ស៊ី.ខេម) នេះ គឺខ្ញុំនឹងមិននិយាយអ្វីវែងឆ្ងាយទេ ក៏ប៉ុន្តែយើងគ្រាន់តែថា ខ្ញុំទុកចិត្តទៅលើស្ថាប័ននេះ ដែលជាស្ថាប័នមួយដែលថា ត្រូវតែបង្ហាញនូវការរក្សាឯកសារដើមទទួលបានមកពីខាងណានោះ។

[១០:១៦:០០]

ចំណុចទីប្រាំបួនរបស់យើងខ្ញុំនោះ គឺទាក់ទងទៅនឹងភាពគួរឲ្យជឿជាក់បាននៃឯកសារនេះ និងឯកសារនៅក្នុងនេះ។ យើងខ្ញុំបានលើកឡើងចំណុចនេះហើយ អ៊ីចឹងខ្ញុំមិននិយាយច្រើនទេទៅលើចំណុចនេះ។ យើងបានលើកចំណុចនេះចាប់តាំងពីដើមដំបូងនៃរឿងក្តីនេះមកម្ល៉េះ។ យើងនិយាយថា មាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជានិយាយអំពីគឺថា ឯកសារទាំងអស់អាចនឹងពិភាក្សាដេញដោលគ្នាបាន រហូតដល់ចុងបញ្ចប់នៃសវនាការ គឺថាខ្ញុំមិនអាចហាមឃាត់មិនឲ្យមានការជំទាស់បាននោះទេ។

ហើយឯកសារទាំងអស់នោះ ដែលយើងខ្ញុំចង់លើកឡើង យើងនឹងធ្វើការបង្ហាញ ធ្វើការជំទាស់តវ៉ា យើងនឹងបង្ហាញជូននូវឯកសារទាំងអស់ពីខាងក្រុមយើងខ្ញុំជូនអង្គជំនុំជម្រះនៅចុងបញ្ចប់នៃសប្តាហ៍នេះ។ ឯកសារនោះមាន TCE-38 គឺយើងខ្ញុំដាក់ជូននូវឯកសារទាំងអស់នេះនៅក្នុងពេលណាមួយនៃចុងសប្តាហ៍នេះ។

[១០:១៧:០៤]

ទាក់ទងទៅនឹងការទទួលយកឯកសារថ្មី យើងខ្ញុំយល់ឃើញថា ច្បាប់ ចៅក្រមនៅក្នុង-- ប្រើប្រាស់ប្រព័ន្ធច្បាប់ស៊ីវិលឡ គឺថាតួនាទីចម្បងរបស់អង្គជំនុំជម្រះនេះគឺត្រូវតែសម្របសម្រួលនូវរវាងភាគីទាំងអស់ ហើយជាពិសេសគឺថាត្រូវតែស្វែងរកឲ្យឃើញនូវការពិត។ មានន័យថា ជាពិសេសទាក់ទងឯកសារទាំងឡាយណាដែលចៅក្រមមិនទាន់បានពិនិត្យនៅឡើយនោះ។ យើងខ្ញុំបានប្រកាន់យកជំហរនេះ ហើយយើងក៏បានដាក់សំណើមួយរួចហើយ យើងខ្ញុំថា អង្គជំនុំជម្រះត្រូវតែដាក់ចេញនូវវិធីមួយដែលយកមកអនុវត្តស្របទៅតាមច្បាប់កម្ពុជា។ ប៉ុន្តែ អង្គជំនុំជម្រះដឹងច្បាស់ប្រាកដណាស់ថា ដឹងច្បាស់ហើយថា អង្គជំនុំជម្រះមាន ត្រូវតែអនុវត្តទៅតាមច្បាប់កម្ពុជានោះ ដែលអង្គជំនុំជម្រះមិនអាចច្រានចោលនូវសិទ្ធិជាមូលដ្ឋានដែលមានចែងនៅក្នុងច្បាប់កម្ពុជានេះបានទេ។

[១០:១៨:០៧]

ហើយចំណុចទីដប់ និងជាចំណុចចុងក្រោយ គឺការដែលលោក នួន ជា ស្នើសុំរក្សាសិទ្ធិមិនឆ្លើយ

តបកាលពីសប្ដាហ៍មុននោះ គឺអង្គជំនុំជម្រះបានលើកឡើងថា នៅពេលដែល នួន ជា ស្នើសុំឲ្យបង្ហាញនូវឯកសារដើម ហើយគាត់រក្សាសិទ្ធិមិនឆ្លើយតបទៅនឹងឯកសារដែលគាត់បានច្រានចោល នេះដោយសារតែថា ការជំទាស់ទៅលើយថាភាពនៃឯកសារវាជារឿងមួយដែលសំខាន់ណាស់ ជាសិទ្ធិមួយសំខាន់របស់គាត់ ដែលគាត់ត្រូវប្រឈមមុខទៅនឹងឯកសារថតចម្លង ដែលបើសិនណាជាឯកសារនោះមិនមែនជាឯកសារនេះទេ។ ប៉ុន្តែលោក ផេសមែន គាត់ថា អ្វីដែលកូនក្ដីខ្ញុំធ្វើនេះមិនអនុវត្តសិទ្ធិ មិនឆ្លើយតបគឺដោយសារតែគាត់ជំទាស់តវ៉ាទៅនឹងយថាភាពនៃឯកសារនេះឯង។

[១០:១៨:៥៨]

ដូចយើងខ្ញុំបានកត់សម្គាល់ហើយ លោក នួន ជា ខ្លួនឯងផ្ទាល់ គាត់មានឆន្ទៈចង់បង្ហាញភស្ដុតាងទៅលើឯកសារ បង្ហាញនូវឯកសារណាមួយ ហើយគាត់ចង់ឲ្យបង្ហាញនូវឯកសារដើម ដោយមិនចង់ឲ្យបង្ហាញតែឯកសារថតចម្លងតែប៉ុណ្ណោះនោះទេ។ ប៉ុន្តែអង្គជំនុំជម្រះមិនទាន់បានសម្រេចទៅលើសំណើរបស់គាត់នេះនៅឡើយទេ។ យើងខ្ញុំយល់ឃើញថា អង្គជំនុំជម្រះនឹងសម្រេចទៅលើសំណើរបស់លោក នួន ជា នៅក្នុងពេលឆាប់ៗនេះ ដើម្បីជាពិសេសទាក់ទងទៅនឹងឯកសារដែលបានបង្ហាញជូនមកឲ្យគាត់នេះ វាជាឯកសារមួយដែលមិនគួរឲ្យជឿជាក់បាន ដោយសារតែសំណុំរឿងនេះវាជាសំណុំរឿងមួយធំស្មុគស្មាញ។

[១០:១៩:៤២]

ដូច្នេះខ្ញុំយល់ឃើញថា អង្គជំនុំជម្រះគួរតែចេញសេចក្ដីសម្រេចមួយក្នុងពេលឆាប់ៗ ទាក់ទងទៅនឹងសំណើរបស់ជនជាប់ចោទនេះ ដោយមិនមានធ្វើការព្រមានអ្វីមកដល់យើងខ្ញុំនោះទេ។ យើងខ្ញុំយល់ថា នេះគឺជាការអនុវត្តមួយសមហេតុសមផលណាស់ ដែលត្រូវតែអនុវត្តយកមកវិធីសាស្ត្រមួយប្រកបឲ្យបានសមរម្យ។ ហើយជាចុងក្រោយខ្ញុំមិនមានចេតនាជំទាស់សិទ្ធិរបស់ភាគីណាមួយនោះទេ យើងខ្ញុំគ្រាន់តែការពារសិទ្ធិរបស់លោក នួន ជា ជាកូនក្ដីរបស់យើងខ្ញុំតែប៉ុណ្ណោះ។

ហើយចំណុចចុងក្រោយបំផុតនោះ សហព្រះរាជអាជ្ញា។ ជាការពិតណាស់សហព្រះរាជអាជ្ញាគឺបានគាត់និយាយអំពីៗសច្ចធារណ៍នៃនិរទោសនេះ គឺថាចំណុចយើងខ្ញុំគឺចុងក្រោយនេះហើយ អស់ប៉ុណ្ណោះហើយ។ សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។

**ប្រធានអង្គជំនុំ៖**

អរគុណសហមេធាវីការពារក្ដី នួន ជា។ ឥឡូវនេះដល់ពេលវេលាសមល្មមនឹងសម្រាកហើយ

អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីចាប់ពីពេលនេះទៅ រហូតដល់ម៉ោងដប់មួយខ្វះម្ភៃនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សូមអញ្ជើញលោក អាង ឧត្តម!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន ខ្ញុំបាទសូមលោកប្រធានមេត្តាអនុញ្ញាតឱ្យលោក អៀង សារី ចូលរួមសវនាការពីបន្ទប់ខាងក្រោម បន្ទប់រងចាំសម្រាប់សវនាការទាំងមូល គឺសវនាការដេញដោលលើភស្តុតាងនេះ គឺចាប់ផ្តើមពីថ្ងៃនេះរហូតដល់ថ្ងៃទី១៩។ សូមលោកប្រធានមេត្តាអនុញ្ញាត។

[១០:២១:២៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំតាមរយៈមេធាវីរបស់ខ្លួន ដោយសុំលះបង់សិទ្ធិមិនចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការនៅក្នុងបន្ទប់សវនាការនេះ ដោយសារមូលហេតុសវនាការនេះ ជាសវនាការនេះជាសវនាការពិនិត្យដេញដោលលើភស្តុតាងឯកសារ ដោយបន្តទៅការតាមដានពីចម្ងាយពីបន្ទប់ឃុំខ្លួននៅខាងក្រោមបន្ទប់សវនាការនេះ ដោយមានឧបករណ៍សោតទស្សន៍។ ប៉ុន្តែ ក្រុមមេធាវីការពារក្តីត្រូវប្រគល់មកឱ្យអង្គជំនុំជម្រះនូវលិខិតលះបង់សិទ្ធិមិនចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះដោយមានចុះហត្ថលេខា ឬក៏ផ្តិតមេដៃជាក់ច្បាស់ពីជនជាប់ចោទ អៀង សារី។

ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី ទៅបន្ទប់ខាងក្រោមចុះ ហើយនិងលោកទាំងពីរនាក់ ទាំង នួន ជា និង អៀង សារី នេះឱ្យគាត់នៅទីនោះនៅក្នុងអំឡុងពេលនៃដំណើរការសវនាការសម្រាប់សប្តាហ៍នេះ។ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី មានលទ្ធភាពតាមដានកិច្ចដំណើរការសវនាការកិច្ចសវនាការពីចម្ងាយ។

សូមនោះទៅចុះ! ហើយសម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:២៣ នាទី ដល់ម៉ោង ១០:៤៣ នាទី)*

[១០:៤៣:២២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

ជាកិច្ចបន្ត អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅមេធាវីការពារក្តីជនជាប់ចោទ អៀង សារី។ មេធាវីមានរយៈ៣០នាទី ដើម្បីលើកអំពីបញ្ហាភស្តុតាងទូទៅ ដែលមាននៅក្នុងឯកសារពាក់ព័ន្ធនឹងកិច្ចដំណើរការសវនាការ។

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល កាណាវាស៖**

អរុណសួស្តីលោក លោកស្រីចៅក្រម លោកប្រធាន និងអស់លោក លោកស្រី នៅជុំវិញ និងនៅក្នុងបន្ទប់សវនាការនេះ ជាទីគោរព។

ហេតុអ្វីបានជាយើងមកក្នុងថ្ងៃនេះ ចូលរួមសវនាការថ្ងៃនេះ? ដើមបណ្តឹងរដ្ឋប្បវេណីជឿថា យើងមកនៅទីនេះ គឺដោយលើកឡើងថាមេធាវីការពារក្តីពន្យារពេលនីតិវិធី។ ក្រុមមេធាវីការពារក្តីគឺជាក្រុមរួម ហើយគេលើកឡើងថា ជាអ្នករារាំង និងជាអ្នកលើកការជំទាស់ទាំងអស់នេះ។ យើងចូលរួមនៅថ្ងៃនេះ ដោយសារតែខាងសហព្រះរាជអាជ្ញាតាមអ្វីដែលខ្ញុំចាំ។

[១០:៤៤:៤៣]

សហព្រះរាជអាជ្ញាបានស្នើសុំមុនពេលដែលយើងឈប់សម្រាកអាទិត្យមុននោះ ឲ្យយកបញ្ហានេះមកពិភាក្សា។ នេះមិនមែនជាសំណើសុំលើកទីមួយនោះទេ យើងបានធ្វើសំណើនេះរួចមកហើយជាច្រើនដងរួចមកហើយ មុនពេលដែលនីតិវិធីសវនាការចាប់ផ្តើម។ យើងបានស្នើដូច្នោះ ដោយសារតែយើងបានដឹងថា នៅពេលដែលឯកសារភស្តុតាង យកមកដាក់នៅក្នុងសវនាការនឹងមានការជំទាស់ជាមិនខាន ហើយជាធម្មតា នៅក្នុងរឿងក្តីបែបនេះ ការជំទាស់ទាំងអស់នោះ ឬក៏ការជំទាស់ភាគច្រើនគឺត្រូវតែធ្វើឡើងមុនពេលសវនាការ មិនមែនក្នុងពេលសវនាការដូចនេះទេ។ គឺមុនពេលសវនាការ គឺគេឲ្យចេញសេចក្តីសម្រេចដាក់ជាឯកសារផ្សេងៗពីភាគី លើកលែងតែមានការលេចឡើងបញ្ហាណាថ្មីមួយក្នុងពេលបង្ហាញភស្តុតាង។

ហេតុដូច្នេះហើយទើបយើងមកចូលរួមក្នុងសវនាការនៅក្នុងថ្ងៃនេះ។ ខ្ញុំសូមរំឭកខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីថា យើងបានមាន-- យើងឃើញមានចេញសេចក្តីសម្រេចដែលពាក់ព័ន្ធទៅនឹង

ការសន្មតថា ការបដិសេធចំពោះការទទួលយកឯកសាររបស់មេធាវីការពារក្ដី អៀង សារី។ ជាពិសេស យើងក៏បានលើកឡើងអំពីបញ្ហានៃភស្តុតាងសេចក្ដីប្រកាស ដែលពាក់ព័ន្ធទៅនឹងការធ្វើទារុណកម្ម។ កថាខណ្ឌ៣៤ ឯកសារលេខ 130/7/3/15 អង្គបុរេជំនុំជម្រះបានកត់សម្គាល់នៅក្នុងកថាខណ្ឌ៣៤ ថា អង្គបុរេជំនុំជម្រះសង្កេតឃើញថាវិធាន ៨៧ គឺផ្ដល់ឱកាសដល់ជនត្រូវចោទ ជំទាស់ការទទួលយកភស្តុតាងក្នុងដំណាក់កាលសវនាការ។ ដូច្នេះហើយ វាមិនមែនថាយើងព្យាយាមរារាំងបង្អាក់សវនាការនេះទេ ដោយហេតុថា បញ្ហាមួយចំនួនច្រើនមិនបានដោះស្រាយនៅក្នុងពេលនេះ។

[១០:៤៧:០០]

ខ្ញុំផ្ដល់ជាឧទាហរណ៍មួយ នៅពេលដែលខ្ញុំបង្ហាញនៅក្នុងបទបង្ហាញរបស់ខ្ញុំនៅពេលនេះ។ ខ្ញុំបាន-- ខ្ញុំលើកឧទាហរណ៍នេះ ដោយសារតែដើមបណ្ដឹងរដ្ឋប្បវេណីប្រាកដជាជឿថា អ្វីដែលសហចៅក្រមស៊ើបអង្កេតបានបំពេញកិច្ចនោះ គឺមិនមាន-- មិនអាចឲ្យយើងធ្វើការជំទាស់ ហើយយើងត្រូវតែទទួលយក។ យើងសូមផ្ដល់ទឡ្ហីករណ៍អះអាងតវ៉ាថា យើងសូមឲ្យសហចៅក្រមស៊ើបអង្កេតពិនិត្យមើលឯកសារទាំងឡាយដែលប្រមូលយកមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា គឺ ឌី.ស៊ី.ខេម។ យើងបានលើកការជំទាស់ទៅលើឯកសារ-- យើងបានធ្វើសំណើទាំងអស់នេះ ដោយសារតែសុំឲ្យសហចៅក្រមស៊ើបអង្កេតពិនិត្យពិចារណាទៅលើឯកសារទាំងអស់នោះ ហើយផ្ដល់ព័ត៌មានឲ្យយើង ថាតើ ឌី.ស៊ី.ខេម គាត់ប្រមូលឯកសារទាំងអស់នោះតាមរបៀបណា? នៅពេលរបៀបណា? ដោយនរណា? ហើយគេរក្សាឯកសារនោះ ដោយរបៀបណា? ហើយគេមានលទ្ធភាពមើលឯកសារនោះ តាមរបៀបណា? នេះជាហេតុផលដែលយើងសូមលើកឡើង។

[១០:៤៨:០៧]

ជាការពិត សំណើរបស់យើងភាគច្រើន គឺយើងបានធ្វើឡើងទៅកាន់ខាងការិយាល័យសហចៅក្រមស៊ើបអង្កេត ក៏ប៉ុន្តែយើងមិនបានទទួលចម្លើយតបទៅលើសំណើរបស់យើងនោះទេ។

ដូច្នេះ ខ្ញុំសូមឲ្យអង្គជំនុំជម្រះ ក្រុមប្រឹក្សាជំនុំជម្រះធ្វើការពិចារណាទៅលើសំណើរបស់យើងខ្ញុំដែលបានស្នើឡើងលើទម្រង់បែបបទនៅក្នុងសហចៅក្រមស៊ើបអង្កេត។ ដូច្នេះ យើងដឹងថាយើងបានស្នើសុំសហចៅក្រមស៊ើបអង្កេតឲ្យពិចារណាទៅលើឯកសារ ហើយធ្វើការពិភាក្សា និងសួរអំពីប្រភេទនៃឯកសារដែលគាត់ប្រមូលបាន។ មុនពេលដែលខ្ញុំសូមលើកឡើងអំពីភាពជឿជាក់នៃលក្ខណៈវិនិច្ឆ័យនៅលើឯកសារ។ ខ្ញុំសូមបង្ហាញថា យើងជឿជាក់អំពីមូលដ្ឋានរួមរវាងសហព្រះរាជអាជ្ញា និងរវាងយើង

ខ្ញុំ។ យើងឯកភាពទៅលើមូលដ្ឋានរួមនោះ។

ខ្ញុំសូមលើកឡើងថា មូលដ្ឋាននោះគឺមិនមានការងាកចេញពីគ្នា ខុសឆ្ងាយនោះទេទៅលើបញ្ហាភាគច្រើន។ អ្វីដែលយើងឯកភាពនោះ គឺថាសវនាការនេះមានសារៈសំខាន់ណាស់។ ភាគីត្រូវតែដឹងឲ្យប្រាកដទាំងអស់គ្នា។ នៅពេលដែលយើងពិចារណាទៅភាពប្រាកដ នៅពេលដែលយើងដឹងអំពីភាពប្រាកដប្រជានោះ គឺសវនាការរបស់យើងអាចដំណើរការដោយរលូន។

[១០:៤៩:៣៦]

វិធាននៃការទទួលយកភស្តុតាងនៅ អ.វ.ត.ក គឺមានលក្ខណៈស៊ីសង្វាក់ទៅនឹងយុត្តិសាស្ត្រអន្តរជាតិ និងវិធានដទៃៗទៀត។ យើងក៏ឯកភាពផងដែរ វិធាន៨៧(៣) ចែងថាបទដ្ឋាននៃការទទួលយកភស្តុតាងត្រូវតែមានភាពពាក់ព័ន្ធ និងភាពជឿជាក់អាចទុកចិត្តបាន។ ហើយភស្តុតាងឯកសារ គឺត្រូវតែមានការជឿជាក់ជាបឋម នៅពេលដែលយើងពិនិត្យមើលទៅលើឯកសារ។ វិធាន៨៧(៣)(គ) គឺមានចែងអំពីភស្តុតាងដ៏សុក្រិត ភស្តុតាងដ៏ល្អបំផុត។ វិធាន៨៧(៣) គឺចែងអំពីការមិនទទួលយកឯកសារមួយចំនួនផងដែរ ដែលឯកសារទាំងអស់នោះ មិនអាចឲ្យយើងទទួលយកបានអនុលោមតាមច្បាប់។ យើងក៏ឯកភាពផងដែរថា ឯកសារទាំងឡាយដែលទទួលបានក្នុងពេលធ្វើទារុណកម្ម គឺយើងមិនអាចទទួលយកបានផងដែរ យោងទៅតាមច្បាប់របស់យើង អនុលោមតាមវិធាន២១(៣) និងមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[១០:៥០:៥១]

ចំណុចចុងក្រោយ យើងឯកភាពថាការវាយតម្លៃទៅលើទម្ងន់នៃភស្តុតាង គឺជាការត្រូវស៊ើបអង្កេតដោយឡែក ខុសពីការទទួលយកបាននៃឯកសារ និងភស្តុតាង។ យើងក៏ឯកភាពផងដែរ តាមអ្វីដែលខ្ញុំស្តាប់ឮនៅក្នុងថ្ងៃនេះ គឺនៅពេលដែលយើងមានភស្តុតាងទាំងអស់នោះហើយ នៅពេលនោះ នៅដែលយើងសម្រេចថា តើភស្តុតាងណាមួយដែលពាក់ព័ន្ធ ក្រុមប្រឹក្សាជំនុំជម្រះត្រូវតែធ្វើការសម្រេចដោយផ្អែកទៅលើច្បាប់ ហើយដោយពិចារណា ថាតើគួរផ្តល់ទម្ងន់បែបណាទៅលើភស្តុតាងទាំងអស់នោះ? ហើយថាតើភស្តុតាងទាំងអស់នោះ វាមានពាក់ព័ន្ធប៉ុនណា? ហើយវាក៏អាចមានតម្លៃតិចតួចផងដែរ នៅពេលដែលយើងវាយតម្លៃទៅលើភស្តុតាង។ ហើយការសម្រេច និងវាយតម្លៃទាំងអស់នេះ ជាសមត្ថកិច្ច និងជាឆន្ទានុសិទ្ធិរបស់ក្រុមប្រឹក្សាជំនុំជម្រះ។

[១០:៥១:៤៧]

ទាំងអស់នេះហើយ គឺជាវិធាន និងគោលការណ៍ដែលយើងឯកភាពជាមួយនឹងសហព្រះរាជអាជ្ញា។ ផ្អែកតាមការឆ្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងការជំទាស់របស់យើង ទៅលើឯកសារមួយចំនួន ដែលយើងបានដាក់នៅថ្ងៃទី១៦ ខែកញ្ញា ឯកសារលេខ E114 កថាខណ្ឌ៧, ៨, ១១, ១៤ និង ១៥ គឺយើងក៏មានការឯកភាពរួមមួយចំនួនដែរ មិនខុសគ្នាច្រើននោះទេ។ ខ្ញុំដឹងថា វា-- ការលើកឡើងរបស់ខ្ញុំជាន់គ្នា ក៏ប៉ុន្តែខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់លាស់នៅក្នុងប្រតិចារឹក ឆ្លើយតបទៅនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញា និងភាគី។ យើងខ្ញុំមិនមែនថា មិនយកចិត្តទុកដាក់ដោយម៉ត់ចត់ក្នុងការការពារក្ដីលោក អៀង សារី នោះទេ។ និយាយដោយន័យទូលាយទៅ យើងត្រូវពិចារណាទៅលើបីដំណាក់កាលនៅពេលដែលយើងពិភាក្សា និងពិចារណាទៅលើភស្តុតាង។

[១០:៥២:៥៣]

ទីមួយ អង្គជំនុំជម្រះគួរតែពិចារណា ថាតើឯកសារទាំងអស់នោះមានយថាភាពដែរឬទេ? នេះជាចំណុចបឋម។ ចំណុចទីមួយ គឺយថាភាព។ ប្រសិនបើសហព្រះរាជអាជ្ញាលើកឡើងអំពីកំណត់ហេតុរបស់គណៈមជ្ឈិម គណៈអចិន្ត្រៃយ៍។ ដូច្នេះលើកលែងតែអាចបញ្ជាក់យថាភាពបាន ទើបឯកសារទាំងអស់នោះមានតម្លៃ។ ខ្ញុំនឹងលើកឡើងជាក់លាក់ និងលម្អិត ថាតើលក្ខខណ្ឌតម្រូវអ្វីខ្លះដែលអាចឲ្យយើងចាត់ទុកឯកសារថាជាយថាភាព?

យថាភាព គឺវាខុសគ្នានឹងភាពអាចទុកចិត្តបាននៃឯកសារ។ ឯកសារវាអាចមានយថភាព ក៏ប៉ុន្តែពេលខ្លះវាមិនមានភាពទុកចិត្តបាននោះទេ នៅពេលដែលយើងពិនិត្យទៅលើភស្តុតាង។ ឧទាហរណ៍ជាពិសេសការវិភាគផ្សេងៗ ទៅលើភស្តុតាង យើងអាចឃើញកាំបិត។ កាំបិតនេះជាវត្ថុដែលបង្កព្យសនកម្មទៅដល់ជនរងគ្រោះ។ នេះជាកាំបិតដើម ក៏ប៉ុន្តែកាំបិតនេះវាត្រូវបានប្រឡាក់ប្រឡូស។ ភស្តុតាងដែលកើតចេញពីកាំបិតនេះ គឺពេលខ្លះមិនអាចជាភស្តុតាងអាចឲ្យយើងទុកចិត្តបាននោះទេ។

[១០:៥៤:១៣]

ដូច្នេះដំណាក់ដំបូងយើងត្រូវពិចារណា ថាតើភស្តុតាងមានយថាភាពដែរឬទេ? ដំណាក់កាលទីពីរ គឺភាពអាចទុកចិត្តបាននៃឯកសារ។ នៅពេលដែលយើងពិចារណាចំណុចពីរនេះហើយ យើងពិនិត្យមើលទៅលើភាពពាក់ព័ន្ធនៃឯកសារ។

ទាំងបីនេះ គឺជាដំណាក់កាលមូលដ្ឋានដែលអង្គជំនុំជម្រះត្រូវពិចារណា នៅពេលដែលទទួលយកភស្តុតាងចូលមកគឺទម្ងន់ប៉ុនណា? ភាពពាក់ព័ន្ធប៉ុនណាទៅលើឯកសារទាំងអស់នោះ ត្រូវតែសម្រេច

នៅពេលដែលយើងបានស្តាប់ចម្លើយ សក្ខីកម្មរបស់សាក្សី។ អង្គជំនុំជម្រះសាលាដំបូងជាអ្នកមានសមត្ថភាព និងមានស្ថានភាពល្អបំផុតត្រូវការពិចារណាទៅលើភស្តុតាងទាំងអស់នេះ។ នេះគឺជាប្រព័ន្ធច្បាប់ស៊ីវិលឡូ ដែលវាខុសពីប្រព័ន្ធច្បាប់ខំមិនឡូ។ យើងខ្ញុំជឿថា យើងកំពុងតែមកចូលរួមនៅក្នុងសវនាការដែលមានក្រុមប្រឹក្សាជំនុំជម្រះមានវិជ្ជាជីវៈ។ សហព្រះរាជអាជ្ញា គាត់បានលើកឡើងអំពីឯកសារ និងភស្តុតាងមួយចំនួន ដែលគាត់ចង់ដាក់ ហើយសហព្រះរាជអាជ្ញា ក៏បានឯកភាពគ្នាជាមួយនឹងយើងត្រង់ចំណុចមួយចំនួនផងដែរ។ សហព្រះរាជអាជ្ញាទទួលស្គាល់ថា យ៉ាងហោចណាស់សហព្រះរាជអាជ្ញាត្រូវតែព្យាយាមបង្ហាញឯកសារទាំងអស់នោះថា វាមានយថាភាព និងអាចទុកចិត្តបាន។ ជាការពិត ហើយត្រូវបង្ហាញអំពីភាពពាក់ព័ន្ធទៅនឹងឯកសារផងដែរ។

[១០:៥៥:៥០]

ដូច្នេះយថាភាព និងភាពពាក់ព័ន្ធនឹងភាពទុកចិត្តបាននោះ គឺត្រូវតែយើងពិនិត្យមើលឯកសារ។ ដូច្នេះហើយយើងខ្ញុំសូមសន្និដ្ឋាន និងជឿជាក់ថា យើងត្រូវតែពិនិត្យពិច័យមើលទៅលើឯកសារ និងភស្តុតាងទាំងអស់នោះ តើមានភស្តុតាងណា និងឯកសារណាខ្លះ ដែលវាពាក់ព័ន្ធ យើងមិនគួរទុករហូតដល់ដំណាក់កាលចុងក្រោយនៃសវនាការនោះទេ។ ហើយឯកសារមួយចំនួន គឺវាមិនពាក់ព័ន្ធ ហើយវាអាចធ្វើឲ្យអង្គជំនុំជម្រះ ក្រុមប្រឹក្សាជំនុំជម្រះពិបាកក្នុងការពិចារណា និងសម្រេច។ ដូច្នេះយើងខ្ញុំទាមទារឲ្យមានការពិនិត្យពិច័យទៅលើឯកសារមួយចំនួនទាំងអស់នោះ ហើយយើងឯកភាពជាគោលការណ៍ផងដែរ ទៅលើគោលការណ៍វិមតិសង្ស័យ នៅពេលដែលមានវិមតិសង្ស័យទៅលើយថាភាព និងភាពទុកចិត្តបាន និងពាក់ព័ន្ធនៃឯកសារវិមតិសង្ស័យទាំងអស់នេះ គួរតែផ្តល់ជូនមកខាងជនជាប់ចោទ។

[១០:៥៦:៤៩]

យើងខ្ញុំសូមនិយាយអំពីគោលការណ៍បទដ្ឋាននៃការទទួលយកភស្តុតាង។ វិធាន៨៤(១) គឺចែងអំពីការចូលខ្លួនបង្ហាញខ្លួនរបស់សាក្សី និងអ្នកជំនាញទៅតាមវិធាន៨៤ នេះ ហើយវិធាន៨៧ គឺចែងអំពីការទទួលយកភស្តុតាងសក្ខីកម្ម។ ភស្តុតាងឯកសារដទៃទៀតគឺ ទទួលយកបានដោយត្រូវគោរពលក្ខខណ្ឌនៅក្នុងវិធាន៨៧(៣)។ ដូចដែលលោក លោកស្រីចៅក្រមបានជ្រាបរួចមកហើយ អង្គជំនុំជម្រះអាចបដិសេធភស្តុតាងទាំងឡាយណា ដែលខ្លួនរកឃើញ ដូចដែលសហព្រះរាជអាជ្ញា បានលើកឡើងហើយ ដែលភស្តុតាងទាំងអស់នោះ មិនជាប់ពាក់ព័ន្ធជាការស្នើសុំជាន់គ្នា មិនអាចរកបានក្នុងរយៈ

ពេលសមស្របណាមួយ។ មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង ច្បាប់មិនអនុញ្ញាត ឬក៏មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍។

[១០:៥៧:៥៧]

វិធាន៨៧(១) ចែងថា ខ្ញុំសូមដកស្រង់សម្តី៖ "លើកលែងតែមានចែងផ្សេងពីនេះ ភស្តុតាងទាំងអស់អាចទទួលយកបាន លើកលែងតែមានចែងផ្សេងពីនេះនៅក្នុងវិធានផ្ទៃក្នុង"។ វិធាននេះមានចែងរួមបញ្ចូលហើយសហព្រះរាជអាជ្ញា ក៏បានឯកភាពដែរ វាចែងបញ្ចូលរួមអំពីគោលការណ៍នៅក្នុងច្បាប់ស៊ីវិល ដែលវាពាក់ព័ន្ធទៅនឹងការវាយតម្លៃដោយសេរីទៅលើភស្តុតាង ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដែលយើងដែលតុលាការត្រូវធ្វើការពិចារណាដោយឥស្សរចិត្ត។ ប៉ុន្តែត្រូវគោរពទៅតាមអ្វីដែលខ្ញុំលើកឡើងថា នៅពេលមានវិមតិសង្ស័យទៅលើភស្តុតាង តម្លៃនៃភស្តុតាងទាំងអស់នោះគួរតែផ្តល់ប្រយោជន៍ទៅកាន់ជនជាប់ចោទ។ នេះគឺវាពាក់ព័ន្ធទៅនឹងភាពអាចទទួលយកបាននៃភស្តុតាង។

[១០:៥៨:៥៩]

គោលការណ៍នៃការវាយតម្លៃភស្តុតាងដោយសេរី គឺត្រូវគោរពទៅលើលក្ខណ:វិនិច្ឆ័យដូចមានចែងនៅក្នុងវិធាន៨៧(៣) ដែលវិធាននេះផ្តល់ឆន្ទានុសិទ្ធិដល់អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើសុំភស្តុតាងណាមួយ ដែលអង្គជំនុំជម្រះយល់ឃើញថា ភស្តុតាងទាំងអស់នោះមិនពាក់ព័ន្ធ ជាន់គ្នា មិនអាចរកបានក្នុងរយ:ពេលសមស្របណាមួយ មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុ ដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង ច្បាប់មិនអនុញ្ញាត ឬមានចេតនាពន្យារកិច្ចដំណើរការនីតិវិធី។

នេះជាលក្ខណ:វិនិច្ឆ័យមួយចំនួនដូចមានចែង។ នៅក្នុងសំណុំរឿង០០១ នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងកថាខណ្ឌ៤១ លោក លោកស្រីចៅក្រមបានសម្រេចទៅលើលក្ខណ:វិនិច្ឆ័យ ដូចតទៅនេះ ខ្ញុំសូមដកស្រង់ "លើសពីនេះ ដើម្បីអាចយកមកប្រើប្រាស់ជាភស្តុតាង សម្ភារ:ដែលមាននៅក្នុងសំណុំរឿងត្រូវតែបំពេញលក្ខខណ្ឌច្បាស់លាស់នៃភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាននៃភស្តុតាង។ អង្គជំនុំជម្រះអាចបដិសេធមិនទទួលយកធ្វើជាភស្តុតាងនូវសម្ភារ:ណាមួយដែលផ្អែកលើលក្ខណ:វិនិច្ឆ័យមានចែងនៅក្នុងវិធាន៨៧(៣) នៃវិធានផ្ទៃក្នុង" បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានចែងបន្តទៀត។ ដូច្នេះហើយ នៅក្នុងនេះអង្គជំនុំជម្រះបានសម្រេចរួចមកហើយ។ នៅក្នុងសំណុំរឿង០០១ ផងដែរ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ដើម្បីប្រើប្រាស់ជាភស្តុតាងបានសម្ភារ:ទាំងឡាយដែលមាននៅក្នុងសំណុំរឿងត្រូវតែបំពេញបទដ្ឋានអប្បបរមានៃភាពពាក់ព័ន្ធ ភាពអាច

ទុកចិត្តបាន ដែលចាំបាច់ត្រូវតែបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ។ នៅពេលដែលផលិត ឬបង្កើតនូវចំពោះមុខអង្គជំនុំជម្រះរួចហើយនោះ តម្លៃនៃភស្តុតាង ទម្ងន់ដែលភ្ជាប់ទៅលើភស្តុតាងទាំងអស់នោះនឹងត្រូវយកមកវាយតម្លៃបន្ថែម។

[១១:០១:០២]

នេះគឺមានសរសេរនៅក្នុងសេចក្ដីសម្រេចនៃភាពអាចទទួលយកបាន នៃសម្ភារៈនៅក្នុងសំណុំរឿងជាភស្តុតាងថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ ឯកសារ E43/4។ នៅពេលសម្រេចថា តើ-- នៅពេលសម្រេចទទួលយកខ្សែវីដេអូនៅក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា សម្ភារៈខ្សែវីដេអូទាំងអស់នោះ អាចទទួលយកបាន ក៏ប៉ុន្តែត្រូវស្ថិតនៅក្រោមការពិនិត្យឡើងវិញនៃភាពពាក់ព័ន្ធយថាភាពក្នុងពេលសវនាការលើអង្គសេចក្ដី។ ឯកសារលេខ E/5/10/2 ពាក់ព័ន្ធទៅនឹងសេចក្ដីសម្រេចលើភាពអាចទទួលយកបាននៃសម្ភារៈ ភស្តុតាងថ្មី និងសេចក្ដីណែនាំទៅដល់ភាគី កថាខណ្ឌ១៦(៤)។

ដូចនេះ អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យហើយថា ពេលខ្លះភស្តុតាងទាំងអស់ ឯកសារទាំងអស់មានភាពពាក់ព័ន្ធនឹងយថាភាព។ ក៏ប៉ុន្តែនៅពេលដែលយើងមើលវិធានផ្ទៃក្នុងរបស់យើង នៅពេលដែលយើងមើលយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះនេះដែលបានបង្កើតឡើងក្នុងសំណុំរឿង០០១ នៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង យើងយល់ឃើញយ៉ាងច្បាស់ថា ដើម្បីទទួលយកភស្តុតាងបាននោះភស្តុតាងទាំងនោះត្រូវតែគោរពទៅតាមបទដ្ឋានអប្បបរមានៃភាពអាចពាក់ព័ន្ធនៃឯកសារ និងយថាភាពនៃឯកសារ។

[១១:០២:៣៨]

ដូច្នេះហើយយើងនៅតែគោរពថា គោលការណ៍វិមតិសង្ស័យត្រូវតែគោរពដដែល។ ដូច្នេះ នៅពេលដែលយើងពិនិត្យទៅលើយថាភាព ភាពអាចទុកចិត្តបាននិងភាពពាក់ព័ន្ធនៃឯកសារ យើងត្រូវគោរពទៅលើគោលការណ៍វិមតិសង្ស័យផងដែរ។ ដូច្នេះវិមតិសង្ស័យត្រូវជាប្រយោជន៍ទៅដល់ជនជាប់ចោទ។

នៅក្នុងសេចក្ដីសម្រេចរបស់តុលាការកំពូល ត្រង់សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់លោកខៀវ សំផន ស្ដីពីសំណើសុំដោះលែងបន្ទាប់ ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១ ឯកសារលេខ E50/3/1/4 កថាខណ្ឌ៣១ ចែងថា “អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់យ៉ាងមុតមាំថា គោលការណ៍វិមតិសង្ស័យមានចែងដោយរដ្ឋធម្មនុញ្ញ ដែលវាកើតចេញពីការសន្មតជាមុនថា “គ្មានទោស” ហើយវាមានមុខងារជាចម្បង-- មុខងារជាចម្បងក្នុងការបង្ហាញឲ្យឃើញនូវការយល់ និងជាស្វ័យប្រវត្តិក្នុង

ករណីពុំមានភស្តុតាង បំបាត់ភាពវិមតិសង្ស័យ”។

[១១:០៣:៥៦]

ដូច្នេះហើយ យើងក៏ត្រូវពិនិត្យមើលទៅលើយុត្តិសាស្ត្ររបស់តុលាការ អាយ.ស៊ី.ធី.វ៉ាយ ក្នុងរឿងក្តី *ឌឺឡាលិក(Delalic)* ដែលក្នុងនោះគោលការណ៍វិមតិសង្ស័យក៏គេបានយកមកអនុវត្តផងដែរនៅក្នុងបរិបទអន្តរជាតិ។ ទោះបីជាខ្ញុំត្រូវបញ្ជាក់ឱ្យបានច្បាស់ក៏ដោយ គឺនៅក្នុងនេះគឺវាបញ្ជាក់អំពីអង្គហេតុដែលវាពាក់ព័ន្ធទៅនឹងអង្គច្បាប់ដូចដែលខ្ញុំបានដកស្រង់រួចមកហើយ។

នៅពេលនេះ ខ្ញុំសូមចូលលម្អិតមួយទៀត ខ្ញុំសូមអភ័យទោសដែលខ្ញុំលើកឡើងជាន់គ្នាទៅនឹងទឡ្ហីករណ៍ និងអំណះអំណាងដូចដែលអង្គជំនុំជម្រះបានស្តាប់រួចមកហើយនៅក្នុងថ្ងៃនេះ។ នៅពេលនេះខ្ញុំលើកឡើងអំពីយថាភាព និងភាពអាចទុកចិត្តបាន និងភាពពាក់ព័ន្ធនៃឯកសារ។ ពាក់ព័ន្ធទៅនឹងយថាភាព យើងត្រូវតែសម្រេច យើងខ្ញុំសន្និដ្ឋានថា មុនពេលដែលយើងទទួលយកភស្តុតាងនោះ យើងត្រូវតែសម្រេចទៅលើយថាភាព។ ភាគីត្រូវតែបង្ហាញជាបឋម អំពីយថាភាព ដើម្បីអាចឱ្យយើងទទួលយកឯកសារបាន អនុលោមតាមវិធាន៨៧(៣)(គ)។

យើងខ្ញុំសូមលើកឡើងថា មកទល់ពេលនេះ មិនមានការបង្ហាញជាបឋមដូច្នេះនោះឡើយ។ យើងខ្ញុំសូមសន្និដ្ឋានថា ការចង្អុលទៅលើសហចៅក្រមស៊ើបអង្កេត ថាសហចៅក្រមស៊ើបអង្កេតនោះគាត់ធ្វើរួចហើយ យើងមិនបាច់បារម្ភនោះទេ យើងគួរតែទុកចិត្តទៅ វាមិនសមស្របនោះទេ ហើយវាមិនស៊ីសង្វាក់ទៅនឹងច្បាប់ដែលយើងត្រូវយកមកអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះមួយនេះនោះឡើយ។

យើងសូមបញ្ជាក់ថា យថាភាពគឺមិនអាចបង្ហាញទៅតាមភាពនៃឯកសារនោះទេ យោងទៅតាមវិធាន៨៧(៣)(គ)។ នៅក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះសាលាដំបូងបានដកចេញនូវចម្លើយរបស់សាក្សីពីររូបដែលបានស្លាប់ ដែលសាក្សីទាំងអស់នេះបានលើកឡើងដោយសហព្រះរាជអាជ្ញា។

[១១:០៦:១២]

អង្គជំនុំជម្រះបានលើកឡើងថា អង្គជំនុំជម្រះបដិសេធចម្លើយទាំងអស់នេះ ដោយសារតែប្រភពខ្លឹមសារ និងលក្ខណៈតវ៉ា រួមទាំងអលទ្ធភាពរបស់ជនជាប់ចោទក្នុងការតវ៉ាទៅលើភាពត្រឹមត្រូវនៃឯកសារ។ កត្តាទាំងនេះគឺវាធ្វើឱ្យចម្លើយទាំងអស់នោះ មិនអាចបង្ហាញអង្គហេតុ ដូចដែលបានចែងនៅក្នុងវិធាន៨៧(៣)។ ចំណុចនេះចែងនៅក្នុងសំណុំរឿងនៃឯកសារលេខ E43/4។

យើងក៏មើលយុត្តិសាស្ត្រមកពីតុលាការ អាយ.ស៊ី.ធី.វ៉ាយ និង អាយ.ស៊ី.ធី.អ័រ ផងដែរ ដែល

នៅទីនោះ ខ្ញុំជឿថាវិធាន៨៩(ង) ចែងថា អង្គជំនុំជម្រះអាចស្នើសុំឲ្យផ្ទៀងផ្ទាត់ទៅលើយថាភាពនៃឯកសារដែលទទួលបាននៅក្រៅតុលាការ។

[១១:០៧:១៦]

ជាបឋម យើងសូមកត់សម្គាល់ពាក្យថា "អាច" វាមិន-- ទោះបីវាមិនមែនជាការបង្គាប់អាជ្ញាបញ្ញាដាច់ណាត់ក៏ដោយ ក៏ប៉ុន្តែយើងសូមលើកឡើងថា ភាគីដែលស្នើសុំបង្ហាញឯកសារនោះ ដែលជាអ្នកត្រូវបង្ហាញអំពីភាពអាចទុកចិត្តបាន ដូច្នេះភាគីនេះត្រូវបានបង្ហាញ ថាតើឯកសារនោះជាអ្វី ហើយឯកសារនោះ ពិតប្រាកដដែរឬទេ មុនពេលដែលយើងអាចទទួលយកឯកសារទាំងអស់នោះមកធ្វើជាភស្តុតាងបាន?

ប្រសិនបើយើងមើលនៅក្នុងរឿងក្តី *បារហ្គាស្វា* អាយ.ស៊ី.ធី.អ័រ 98-41 ដែលក្នុងនេះពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចលើការទទួលយកភស្តុតាងមួយចំនួន។ សេចក្តីសម្រេចនេះចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៤ កថាខណ្ឌ៨ ហើយសេចក្តីនេះក៏វាស្រដៀងគ្នាទៅនឹងសេចក្តីសម្រេចរបស់តុលាការមួយទៀតដែលវាពាក់ព័ន្ធទៅនឹងការទទួលយកការប្រាស្រ័យទាក់ទងដែលបានលួចស្តាប់ ហើយយើងខ្ញុំក៏បានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានរបស់យើងខ្ញុំជាច្រើនលើកច្រើនសាដែរ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

[១១:០៨:៤៣]

ឯកសារទាំងឡាយ ដែលពុំមានយថាភាព តាមលក្ខណៈរបស់វា បានន័យថា សម្ភារៈទាំងអស់នោះគឺមិនមានតម្លៃជាភស្តុតាងនោះទេ។ យើងត្រូវតែពិចារណាទៅលើតម្លៃនៃភស្តុតាងនៃសម្ភារៈដែលមិនមានយថាភាព។ យើងសូមទទួលស្គាល់ថា សហព្រះរាជអាជ្ញាត្រឹមត្រូវនៅពេលដែលនិយាយ-- នៅពេលដែលសហព្រះរាជអាជ្ញានិយាយថា វាមានភាពពិបាក ដែលយើងត្រូវធ្វើការដោះស្រាយ ជាពិសេសនៅពេលដែលយើងបង្ហាញទៅលើភស្តុតាង ហើយសហព្រះរាជអាជ្ញាត្រូវតែបង្ហាញឲ្យហួសពីវិមតិសង្ស័យ។ ក៏ប៉ុន្តែនៅពេលពិចារណាលើចំណុចនេះ យើងត្រូវតែពិនិត្យទៅលើទម្ងន់នៃភស្តុតាង ហើយត្រូវតែយល់ថា ភស្តុតាងទាំងអស់នោះ មានយថាភាពដែរឬទេ ហើយអាចទុកចិត្តបានដែរឬទេ។

[១១:០៩:៣៧]

តុលាការ អាយ.ស៊ី.ធី.អ័រ នៅក្នុងសំណុំរឿង *មូសេម៉ា* សាលាដំបូងបានលើកឡើងថា នៅពេលវាយតម្លៃទៅលើយថាភាពនៃភស្តុតាងជាឯកសារ គេត្រូវពិចារណាទៅលើទម្រង់ ខ្លឹមសារនៃការប្រើ

ប្រាស់ឯកសារ រួមទាំងចំណុចដែលថា ឯកសារទាំងអស់នេះ ជាឯកសារដើម ឬក៏ឯកសារថតចម្លង។ ប្រសិនបើជាឯកសារថតចម្លង ឯកសារទាំងអស់នោះ បានចុះបញ្ជី និងដាក់នៅក្នុងអាជ្ញាធរ ដែលត្រឹមត្រូវដែរឬទេ? ហើយឯកសារទាំងអស់នោះ មានចុះហត្ថលេខា បោះត្រា និងបញ្ជាក់ក្នុងទម្រង់ណាមួយផ្សេងដែរឬទេ? ហើយឯកសារនោះ ត្រូវបានរៀបចំត្រឹមត្រូវសរសេរឡើង ឬផលិតឡើង ឬក៏អនុញ្ញាតឲ្យធ្វើឡើងដោយបុគ្គល ឬភាគីដែលជាអ្នកនិពន្ធ ឬអ្នកបង្កើតឡើងដែរឬទេ? នេះជាសេចក្ដីសម្រេចរបស់តុលាការ អាយ.ស៊ី.ធី.អ័រ នៅក្នុងរឿងក្ដី *មូសេម៉ា* ពាក់ព័ន្ធទៅនឹងសាលក្រម និងការប្រកាសទោសថ្ងៃទី២៧ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ៦៦ ដល់ ៦៧។

ដូច្នេះនៅពេលដែលយើងមើលតុលាការ អាយ.ស៊ី.ធី.អ័រ, អាយ.ស៊ី.ធី.វ៉ាយ យុត្តិសាស្ត្ររបស់តុលាការទាំងពីរ យុត្តិសាស្ត្រទាំងអស់នោះ គឺមិនខុសគ្នាឆ្ងាយដែលទាមទារឲ្យអង្គជំនុំជម្រះនេះគោរពតាមផងដែរនោះទេ។

[១១:១១:០០]

នៅពេលដែលយើងពិចារណាទៅលើការទទួលយកឯកសារ និងភស្តុតាង។ ភាពជឿជាក់ ភាពជឿទុកចិត្តបាននៃឯកសារ-- នៅពេលនេះ ខ្ញុំនិយាយអំពីភាពទុកចិត្តនៃឯកសារ។ ភាពទុកចិត្តនៃឯកសារត្រូវតែសម្រេចមុនពេលទទួលយកជាភស្តុតាងផងដែរ។ ឯកសារដែលមិនអាចទុកចិត្តបានគឺឯកសារដែលមិនអាចបង្ហាញអំពីអង្គហេតុ ហើយអាចឲ្យយើងសម្រេចមិនអាចទទួលយកបាន អនុលោមតាមវិធាន៨៧(៣)(គ)។ ខ្ញុំសូមឲ្យអង្គជំនុំជម្រះមើលរឿងក្ដី ឌុច ពាក់ព័ន្ធទៅនឹងការទទួលយកសម្ភារៈឯកសារនៅក្នុងសំណុំរឿងយកមកធ្វើជាភស្តុតាង។ សេចក្ដីសម្រេចនេះ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ ឯកសារលេខ E43/4 កថាខណ្ឌ៧ និងកថាខណ្ឌ១៦។ យើងខ្ញុំទទួលស្គាល់ថា ទម្រង់ ខ្លឹមសារ ឬភាពដើម ប្រភពនៃព័ត៌មានទាំងអស់នោះ វាអាចជាការបញ្ជាក់បង្ហាញឲ្យយើងឃើញអំពីភាពទុកចិត្តបាននៃឯកសារ។

ដូច្នេះ ខ្ញុំមិនចំណាយពេលក្នុងការធ្វើអត្ថាធិប្បាយទៅលើការលើកឡើងរបស់ខាងសហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងចំណុចនោះទេ វាមានលក្ខណៈលម្អិតរួចទៅហើយ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ចំណុចនេះ ដោយសារតែយើងក៏ឯកភាពផងដែរថា យើងត្រូវពិនិត្យមើលទៅលើសញ្ញាបញ្ជាក់មួយចំនួនដែលបង្ហាញឲ្យយើងឃើញទៅលើភាពទុកចិត្តបាននៃឯកសារ។

[១១:១២:៣៤]

លក្ខណៈវិនិច្ឆ័យមួយចំនួនផ្សេងទៀតនោះ ដែលអាចឱ្យយើងទទួលយកឯកសារណាមួយនោះ គឺយើងក៏ត្រូវពិចារណា ដូចដែលស្នើឡើងដោយសហព្រះរាជអាជ្ញាផងដែរ។ ដូច្នេះអ្វីដែលយើងស្នើសុំឱ្យមានសវនាការថ្ងៃនេះនោះ គឺយើងចង់ឱ្យសហព្រះរាជអាជ្ញាជាអ្នកបង្ហាញលក្ខខណ្ឌបញ្ជាក់នេះ ឱ្យបានច្បាស់លាស់មកឱ្យយើង ជាពិសេសឯកសាររបស់ ឌី.ស៊ី.ខេម ។

ដូច្នេះអ្វីដែលយើងលើកឡើងនេះ គឺថា ឌី.ស៊ី.ខេម គឺមិនមែនជាស្ថាប័នមួយមិនលម្អៀងនោះទេ។ ដូច្នេះ យើងចង់ឱ្យសហព្រះរាជអាជ្ញាបញ្ជាក់ថា តើបានទទួលដោយរបៀបណា? លក្ខខណ្ឌវិនិច្ឆ័យគេសម្រេចនោះយ៉ាងម៉េច? ហើយយើងត្រូវពិចារណាផងដែរថា ភាគីមានប្រយោជន៍នៅក្នុងការពិនិត្យមើលទៅលើឯកសារទាំងអស់នេះ ជាពិសេសផលប្រយោជន៍ដែលវាអាចប៉ះពាល់ចេញពីឯកសារទាំងអស់នេះ។

[១១:១៣:៤៨]

ដូច្នេះ វាមិនមែនថាឯកសារទាំងអស់នោះមិនមានយថាភាព និងមិនអាចទុកចិត្តបាននោះទេ។ ក៏ប៉ុន្តែយថាភាព និងភាពអាចទុកចិត្តបាននោះ ត្រូវតែបង្ហាញទោះបីជាវាលេចចេញពីស្ថាប័ន និងភាគីណាមួយក៏ដោយ។

កត្តាមួយចំនួនដែលយើងត្រូវយកមកពិចារណានៅសាលាក្តីពិសេសនានានោះ រួមទាំងឯក-- រួមមានហត្ថលេខា ត្រា និងសញ្ញាសម្គាល់ ឬការកំណត់លេខជាដើម។ ខ្ញុំមិនចូលលម្អិតទៀតទេ ដោយសារតែយើងឯកភាពជាគោលការណ៍ជាមួយនឹងសហព្រះរាជអាជ្ញាត្រង់ចំណុចនេះ។ មុនពេលដែលឯកសារទទួលយកបាននោះ ត្រូវតែមានលក្ខខណ្ឌចង្អុលបញ្ជាក់ឱ្យបានគ្រប់គ្រាន់អំពីភាពទុកចិត្តបាននៃឯកសារ ដែលលក្ខខណ្ឌនេះវាអាចជាលក្ខខណ្ឌបឋមឱ្យយើងអាចទទួលយកបាន សហព្រះរាជអាជ្ញាក៏បានឯកភាពដែរ។

នៅក្នុងរឿងក្តី *ឌីឡាលិក* នៅក្នុងតុលាការ អាយ.ស៊ី.ធី.វ៉ាយ ដែលបានបង្កើតវិធាននេះគឺវិធានដែលមិនមានការជំទាស់តវ៉ានោះទេ នៅក្នុងរឿងក្តីនោះ។ លោក លោកស្រីចៅក្រមអាចមើលរឿងក្តីដែលវាពាក់ព័ន្ធទៅនឹងពាក្យសុំរបស់ *ឌីឡាលិក* សុំការអនុញ្ញាតប្តឹងសាទុក្ខទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៨ កថាខណ្ឌ២០។

ពាក់ព័ន្ធទៅនឹងភាពអាចទុកចិត្តបាននៃឯកសារ គឺវាពាក់ព័ន្ធនឹងតម្លៃនៃភស្តុតាង។ យោងតាមយុត្តិសាស្ត្ររបស់សាលាក្តី និងតុលាការមិនអចិន្ត្រៃយ៍មួយចំនួននោះ ឯកសារត្រូវតែបំពេញលក្ខខណ្ឌ

អប្បរមាមួយចំនួនដើម្បីអាចឲ្យយើងពិចារណាភាពទុកចិត្តបាននៃឯកសារ ហើយយើងអាចពិចារណាទៅលើតម្លៃនៃភស្តុតាង។ ឯកសារត្រូវតែមាន-- ត្រូវតែគោរពទៅលក្ខខណ្ឌអប្បបរមាដើម្បីអាចឲ្យយើងពិចារណាទៅលើតម្លៃនៃភស្តុតាងបាន។ នៅក្នុងរឿងក្តី *តូប៊ូរ៉ា* និង*អាឡាឡ៊ិហាសាណូវិច* តុលាការអាយ.ស៊ី.ធី.វ៉ាយ តុលាការបានកំណត់សម្គាល់ថា សាលាដំបូងបញ្ជាក់ថា "ឯកសារត្រូវតែមានភាពពាក់ព័ន្ធនឹងត្រូវតែមានតម្លៃជាភស្តុតាង វាមានន័យថាដើម្បីឲ្យប្រកាសទទួលយកឯកសារជាភស្តុតាងបាននោះ អង្គជំនុំជម្រះត្រូវតែសម្រេចទៅលើតម្លៃរបស់ឯកសារទាំងអស់នោះ ហើយត្រូវតែសម្រេចនៅពេលក្រោយបាន"។ ខ្ញុំមិនមែនទាមទារឲ្យសម្រេចតម្លៃនៃភស្តុតាងនៅពេលនេះទេ ក៏ប៉ុន្តែតម្លៃនៃភស្តុតាងគឺជាគុណសម្បត្តិមួយ ភាពចាំបាច់មួយដែលវាមានតម្លៃខុសៗគ្នាទៅតាមកាលៈទេសៈ និងទៅតាមអង្គហេតុ។

[១១:១៦:៤២]

ពាក់ព័ន្ធទៅនឹងចំណុចទាំងអស់នេះ តាមវិធានដ៏សុក្រិត វិធានដ៏ល្អបំផុត ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើង ខ្ញុំមិនចាំចំណុចណាដែលសហព្រះរាជអាជ្ញាចង្អុលបញ្ជាក់នោះទេ។ តាមវិធានភស្តុតាងដ៏ល្អបំផុតនេះ វាទាមទារឲ្យបង្ហាញអំពីខ្លឹមសារនៃឯកសារ។ នៅពេលដែលយើងមានឯកសារដើមហើយ ហេតុអ្វីយើងមិនប្រើឯកសារដើមទៅ។ យើងត្រូវចងចាំថា យើងនៅក្នុងតុលាការអន្តរជាតិ មិនមែនជាតុលាការជាតិនោះទេ ដែលយើងមានឯកសារតែប្រាំ ឬក៏ដប់។ នៅទីនេះយើងមានឯកសាររាប់រយឯកសារ។ នៅក្នុងករណីមួយចំនួន វាពិបាកក្នុងការប្រើប្រាស់ឯកសារដើម។ ហេតុដូច្នេះហើយ យើងត្រូវតែពិនិត្យមើលវិធាននៃភស្តុតាងដែលល្អបំផុតដែលវាមានពាក់ព័ន្ធ និងអនុវត្តជាធរមាន។ យើងទទួលស្គាល់ទៅលើវិធាននេះ ហើយទាមទារឲ្យអង្គជំនុំជម្រះអនុវត្តតាមវិធាននេះ។

[១១:១៧:៤៥]

វិធាន ដែលយើងហៅថា វិធានល្អបំផុតនេះ គឺជាគោលការណ៍ណែនាំមួយដែលត្រូវបានគេប្រើប្រាស់នៅមុខតុលាការមិនអចិន្ត្រៃយ៍នានា។ ខ្ញុំសូមឲ្យមើលរឿងក្តី *ដែរីស៊ិក (ប្រកបតាមសំឡេងដើម)* IT04081 ដែលវាពាក់ព័ន្ធទៅនឹងគោលការណ៍ណែនាំទៅលើការទទួលយកភស្តុតាង និងការបង្ហាញភស្តុតាងទៅដល់ក្រុមមេធាវីការពារក្តីនៅក្នុងតុលាការ។ ឯកសារនេះ គឺចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៨ កថាខណ្ឌ៣៦ ការសន្និដ្ឋានទៅលើវិធាននៃភស្តុតាងល្អបំផុតនេះ គឺថាភស្តុតាងបន្ទាប់បន្សំ ពេលខ្លះទៅគឺមិនមានភាពអាចទុកចិត្តបានដូចឯកសារដើមរបស់វានោះទេ។ នេះវាជាលក្ខខណ្ឌដូចដែលលោក នួន ជា

បានបញ្ជាក់អ៊ីចឹង។ ខ្ញុំទាមទារឯកសារដើម ហើយធ្វើយ៉ាងម៉េចទើបខ្ញុំដឹងទៅលើខ្លឹមសារដើមប្រសិនបើខ្ញុំមិនមានឯកសារដើមផងនោះ។

[១១:១៨:៥៣]

វិធាននេះ គឺវាមានអនុវត្តនៅក្នុងរឿងក្តីមួយចំនួនផងដែរ ដែលថាឯកសារដើម ឬក៏ឯកសារមួយចំនួននោះវាអាចខុសគ្នាពីឯកសារដើម ពីឯកសារថតចម្លង ឬក៏ការចងចាំរបស់សាក្សី។ ដូច្នេះយើងខ្ញុំសូមបញ្ជាក់នៅត្រង់នេះថា ដោយសារតែយើងមិនដែលរៀបចំសវនាការដែលសហព្រះរាជអាជ្ញា អាចបង្ហាញអំពីសញ្ញាណបញ្ជាក់-- លក្ខខណ្ឌបញ្ជាក់នៃភាពទុកចិត្តបាននៃឯកសារនោះ ថាតើឲ្យភាគីលើកឡើងបញ្ហានេះតាមរបៀបណា ដោយសារតែនៅពេលដែលយើងមិនមានឯកសារដើមនោះ វាមិនគ្រប់គ្រាន់ឲ្យយើងបង្ហាញផងនោះ។

ជាការពិតយើងជឿថានៅពេលនេះយើងមានសវនាការហើយ សហព្រះរាជអាជ្ញាគាត់បានលើកឡើងថាអ្វីទៅដែលគាត់ជឿថាលក្ខខណ្ឌបញ្ជាក់នោះ។ ដូច្នេះ នៅពេលយើងបង្ហាញលក្ខខណ្ឌបញ្ជាក់នោះទើបយើងធ្វើយ៉ាងណាអាចឲ្យតែយើងប្រើឯកសារថតចម្លងបាន។ នៅពេលដែលយើងមានឯកសារដើម ដូច្នេះយើងជឿថា វិធាននៃភស្តុតាងល្អបំផុតនោះ គួរតែយើងយកមកអនុវត្តទៅ។ ដោយសារតែវាអាចមានការលើកឡើងថា វាជាការក្លែងបន្លំទៅលើឯកសារមួយចំនួន ឬក៏ឯកសារមួយចំនួននោះត្រូវមានៗភាពប្រឡូសប្រឡាក់ មិនមែនថាវាជាឧបសគ្គមួយមិនអាចឲ្យយើងធ្វើទៅបាននោះទេ ប្រសិនបើយើងយកឯកសារដើមនោះ។

ដូច្នេះ យើងខ្ញុំជឿជាក់ថា វិធានភស្តុតាងល្អបំផុតមានតួនាទី និងដើរតួនាទីយ៉ាងសំខាន់នៅចំពោះមុខអង្គជំនុំជម្រះនេះ។ អង្គជំនុំជម្រះសាលាដំបូង ក៏អាចស្នើសុំ-- ក៏ត្រូវបានស្នើសុំឲ្យបដិសេធមួយឯកសារមួយចំនួនដែលថា ផលប៉ះពាល់របស់វាមានតម្លៃច្រើនជាងតម្លៃនៃភស្តុតាង ដូចដែលខ្ញុំបានបញ្ជាក់រួចមកហើយ យថាភាព ភាពអាចទុកចិត្តបាន យើងក៏ត្រូវពិចារណាទៅលើតម្លៃនៃភស្តុតាងនៅពេលក្រោយ។ ក៏ប៉ុន្តែភស្តុតាងមួយចំនួនតាមលក្ខណៈបឋមរបស់វា តាមមើលមួយក្រឡេកភ្នែក គឺវាទាមទារឲ្យយើងធ្វើការសម្រេចនៅពេលដែលយើងពិចារណាតែម្តង។

[១១:២១:៣៥]

ទោះបីជាយើងដឹងថា ចៅក្រមទាំងអស់មានវិជ្ជាជីវៈត្រឹមត្រូវ ហើយមិនអាចលម្អៀងទៅតាមផលប៉ះពាល់នៃឯកសារមួយចំនួននោះ។ នៅតុលាការមិនអចិន្ត្រៃយ៍ឯកសារមួយចំនួន គឺមិនអាចទទួល

បាន ដោយសារតែវាមានតម្លៃច្រើនជាងតម្លៃនៃភស្តុតាងរបស់វា។ យើងអាចមើលនៅក្នុងរឿងក្តី *កាវ៉ាហ្សកា* (*Kvocka*) នៅពេលនោះអង្គជំនុំជម្រះសាលាដំបូងបានដកចេញនូវឯកសារមួយចំនួន គឺអត្ថបទស្រង់ចេញពីសារព័ត៌មាននៅក្នុង-- ដែលបង្ហាញអំពីជំរំ*អូម៉ាស្កា* ដោយសារតែតម្លៃនៃភស្តុតាងមានកម្រិតទាប ហើយវាមិនមានការចោទប្រកាន់ណាមួយដែលអាចឲ្យមានភស្តុតាងគាំទ្របាន។ ហើយឯកសារនោះ វាអាចជាការ-- អាចមានតម្លៃតិចជាងតម្លៃនៃភស្តុតាង។ ឯកសារនេះ គឺវាពាក់ព័ន្ធនឹងសេចក្តីសម្រេចទៅលើវត្ថុតាងចុះថ្ងៃ១៩ ខែកក្កដា ឆ្នាំ២០០១ ត្រង់ទំព័រពីរ។ នៅក្នុងករណីមួយចំនួនសហព្រះរាជអាជ្ញា ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីមានបំណងចង់យកសារព័ត៌មានមកធ្វើជាមូលដ្ឋាន និងឯកសារសំអាង។ ហើយឯកសារព័ត៌មាននោះ វាអាចមានផលប៉ះពាល់ ហើយវាមិនមានតម្លៃជាភស្តុតាង។ ជាពិសេសនៅពេលដែលយើងមើលទៅលើការដកស្រង់សម្តីនៅក្នុងឯកសារសារព័ត៌មាននោះ ដែលមិនអាចឲ្យមានការតវ៉ាបាន ដែលវាទាមទារឲ្យមានការពិគ្រោះយោបល់ និងប្រឹក្សា។

[១១:២៣:៤១]

នៅតុលាការ អាយ.ស៊ី.ធី.វ៉ាយ គោលការណ៍ដែលថាឯកសារត្រូវតែបដិសេធចោលនៅពេលដែលផលប៉ះពាល់របស់វាមានតម្លៃច្រើនជាងតម្លៃនៃភស្តុតាង ដែលចំណុចនេះ មានចែងនៅក្នុងវិធាន ៨៩ (ឃ) វាមិនមានអនុវត្តនៅក្នុងតុលាការ អាយ.ស៊ី.ធី.អ័រ ឬក៏តុលាការសៀរ៉ាឡេអូនទេ។ ក៏ប៉ុន្តែនៅទីនោះ តុលាការទាំងពីរនោះ គឺបានអនុវត្តឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយរបស់ចៅក្រមក្នុងការសម្រេចទៅលើភាពអាចទទួលយកបាននៃភស្តុតាង នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងពិចារណាទៅលើតម្លៃភស្តុតាង និងផលប៉ះពាល់របស់វា។ រឿងនេះ មាននៅក្នុងរឿងក្តី *ខេរ៉េមេរ៉ា* គឺសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំទទួលយកកិច្ចសម្ភាសក្រោយពេលចាប់ខ្លួនជាមួយនឹង *ចូសេហ្វ ហ្ស៊ីរ៉ូរេរ៉ា* និង *ង៉ីរុំបាត់សេ* ដែលសេចក្តីសម្រេចនេះ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០៧ កថាខណ្ឌបី។ នៅទីនោះ គឺសហព្រះរាជអាជ្ញាបានស្នើសុំទទួលយកភស្តុតាងមួយចំនួនផងដែរ ដែលសុំទទួលយកភស្តុតាងនោះ អនុលោមតាមវិធាន៩២ស្ទួន និងវិធាន៨៩(គ)។ ដូច្នេះយើងជឿថា វិធានទាំងអស់នេះវាមានលក្ខណៈពាក់ព័ន្ធ និងអាចអនុវត្តបាននៅក្នុងតុលាការអន្តរជាតិ។

យើងខ្ញុំសូមបញ្ជាក់ថា សាលាដំបូងនៅទីនេះ គឺត្រូវតែអនុវត្តក្រម និងច្បាប់កម្ពុជា និងនីតិវិធីរបស់កម្ពុជា។ នេះជាមូលដ្ឋានបឋម និងមូលដ្ឋានចម្បង។ ក៏ប៉ុន្តែតុលាការនេះ ក៏យើងឃើញថា ត្រូវគោរពតាមរដ្ឋធម្មនុញ្ញ ដែលក្នុងនោះមានចែងអំពីគោលការណ៍អន្តរជាតិ ហើយដោយយើងត្រូវគោរព

អំពីតុលាការនេះ ជាតុលាការមានលក្ខណៈអន្តរជាតិ ហើយមានការគោរពទៅតាមប្រព័ន្ធច្បាប់ស៊ីវិលឡូផងដែរនោះ។

[១១:២៦:០៧]

ចំណុចចុងក្រោយ ខ្ញុំសូមលើកឡើងអំពីការទទួលយកឯកសារ ដែលវាពាក់ព័ន្ធទៅនឹងការគំរាមកំហែង និងការអុជអាល។ វិធាន២១(៣) មិនមានទម្រង់នៃការអុជអាល ឬក៏ការបង្ខិតបង្ខំ ការគំរាមកំហែងណាមួយ ដែលធ្វើឡើងចំពោះអ្នកដែលត្រូវគេសម្ភាសន៍ អាចយកមកប្រើប្រាស់ជាភស្តុតាងនោះទេ។ ប្រសិនបើមានការអុជអាល ការបង្ខិតបង្ខំ ឬការគំរាមកំហែងមែននោះ ចម្លើយទាំងអស់នោះមិនអាចទទួលយកជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះនោះទេ។

[១១:២៦:៤៦]

នៅក្នុងសំណុំរឿង០០១ អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូង--។ បាទ ខ្ញុំសូមបញ្ជាក់ឡើងវិញ នៅក្នុងសំណុំរឿង០០២ អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងត្រូវអនុវត្តគោលការណ៍នេះ ជាពិសេសដោយគោរពទៅតាមវិធាន២១(៣) ដែលថាចម្លើយសារភាព ដែលធ្វើឡើងក្រោមអំពើទារុណកម្មមិនអាចយក-- ទទួលស្គាល់ជាអង្គហេតុបាននោះទេ ជាពិសេសប្រសិនបើខ្លឹមសារទាំងអស់នោះ វាធ្វើឡើងក្រោមទារុណកម្ម ហើយមិនអាចជាខ្លឹមសារស្មោះត្រង់។

[១១:២៧:៣១]

ខ្ញុំដឹងថា ពេលវេលាខ្ញុំជិតអស់ហើយ ដូច្នេះហើយខ្ញុំសូមនិយាយអំពីភាពពាក់ព័ន្ធនៃឯកសារតែមួយភ្លែតទេ។ ភាពពាក់ព័ន្ធនៃឯកសារក៏ត្រូវទទួលយកមុនពេល ដែលយើងទទួលស្គាល់ឯកសារជាភស្តុតាងផងដែរ ដើម្បីឲ្យយើងចៀសវាងថា ឯកសារមួយចំនួននោះមិនអាចមានភាពពាក់ព័ន្ធទៅនឹងចំណុចជាក់លាក់ ឬក៏អង្គជាក់លាក់នោះទេ។

ដូច្នេះ ភាគីដែលស្នើសុំឲ្យប្រើប្រាស់ភស្តុតាងនោះ គឺត្រូវតែបង្ហាញថា ហេតុអ្វីឯកសារទាំងអស់នោះពាក់ព័ន្ធ ឬក៏មិនពាក់ព័ន្ធ? ហើយវាពាក់ព័ន្ធដោយរបៀបណា? ភាពពាក់ព័ន្ធនៃឯកសារ គឺមានចែងថា ជាភស្តុតាងដែលអាចបង្ហាញ ឬក៏មិនអាចបង្ហាញអំពីអង្គហេតុ។ ដូច្នេះមានន័យថា ភស្តុតាង ដែលពាក់ព័ន្ធវាអាច ឬក៏មិនអាចអំពី-- មិនអាចបង្ហាញអំពីអត្ថិភាពនៃអង្គហេតុ ឬចំណុចដែលពាក់ព័ន្ធ។

[១១:២៨:៣១]

យើងខ្ញុំជឿជាក់ថា នៅពេលយើងសម្រេចយថាភាព ភាពអាចទុកចិត្តបាននោះ ក្រៅពីការទទួលយកឯកសារទាំងអស់នោះជាភស្តុតាង យើងក៏ត្រូវសម្រេចផងដែរថា ហេតុអ្វីឯកសារជាភស្តុតាងទាំងអស់នោះវាមានភាពពាក់ព័ន្ធ? ហើយពាក់ព័ន្ធដោយរបៀបណា? វាក៏ដូចករណីដែលថា ប្រសិនបើជាភាគី គាត់សួរទៅ-- គាត់ស្តាប់ចម្លើយទៅលើសាក្សី។ ដូច្នេះនៅពេលចំណុចនុំង វាអាចមានផលប៉ះពាល់ទៅដល់សាក្សី ដោយសារពេលខ្លះសាក្សីអាចដកចេញពីការផ្តល់សក្ខីកម្ម ហើយពេលខ្លះទៅទោះបីដកចេញក៏ដោយ ក៏វាមានភាពពាក់ព័ន្ធ។

[១១:២៩:២០]

អង្គជំនុំជម្រះសាលាដំបូងអាចកាត់ភាគីបាន ហេតុអ្វីបានជាភាគីសួរទៅលើចំណុចដែលវាពាក់ព័ន្ធផ្សេងទៀត ឬក៏វាមិនពាក់ព័ន្ធផ្សេងទៀត? ហើយវាពាក់ព័ន្ធទៅនឹងបទចោទត្រង់កថាខណ្ឌមួយណានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ?

ដូច្នេះការធ្វើដូច្នេះគឺចៀសវាងកុំឲ្យភាគីសួរសំណួរដែលមិនពាក់ព័ន្ធ។ ដូច្នេះនៅក្នុងដំណាក់កាលនៃការទទួលយកភស្តុតាងនោះ គឺយើងមិនគួរយកឯកសារដែលមិនពាក់ព័ន្ធយកមកពិចារណានោះទេ។

ជាថ្មីម្តងទៀតដោយសារតែខ្ញុំអស់ពេលវេលានោះហើយ ខ្ញុំសូមអរគុណអង្គជំនុំជម្រះសាលាដំបូង ដែលបើកឱកាសនៅពេលនេះ ឲ្យយើងខ្ញុំលើកសេចក្តីសន្និដ្ឋានរបស់យើងខ្ញុំ។ សូមអរគុណ។

[១១:៣០:០៩]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវីការពារក្តីជនជាប់ចោទ អៀង សារី។ ហើយជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាទៅមេធាវីការពារក្តីឲ្យជនជាប់ចោទ ខៀវ សំផន ហើយមេធាវីមានពេលវេលា៣០នាទី ដើម្បីលើកបញ្ហាភស្តុតាងទូទៅដែលមាននៅក្នុងឯកសារ ដែលពាក់ព័ន្ធនឹងដំណើរការសវនាការនៃរឿងក្តី០០២នេះ។ សូមអញ្ជើញ!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ និងអង្គសវនាការទាំងមូល។ ទាក់ទងទៅនឹងការជំនុំជម្រះនៅថ្ងៃនេះ ខ្ញុំបាទសូមធ្វើការកត់សម្គាល់ជាលក្ខណៈខ្លីសង្ខេប ដោយហេតុថា សហភាគីរបស់យើងបានបង្ហាញពីចំណុចពាក់ព័ន្ធយ៉ាងច្រើនហើយ។ ហើយម្យ៉ាងទៀត ខ្ញុំបានពិនិត្យទៅលើសេចក្តីថ្លែងរបស់សហព្រះរាជអាជ្ញា ក៏ឃើញនូវចំណុចដែលត្រូវរ៉ូវគ្នាមួយចំនួនធំដែល

អាចឲ្យក្រុមប្រឹក្សាជំនុំជម្រះ សម្រេចទៅលើនីតិវិធីនេះបាន។

[១១:៣១:៣៥]

ជាបឋម ខ្ញុំបាទសូមទាញការចាប់អារម្មណ៍ចំពោះវិធាន៨៧(១) ទាក់ទងទៅនឹងវិធាននៃការបង្ហាញភស្តុតាង ដែលយើងកំពុងធ្វើការដេញដោលពិភាក្សាកន្លងមកនេះ ហើយដែលខ្ញុំមើលឃើញថាអាចមានការយល់ច្រឡំ។ ការលើកឡើងអំពីវិធាននេះរបស់ភាគីកន្លងមក បង្ហាញនូវភាពត្រឹមត្រូវហើយថាអាចយកវិធាននេះមកអនុវត្ត ក៏ប៉ុន្តែការយល់ច្រឡំនោះវាមាន ការយល់ច្រឡំយ៉ាងម៉េច? ការយល់ច្រឡំ ឬការភ័ន្តច្រឡំនោះគឺថា ពាក្យថា "ទទួលយកបាន"។ ខ្ញុំសូមអានប្រយោគទាំងមូល "លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក"។ អ៊ីចឹង ពាក្យថា "ទទួលយក" នេះ ក្នុងភាសាអង់គ្លេសមានន័យថា *"អេតមីសស៊ីប៊ល(Admissible)"* ដែលតុលាការត្រូវទទួលយក។ បានន័យថា នៅពេលដែលគេដាក់ភស្តុតាងមក គឺក្រុមប្រឹក្សាជំនុំជម្រះទទួលយក។ ទទួលយកនេះ សួរថាមានន័យថាម៉េច? នេះជាចំណុចដែលយើងត្រូវពិភាក្សា។ ទទួលយកមិនមែនមានន័យថា យកជាការដែលឲ្យក្រុមប្រឹក្សាជំនុំជម្រះលើកជាសំអាង ក្នុងការសម្រេចសេចក្តីរបស់ក្រុមប្រឹក្សានោះទេ។ ការទទួលយកនេះគឺមានន័យថា ការទទួលយកសម្រាប់ដេញដោល។

[១១:៣៣:១៥]

នេះហើយជាចំណុចដែលជាចំណុចគន្លឹះសម្រាប់បន្តទៅកថាខណ្ឌខាងក្រោមទៀត។ ក៏ប៉ុន្តែនៅពេលដែលយើងពិនិត្យថា អ៊ូទទួលយកអ៊ីចឹងបានន័យថា យកជាការ។ អានេះវាធ្វើឲ្យមានការភ័ន្តច្រឡំពីព្រោះថា ការទទួលយកត្រូវឆ្លងកាត់ការដេញដោលមួយទៀត មានន័យថា ទទួលយកហើយ ដើម្បីឲ្យយកជាការបានត្រូវឆ្លងកាត់ការដេញដោល។ ហេតុអីបានមានការដេញដោល ដេញដោលដោយភាគីហ្នឹងគឺដើម្បីបញ្ជាក់ថា ភស្តុតាងហ្នឹងវាត្រឹមត្រូវ ឬក៏វាខុសយ៉ាងណាយ៉ាងណីនោះ។ បើសិនជាភស្តុតាងដែលដាក់មកពុំមានការដេញដោលទេ។ អ៊ីចឹងសួរថាតើក្រុមប្រឹក្សាជំនុំជម្រះ អាចស្វែងយល់ថាភស្តុតាងហ្នឹងជាភស្តុតាងពិតប្រាកដគួរឲ្យជឿបាន ឬក៏មានភាពពាក់ព័ន្ធនោះយ៉ាងម៉េចនោះបានទេ? គឺវាអត់មានទេ។ អ៊ីចឹងវាទាមទារឲ្យមានការដេញដោលពីភាគីទាំងអស់ ដើម្បីស្វែងរកចំណុចដែលគួរឲ្យជឿបាន ឬចំណុចដែលមិនគួរឲ្យជឿបាននៃភស្តុតាងនេះ ហើយចំណុចនេះគឺសហព្រះរាជអាជ្ញា លោកបានលើកបញ្ជាក់ហើយថា លោកនឹងបង្ហាញឲ្យមានភាពជឿជាក់ និងឲ្យមានការដេញដោលចំពោះភស្តុតាងទាំងឡាយណា ដែលលោកនឹងលើក។ ដូច្នេះ វាជាចំណុចសំខាន់មួយ សម្រាប់ការពិនិត្យទៅលើភស្តុតាង

របស់ក្រុមប្រឹក្សាជំនុំជម្រះ។

[១១:៣៤:៣៩]

អ៊ីចឹងចូលទៅដំណាក់កាលទីបី ទាក់ទងនឹងថា តើភស្តុតាងបែបណាដែលគួរយកជាការ ដែលក្រុមប្រឹក្សាជំនុំជម្រះគួរលើកយកមកពិចារណា ដើម្បីកំណត់ថា វាគួរឲ្យជឿបាន ឬអត់នោះ? អានេះវាជាឆន្ទានុសិទ្ធិរបស់ក្រុមប្រឹក្សាជំនុំជម្រះ ក្នុងការសម្រេចទៅលើភាពពាក់ព័ន្ធ និងភាពគួរឲ្យជឿបានរបស់ភស្តុតាង។ អ៊ីចឹង ការសម្រេចយកចំណុចណា ឬភស្តុតាងណានៅក្នុងឯកសារទាំងឡាយជាភស្តុតាង វាជាឆន្ទានុសិទ្ធិរបស់ក្រុមប្រឹក្សាជំនុំជម្រះ។ ក៏ប៉ុន្តែ ឆន្ទានុសិទ្ធិនោះមិនមែនមានន័យថា ចង់សម្រេចយ៉ាងម៉េចក៏បានស្រេចតែចិត្តនោះទេ គឺក្រុមប្រឹក្សាជំនុំជម្រះ ខ្ញុំជឿថាលោកមានគោលការណ៍កំណត់ពីភាពគួរឲ្យជឿជាក់បាន ឬក៏ភាពពាក់ព័ន្ធនៃឯកសារ ឬភស្តុតាងទាំងអស់នោះមុននឹងសម្រេចយកភស្តុតាងទាំងអស់សម្រាប់ដាក់បន្ទុក ឬក៏ដោះបន្ទុកក្នុងរឿងក្តីនេះ។

[១១:៣៥:៤១]

ជាគោលការណ៍ដែលយើងពិភាក្សាគ្នាមួយទៀតថា ហេតុអ្វីបានត្រូវឲ្យមានការដេញដោលទៅលើភស្តុតាង? ខ្ញុំជឿថា ក្រុមប្រឹក្សាជំនុំជម្រះក៏ដូចសហព្រះរាជអាជ្ញា លោកប្រាកដជាយល់ច្បាស់អំពីតួនាទីនៃការ ដែលជាបន្ទុកបង្ហាញភស្តុតាង របស់សហព្រះរាជអាជ្ញានោះយ៉ាងច្បាស់ប្រាកដណាស់ហើយ។ អ៊ីចឹង ដើម្បីឲ្យបង្ហាញភស្តុតាងបាន សួរថា តើយើងមានបទដ្ឋានអី កម្រិតអី ខ្នាតអី ដើម្បីបញ្ជាក់ថា សហព្រះរាជអាជ្ញាបង្ហាញភស្តុតាង? គឺយើងមានគោលការណ៍មួយទាក់ទងទៅនឹងការបង្ហាញឲ្យលើសពីវិមតិសង្ស័យ។ ដែលចំណុចនេះ ខ្ញុំបានឮលោកមេធាវី ម៉ៃខល កាណាវាស ក៏បានជម្រាបជូនហើយអម្បាញ់មិញនេះ។ ការបង្ហាញឲ្យលើសពីវិមិតសង្ស័យនេះ គឺវាជាខ្នាតសម្រាប់វាស់នូវភស្តុតាង ដែលសហព្រះរាជអាជ្ញាមានភារកិច្ចដើម្បីបំពេញ។ អ៊ីចឹងសួរថា ចុះបើសហព្រះរាជអាជ្ញាខកខានមិនបានបំពេញតួនាទីនេះ បានន័យថាមិនបានបង្ហាញភស្តុតាងឲ្យលើសពីវិមតិសង្ស័យ នៅក្នុងគោលការណ៍មួយទៀត គឺមានគោលការណ៍ឆ្លើយតបចំពោះគោលការណ៍នេះគឺថា វិមតិសង្ស័យគឺជាប្រយោជន៍របស់ជនជាប់ចោទ។ អ៊ីចឹងមានន័យថា ការបង្ហាញភស្តុតាងដែលមិនបានលើសពីវិមតិសង្ស័យនោះមិនអាចយកជាការ ដែលក្រុមប្រឹក្សាជំនុំជម្រះមិនអាចយកធ្វើជាមូលដ្ឋានសម្រាប់ដាក់ទោសដល់ជនជាប់ចោទបានទេ។ អ៊ីចឹងដោយសារគោលការណ៍វាពាក់ព័ន្ធគ្នាបែបនេះ បានតម្រូវឲ្យសហព្រះរាជអាជ្ញាមានភារកិច្ចក្នុងការបង្ហាញភស្តុតាង។

[១១:៣៧:៥៧]

ក៏ប៉ុន្តែ បើសិនជាយើងនៅទីនេះ យើងយល់ឃើញថានៅក្នុងវិធាន៨៧(១) នេះ យល់ថារាល់ភស្តុតាងទាំងអស់ ដែលដាក់ចូលមកហ្នឹងអាចយកជាការបាន មានន័យថា អាចទទួលយកបាន។ មានន័យថា យកជាការបានវិញនោះ អ៊ីចឹងការដេញដោលនេះគឺត្រូវអត់មាន វាបាត់ការដេញដោល។ កាលណាអត់មានការដេញដោល ក៏យើងមិនអាចដឹងថាតើភស្តុតាងហ្នឹង វាមានកំហុស ឬក៏អាចគួរឲ្យជឿទុកចិត្តបានប៉ុនណា? គឺអត់មានដូចគ្នា។

ទាក់ទងទៅនឹងការលើកឡើងរបស់ដើមបណ្ដឹង មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនដែលថាការលើកជំទាស់របស់មេធាវីការពារ គឺធ្វើឡើងដើម្បីបង្អន់ពេលវេលា។ ខ្ញុំថា នេះជាការលើកឡើងមួយអាចជាការភ័ន្តច្រឡំធ្ងន់ធ្ងរមែនទែន ពីព្រោះថា សវនាការបែបនេះគឺច្បាស់ជាត្រូវចំណាយពេលវេលាហើយ នេះជារឿងធម្មតា។ ដោយឡែកទៀត សម្រាប់ភស្តុតាង ឯកសារ ដែលមានច្រើនរហូតដល់រាប់ពាន់ឯកសារ គឺការខាតបង់ពេលវេលា គឺប្រាកដជាកើតមានឡើងជាមិនខាន។ អ៊ីចឹងសួរថា តើធ្វើយ៉ាងម៉េចទៅដើម្បីកុំឲ្យខាតពេលវេលា? អាចធ្វើបានទេ? ការបាត់បង់ពេលវេលា ទីមួយវាត្រូវតែមានហើយត្រូវតែកើតឡើងហើយ ក៏ប៉ុន្តែប្រហែលជាចំណុចមួយថា តើធ្វើយ៉ាងម៉េចកុំឲ្យខាតពេលវេលាច្រើនពេក។ អានេះជាចំណុចដែលៗក្រុមប្រឹក្សាជំនុំជម្រះអាចពិនិត្យបាន មិនមែនមានន័យថា សវនាការមួយត្រូវធ្វើឡើងដោយមិនឲ្យបាត់បង់ពេលវេលានោះទេ។

[១១:៤០:២៥]

អ៊ីចឹងសួរថា ដើម្បីពិនិត្យកុំឲ្យខាតពេលវេលាច្រើន តើចំណុចអីខ្លះដែលសហព្រះរាជអាជ្ញាអាចផ្ដល់បាន អាចធ្វើវិភាគទានបាន? ទីមួយ យើងពិនិត្យទៅលើភស្តុតាង ឬក៏ឯកសារទាំងឡាយដែលសហព្រះរាជអាជ្ញាដាក់។ ដូច-- ខ្ញុំសូមបញ្ជាក់សាឡើងវិញចំពោះវិធាន៨៧(១) នេះហើយថា "ភាគីមានសិទ្ធិដាក់ឯកសារទាំងអស់ ហើយឯកសារជាភស្តុតាងអីទាំងអស់ហ្នឹង គឺត្រូវតែទទួលយក" អ៊ីចឹងបានន័យថា ឯកសារយ៉ាងម៉េចក៏ដោយឲ្យតែដាក់ចូលមក គឺតុលាការទទួលយក លើកលែងតែមានការសម្រេចផ្ទុយផ្សេងទៀត ដូចនៅក្នុងកថាខណ្ឌខាងក្រោយបន្ទាប់មកទៀតនៅក្នុងវិធានដដែលនេះ។

អ៊ីចឹងទីមួយដាក់ចូលមកត្រូវតែទទួលយក បើសិនជាដាក់ចូលមកយកៗ អ៊ីចឹងភស្តុតាងវាមានច្រើនណាស់ ឯកសារវាមានច្រើនណាស់ ពីព្រោះដាក់យកៗទទួលយកទាំងអស់។ អ៊ីចឹងដើម្បីបញ្ជាក់ថាឯកសារទាំងអស់នោះ វាមានប្រយោជន៍រឿងក្ដី សម្រាប់ជាពិសេសសម្រាប់ការដាក់បន្ទុក ដោយសារ

ការងារដាក់បង្ហាញភស្តុតាង វាជាការងាររបស់សហព្រះរាជអាជ្ញា។ ដូច្នេះត្រូវពិនិត្យទៅលើ តើភស្តុតាងណាខ្លះដែលមានប្រយោជន៍សម្រាប់ដាក់បន្ទុកនោះ? ព្រះរាជអាជ្ញាអាចលើកយកមកធ្វើការគូសបញ្ជាក់ថា នៃអាឯកសារប្រភេទនេះ គឺសម្រាប់ដាក់បន្ទុក ដាក់បន្ទុកទៅលើផ្នែកអីមួយ។ ឧទាហរណ៍យើងពិនិត្យទៅលើធាតុផ្សំនៃបទល្មើសហ្នឹងទៅថា មានភស្តុតាងណាសម្រាប់អាណាអីចឹងទៅ។

[១១:៤១:៥៨]

ក៏ប៉ុន្តែបើសិនជា ការដាក់ចូលមកនៃឯកសារ ៗខ្លះជាឯកសារដែលមិនជាប់ពាក់ព័ន្ធ ឯកសារខ្លះជាឯកសារដែលមិនគួរឲ្យជឿបាន ឯកសារខ្លះជាឯកសារគ្មានប្រភពច្បាស់លាស់ ឯកសារខ្លះជាឯកសារដែលគ្មានឯកសារដើម ឯកសារខ្លះវាគ្រាន់តែជាពាក្យចចាមអារាមសម្ដីថ្លែងការណ៍ដែលមិនយកជាការកើត។ កាលណាបើយើងដាក់បញ្ចូលឯកសារគ្រប់យ៉ាងចូលមកទាំងអស់ អាហ្នឹងហើយធ្វើឲ្យពេលវេលារបស់យើងកាន់តែខាត ហើយប៉ះពាល់ ធ្វើឲ្យយើងមានការអូសបន្លាយពេលវេលាកាន់តែច្រើន។ អីចឹង ការកំណត់ទៅលើភស្តុតាង ដែលសហព្រះរាជអាជ្ញាលើក វាជាការចាំបាច់ដើម្បីជួយបង្កើនពេលវេលាសវនាការនេះឲ្យបានលឿន។

[១១:៤២:៥៥]

ខ្ញុំសូមដកស្រង់នូវចំណុចដ៏ខ្លីមួយពីរឿងក្ដីនៅក្នុងសាលាដំបូងលេខបី នៃតុលាការ អាយ.ស៊ី.ធី.វ៉ាយ តុលាការអន្តរជាតិយូហ្គោស្លាវី ក្នុងករណីលោក *ប្រលីក*។ *ប្រលីក* សរសេរអក្សរ “P-R-L-I-C” ក្នុងអត្ថបទនេះខ្ញុំបាទអានជាភាសាអង់គ្លេស ពីព្រោះជាសម្ដីដកស្រង់៖ ដើម្បីចៀសវាងការអានខុសឬការ បកប្រែខុស។

(អានជាភាសាអង់គ្លេស៖)“ការទទួលយកឯកសាររាប់ពាន់ឯកសារមុនពេលការពិភាក្សានៅក្នុងតុលាការនោះ វាអាចធ្វើឲ្យមានការពន្យារកិច្ចដំណើរការនីតិវិធី។ វិសាលភាពដែលថាអង្គជំនុំជម្រះសាលាដំបូងមិនមានផលប្រយោជន៍នៅក្នុងការពន្យល់ពីសាក្សីនានា ដែលត្រូវដាក់ឯកសារទាំងអស់នេះនៅក្នុងបរិបទរបស់ខ្លួន ហើយបង្ហាញអំពីភាពពាក់ព័ន្ធនៃឯកសារទាំងអស់នោះ និងតម្លៃនៃភស្តុតាងនៃឯកសារទាំងអស់នោះ។ អង្គជំនុំជម្រះទាមទារឲ្យចំណាយធនធានរបស់ខ្លួនឲ្យបានច្រើន ដើម្បីធ្វើការពិនិត្យ និងវាយតម្លៃទៅលើឯកសាររាប់ពាន់ទាំងអស់នោះ។ យើងអាចចំណាយពេលជាច្រើនខែ ហើយនិងអាចមានការពន្យារពេលនៃការប្រកាសសាលក្រម”។ (បញ្ចប់ការអានជាភាសាអង់គ្លេស)

[១១:៤៥:០៧]

តុលាការនេះបានសន្និដ្ឋានបន្ថែមទៀតថា ខ្ញុំសូមអានជាភាសាអង់គ្លេស។

(អានជាភាសាអង់គ្លេស៖) 'អយ្យការត្រូវមានកាតព្វកិច្ចក្នុងការធ្វើការជ្រើសរើស ហើយកំណត់អត្តសញ្ញាណឯកសារទាំងអស់នោះ ដែលមានភាពចាំបាច់បំផុតក្នុងការសម្រេចនៃ-- លើចំណុចជាក់លាក់។ ហើយត្រូវបង្ហាញឯកសារទាំងអស់នោះទៅដល់សាក្សី ដែលអាចផ្តល់ជូនអង្គជំនុំជម្រះនូវព័ត៌មានទាំងឡាយដែលមាននៅក្នុងតុលាការអំពីយថាភាព ភាពពាក់ព័ន្ធ និងតម្លៃជាភស្តុតាងនៃឯកសារទាំងអស់នោះ។ សូមអរគុណ។ (បញ្ចប់ការអានជាភាសាអង់គ្លេស)

ដូច្នេះ តាមខ្លឹមសារនេះ គឺថាព្រះរាជអាជ្ញា មានភារកិច្ចដើម្បីកំណត់ពីផលប្រយោជន៍នៃឯកសារឬក៏ភស្តុតាងដែលលោកនឹងលើកយកមកបង្ហាញ។ ថាបើសិនជាលោកដាក់ចូលមកដូចនៅក្នុងវិធាន ៨៧(១) ដែលថាឯកសារអីក៏ដាក់ចូលបាននោះ គឺធ្វើឲ្យឯកសារវាមានចំនួនច្រើន ហើយការកំណត់យកឯកសារណាមួយជាក់លាក់នោះ វាធ្វើឲ្យមានភាពមិនច្បាស់លាស់។

[១១:៤៦:៥០]

អ៊ីចឹងចៀសវាងកុំឲ្យមានការចំណាយពេលវេលាច្រើន ការកំណត់ទៅលើភស្តុតាងដែលចាំបាច់សម្រាប់ប្រើប្រាស់របស់សហព្រះរាជអាជ្ញា ជាពិសេសគឺភស្តុតាងសម្រាប់ដាក់បន្ទុក វាធ្វើឲ្យចំណេញពេលវេលា។ អ៊ីចឹងការខាត ឬចំណេញពេលវេលាមិនមែនអាស្រ័យទៅលើមេធាវីការពារទេ មិនមែនក្រុមការពារទេ។ នេះទៅលើការចោទប្រកាន់ បើសិនជាមានភស្តុតាងច្បាស់លាស់ពិតប្រាកដ មិនមែនមានន័យថា មេធាវីការពារត្រូវរំខាន ធ្វើឲ្យហិនហោចនូវពេលវេលាដ៏មានតម្លៃរបស់ក្រុមប្រឹក្សាជំនុំជម្រះនោះទេ។

[១១:៤៧:៤៧]

ទាក់ទងទៅនឹងគោលការណ៍នៃការកំណត់ជាលក្ខណៈទូទៅ ថាតើយើងគួរកំណត់យកភស្តុតាងដោយរបៀបណា? ខ្ញុំបានស្តាប់លោកមេធាវី ម៉ៃខល កាណាវាស ក៏បានលើកពីចំណុចបីសំខាន់ៗ ទាក់ទងទៅនឹងយថាភាពចំណុចទីមួយ។ ទីពីរទាក់ទងនឹងថា តើភស្តុតាងគួរឲ្យជឿបានប៉ុនណា? និងទីបី ថាតើភស្តុតាងនោះពាក់ព័ន្ធប៉ុនណា? នេះជាគោលការណ៍ ដែលសម្រាប់ក្រុមប្រឹក្សាជំនុំជម្រះធ្វើការវាយតម្លៃ សម្រាប់ជាលក្ខខណ្ឌក្នុងការដេញដោល ពីព្រោះថាភស្តុតាងទាំងអស់ ខាងមេធាវីការពារយើងខ្ញុំនេះ មិនមែនបដិសេធថា រាល់ភស្តុតាងដែលសហព្រះរាជអាជ្ញាដាក់មក សុទ្ធតែជាភស្តុតាងដែលមិន

បានការ ឬភស្តុតាងគ្មានប្រយោជន៍សម្រាប់រឿងក្តីនោះទេ។ ក៏ប៉ុន្តែវាទាមទារឲ្យមានការពិនិត្យទៅលើភាពជឿជាក់ទៅលើយថាភាព ទៅលើភាពពាក់ព័ន្ធនៃភស្តុតាងទាំងអស់នោះ។ យើងមិនអាចកំណត់ថាភស្តុតាងមួយ ដែលបានដាក់ចូលមក ត្រូវយកជាការបានទាំងស្រុងទេ។ ម្យ៉ាងទៀត ការកត់សម្គាល់របស់ក្រុមប្រឹក្សាជំនុំជម្រះ ដែលថាភស្តុតាងដែលដាក់ជូនត្រូវ-- អាចសន្មតជាមុនថាទទួលយកបាន ដែលមាន ភស្តុតាងដែលមាននៅក្នុង *ហ្វូតណូត* នៅក្នុងជើងរឹមទំព័រ គឺអាចទទួលយកបាន។

[១១:៤៩:៤៩]

ចំណុចនេះ វាអាចធ្វើឲ្យមានការយល់ច្រឡំមួយដែរ ថាតើយើងទទួលយកបានក្នុងកម្រិតណា? ទទួលយកបានទៅលើភស្តុតាងទាំងស្រុង នៅក្នុងរឹមទំព័រទាំងអស់ ឯកសារទាំងអស់ ឬក៏ទទួលយកបានចំពោះព័ត៌មានដែលមាននៅក្នុងរឹមទំព័រ ឬជើងទំព័រនោះ ក្នុង *ហ្វូតណូត*នោះ។ នៅពេលដែលសហចៅក្រមស៊ើបអង្កេត បានចេញដីកាដំណោះស្រាយ ហើយក៏បានសរសេរនៅក្នុងជើងទំព័រអំពីព័ត៌មានមួយចំនួន ដើម្បីគាំទ្រទៅលើសេចក្តីថ្លែង ឬក៏ការអះអាង ការកំណត់នានា សេចក្តីសម្រេចនានារបស់លោកជាការកំណត់បែបសង្ខេប។ ឧទាហរណ៍ គ្រាន់តែបង្ហាញនូវឈ្មោះអត្ថបទ ឈ្មោះទីតាំង អត្ថបទទំព័រណា? ឬក៏លេខណា? សៀវភៅណា? អ្នកនិពន្ធណា? ឯកសារណា? អ៊ីចឹងវាជាលក្ខណៈសង្ខេបអំពីអត្តសញ្ញាណអត្ថបទ មិនមែនជាខ្លឹមសារសរុបដែលមាននៅក្នុងអត្ថបទទាំងស្រុងទេ។

[១១:៥១:០៩]

ហើយម្យ៉ាងទៀត អ្វីដែលជាចំណោទនោះថា ខ្លឹមសារនៅក្នុងអត្ថបទនីមួយៗមិនមែនស៊ីសង្វាក់គ្នាទាំងអស់ទេ នេះជាចំណុចដែលយើងគួរពិចារណាផងដែរ។ នៅក្នុងឯកសារមួយ វាអាចមានចំណុចខ្វែងគ្នា វាអាចមានចំណុចទាស់គ្នា មិនស្របគ្នា ឬក៏មិន-- វាមានជាចំណោទ។ អ៊ីចឹងសួរថា ការទទួលយកនូវឯកសារទាំងអស់នេះ ធ្វើជាបានការ អាចយកបានក្នុងកម្រិតណាកើត? បើនៅក្នុងឯកសារតែមួយមានចំណុចខ្វែងគ្នាដូច្នេះ។ អ៊ីចឹងហើយបានទាមទារឲ្យមានការពិភាក្សាដេញដោល ដើម្បីស្វែងរកចំណុចដែលយកជាការបាន និងចំណុចដែលមិនអាចយកជាការបាន។ ទោះបីអត្ថបទនោះ កើតឡើងពីសំណេររបស់ម្ចាស់ដើម ឬក៏ជាសំណេររបស់អ្នកនិពន្ធក្តី ជាឯកសារណាក៏ដោយ ព្រោះអ្នកសរសេរទាំងអស់នោះក៏ជាមនុស្ស ហើយការដែលអាចធ្វើខុសនេះជាយថាហេតុ គឺប្រាកដជាអាចមាន មិនអាចថាយើងធ្វើត្រឹមត្រូវបានទាំងស្រុងទេ។

[១១:៥២:៤១]

ចំណុចមួយទៀត ដែលខ្ញុំសូមលើកបញ្ជាក់ទៅលើបន្ទុកនៃការបង្ហាញភស្តុតាងនេះដែរ បើសិនជាយើងយល់ថារាល់ភស្តុតាងទាំងអស់ដែលដាក់ចូលមកក្នុងតុលាការនេះ អាចយកជាការបាន ដោយមិនចាំបាច់ដេញដោល ដោយមិនឆ្លងកាត់ការដេញដោល វាធ្វើឱ្យប៉ះពាល់ទៅដល់ការស្វែងរកការពិតពីព្រោះការកំណត់ភស្តុតាង មិនមែនមានន័យថា នៅពេលដែលភាគីដាក់ចូលមកសុទ្ធតែជាការពិតទាំងអស់ទេ។ អ៊ីចឹងធ្វើម៉េចដើម្បីស្វែងរកការពិតបាន ក៏ត្រូវឆ្លងកាត់ការដេញដោលដូចគ្នា។ អ៊ីចឹងការដេញដោលនេះ វាជាផ្នែកមួយធ្វើឱ្យភាគីដែលជាប់ពាក់ព័ន្ធនេះទទួលយល់ស្រប ឬក៏បដិសេធ ហើយដែលចុងក្រោយក្រុមប្រឹក្សាជំនុំជម្រះអាចពិនិត្យថា តើការបដិសេធនេះវាមានហេតុផលត្រឹមត្រូវ ឬក៏ការយល់ស្របនេះ វាកើតឡើងដោយសារអ្វីមួយ?

[១១:៥៣:៥៣]

អ៊ីចឹងមិនមែនមានន័យថា ការយល់ស្របទាំងអស់សុទ្ធតែបានការទេ នេះចំណុចមួយដែរ។ ប៉ុន្តែវាភាគច្រើន បើសិនជាភាគីទាំងអស់យល់ស្របទៅលើអង្គហេតុណាមួយ ទៅលើភស្តុតាងណាមួយ អានេះវាធ្វើឱ្យក្រុមប្រឹក្សាជំនុំជម្រះ ងាយស្រួលពិចារណាដើម្បីធ្វើសេចក្តីសម្រេច។ ក៏ប៉ុន្តែបើមានភាគីម្ខាងយល់ថា វាជាភស្តុតាងពិត ភាគីម្ខាងទៀតយល់ថាមិនពិត ជាភស្តុតាងក្លែងក្លាយ ឬក៏មិនអាចយកជាការបាន។ អ៊ីចឹងធ្លាក់ទៅលើថៅក្រមក្រុមប្រឹក្សាជំនុំជម្រះជាអ្នកសម្រេចវិញដដែល។

[១១:៥៤:៤២]

មួយទៀត ទាក់ទងទៅនឹងវិធាន៨៧(១) នេះដែរ បើសិនជាយើងយល់ថា រាល់ភស្តុតាងដែលដាក់បញ្ចូលនេះ-- បើសិនជាផ្តល់ឱ្យមេធាវីការពារជាអ្នកបង្ហាញចំពោះរាល់ភស្តុតាងទាំងអស់ ដែលសហព្រះរាជអាជ្ញាលើកឡើងមកនូវចំណុចដែលខ្លួនជំទាស់នោះ វាហាក់ដូចជាប្តូរការទទួលខុសត្រូវក្នុងការបង្ហាញភស្តុតាងរបស់សហព្រះរាជអាជ្ញា ពីព្រោះថាសហព្រះរាជអាជ្ញា គាត់មានបន្ទុកបង្ហាញភស្តុតាង។ ក៏ប៉ុន្តែនៅពេលដែលគាត់ដាក់ចូលនូវឯកសារណាមួយ ហើយបែរជាភារកិច្ចនោះឱ្យមេធាវីការពារបង្ហាញថាតើភស្តុតាងទាំងអស់នោះ លោកជំទាស់ហ្នឹង មានជំទាស់ដោយសារអី? ជំទាស់ហេតុអីបានត្រូវបានជំទាស់ ឬមួយត្រូវបង្ហាញពីភាពជឿជាក់បាន បង្ហាញពីយថាភាព បង្ហាញពីភាពពាក់ព័ន្ធនៃឯកសារនោះ។ អ៊ីចឹងវាធ្វើឱ្យបន្ទុកនៃការបង្ហាញភស្តុតាងហ្នឹង មិនមែនស្ថិតនៅលើសហព្រះរាជអាជ្ញាទេ គឺវាធ្លាក់មកលើមេធាវីការពារវិញ។ អ៊ីចឹងយើងមើលឃើញថា ជារួមហាក់ដូចជាសហព្រះរាជអាជ្ញាយល់ឃើញថាបន្ទុកនៃការបង្ហាញភស្តុតាង គឺជាបន្ទុករបស់លោក ក៏ប៉ុន្តែដល់តែ

ពេលពិនិត្យទៅលើភស្តុតាងនីមួយៗវិញ បើសិនជាចង់បង្ហាញថាវាជាប់ពាក់ព័ន្ធ ឬក៏យកជាការបាន ឬយ៉ាងម៉េចនោះ បែរជាឱ្យមេធាវីការពារអ្នកបង្ហាញ អានេះជារឿងមិនត្រឹមត្រូវទេ។

[១១:៥៦:៤១]

ពីព្រោះជាគោលការណ៍រួម កាលណាព្រះរាជអាជ្ញា លោកមានបន្ទុកបង្ហាញភស្តុតាង អ៊ីចឹង ឯកសារទាំងឡាយដែលចាត់ទុកថាជាភស្តុតាងដែលលោកបានដាក់ចូលនោះ ក៏លោកត្រូវបង្ហាញពីភាពគួរឱ្យជឿជាក់បាន ពីភាពពាក់ព័ន្ធទាំងឡាយនោះផងដែរ។ ដើម្បីអី? ពីព្រោះវាមានគោលការណ៍រួមធំមួយទៀតសម្រាប់តម្រូវឱ្យសហព្រះរាជអាជ្ញាទទួលបន្ទុកបង្ហាញភស្តុតាងនេះ គឺគោលការណ៍អ្វី? គឺគោលការណ៍សន្មតជាមុនថាគ្មានទោស ពីព្រោះជនជាប់ចោទ យើងទទួលស្គាល់ថា ក្នុងច្បាប់យើងទទួលស្គាល់ថា គាត់គ្មានទោសទេរហូតមកដល់ពេលនេះ ឥឡូវនេះ លុះណាតែសាលក្រមត្រូវបានសម្រេចជាស្ថាពរ។

[១១:៥៧:៤៤]

អ៊ីចឹងបើគាត់គ្មានទោស ព្រះរាជអាជ្ញាត្រូវបង្ហាញពីពិរុទ្ធភាព ថាគាត់បានធ្វើខុសអី? អានេះហើយជាចំណុច ជាគោលការណ៍ធំ ដែលតម្រូវឱ្យសហព្រះរាជអាជ្ញាត្រូវតែបង្ហាញភស្តុតាង មិនមែនមានន័យថា ការបង្ហាញភស្តុតាង គាត់បង្ហាញភស្តុតាងមួយ ប៉ុន្តែដល់តែពេលខ្លឹមសារនៃភស្តុតាងហ្នឹង គាត់មិនចាំបាច់បង្ហាញ គាត់គ្រាន់តែដាក់ចូលមក អាហ្នឹងស្រាប់តែ អូ៎! ភស្តុតាងហ្នឹងយកជាការបានហើយ។ មិនមែនអ៊ីចឹងទេ។ គេត្រូវបង្ហាញពីភាពជឿជាក់ ពីយថាភាព ត្រូវបង្ហាញពីភាពជាប់ពាក់ព័ន្ធនៃភស្តុតាងនោះ ដូចការបង្ហាញលើធាតុផ្សំបទល្មើសដទៃទៀតអ៊ីចឹងដែរ ព្រោះជាបន្ទុករបស់គាត់។

[១១:៥៨:៣៦]

អ៊ីចឹងសរុបសេចក្តីមកវិញ ខ្ញុំបាទសូមបញ្ជាក់ថាក្នុងមាត្រា-- ក្នុងវិធាន៧៨(១)នេះ ការទទួលយកនៃភស្តុតាងមិនមែនមានន័យថា ការទទួលជាបានការនៃភស្តុតាងនោះទេ។ ភស្តុតាងដែលអាចទទួលយកជាការបាន វាត្រូវតែឆ្លងកាត់ការដេញដោលរបស់ភាគីទាំងសងខាង ដើម្បីបញ្ជាក់អំពីយថាភាព បញ្ជាក់អំពីភាពដែលអាចឱ្យជឿបាន បញ្ជាក់អំពីភាពជាប់ពាក់ព័ន្ធរបស់ភស្តុតាងចំពោះរឿងក្តីនេះ។

ខ្ញុំបាទក្នុងនាមមេធាវីការពារ សូមបញ្ជាក់នូវជំហរថា យើងនឹងធ្វើការជំទាស់បើសិនជាភស្តុតាងទាំងឡាយណាដែលយកមកធ្វើការ-- ដែលមិនបានយកមកធ្វើការដេញដោល ហើយក្រុមប្រឹក្សាជំនុំ

ជម្រះផ្អែកលើភស្តុតាងទាំងអស់នោះ ដោយចាត់ទុកថាភស្តុតាងទាំងអស់នោះបានការរាល់គ្រប់នីតិវិធីទាំងអស់។

[១២:០០:០៣]

ដូច្នេះ ជាសំណូមពរចុងក្រោយគឺ សុំក្រុមប្រឹក្សាជំនុំជម្រះកុំពិចារណាទៅលើ-- កុំពិចារណា កុំយកជាការចំពោះភស្តុតាងទាំងឡាយណា ដែលមិនបានដេញដោលដោយភាគី។ ពីព្រោះថាភស្តុតាងទាំងអស់នោះ នឹងមិនមានយថាភាព ឬក៏មិនអាចគួរឲ្យជឿបាន និងមិនអាចជាប់ពាក់ព័ន្ធក្នុងរឿងក្ដីនេះ។ ដូច្នេះ ក្រុមប្រឹក្សាជំនុំជម្រះមិនត្រូវយកភស្តុតាងដែលមិនបានដេញដោលនេះ ទៅធ្វើការជាសំអាងសម្រាប់ធ្វើសេចក្ដីសម្រេចនោះទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវីដែលបានធ្វើការកត់សម្គាល់បញ្ហាទូទៅស្ដីពីភស្តុតាងនេះ ហើយដោយសារមេធាវីចុងក្រោយនេះ បានសង្កត់ធ្ងន់ដដែលៗអំពីការដែលសេចក្ដីសម្រេចដោយទទួលយកភស្តុតាង ឯកសារភស្តុតាងដែលដាក់ដោយភាគី ដោយមិនឆ្លងកាត់ការដេញដោល ហើយប្រហែលជាលោកមេធាវីបានមើលរំលងនូវបទប្បញ្ញត្តិដែលមានចែងនៅក្នុងវិធាន៨៧(២)។

អ៊ីចឹង អង្គជំនុំជម្រះសូមអាននូវខ្លឹមសារនេះ ដើម្បីឲ្យមេធាវីបានយល់កាន់តែច្បាស់លាស់ថែមទៀត។ វិធាន៨៧(២) នៃវិធានផ្ទៃក្នុងចែងថា "សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវផ្អែកលើភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយដែលភស្តុតាងនោះត្រូវឆ្លងកាត់ការដេញដោល"។ ឃ្លាពាក្យពេចន៍ដែលមានចែងនៅក្នុងវិធាន៨៧ អនុវិធាន២ ដែលលោកមេធាវីបានមើលរំលង ឬក៏មិនបានពិនិត្យលើបញ្ហានេះ។ ទំនងជាអាចបកស្រាយជាក់ច្បាស់ហើយ លើហេតុផលទាំងឡាយនៃសំអាងហេតុមុននឹងឈានដល់សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ។

[១២:០២:១៩]

ហើយដោយសារមានបញ្ហាមួយកាលពីព្រឹកមិញ ដែលមេធាវីការពារក្ដីលោក ខៀវ សំផន មានបំណងស្នើសុំឲ្យ លោក ខៀវ សំផន ឡើងបង្ហាញជំហររបស់គាត់នៅក្នុងការប្រើសិទ្ធិរបស់គាត់ សិទ្ធិនៅស្ងៀមមិនឆ្លើយតប ឬក៏សិទ្ធិក្នុងការឆ្លើយតបដោះសាពាក់ព័ន្ធទៅនឹងអង្គហេតុនានា ដោយបញ្ហាពីរ។ ទីមួយ គឺបញ្ហានេះ អង្គជំនុំជម្រះបានសួរទៅជនជាប់ចោទ ខៀវ សំផន កាលពីសប្ដាហ៍កន្លងទៅ ហើយគាត់ទុកលទ្ធភាពក្នុងការប្រឹក្សាយោបល់ជាមួយនឹងមេធាវីជាមុនសិន។ ហើយអម្បាញ់មិញនេះ មេធាវី

បានស្នើសុំផង ហើយបញ្ហានេះ បើសិនបើយើងទុកយូរទៀត អាចភ្លេច ឬក៏អាចនាំឲ្យប៉ះពាល់ដល់ភាគីដទៃទៀត នៅក្នុងការត្រៀមរៀបចំនូវកិច្ចដំណើរការសម្រាប់ចូលរួមពិភាក្សាដេញដោលសម្រាប់អង្គហេតុដែលពាក់ព័ន្ធ។

[១២:០៣:២៤]

ដូច្នេះ ដើម្បីឲ្យចង់បាន-- ឲ្យអង្គជំនុំជម្រះ និងភាគីដទៃទៀតបានយល់ច្បាស់លាស់អំពីបញ្ហានេះ អនុរក្សមន្ទីរឃុំឃាំងនាំលោក ខៀវ សំផន មកកាន់ឈើរាងវង់ក្រចកសេះ នៅចំពោះមុខអង្គជំនុំជម្រះនេះ ដើម្បីឲ្យគាត់បង្ហាញជំហរឲ្យជាក់ច្បាស់អំពីការគាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ឬក៏គាត់អនុវត្តនូវសិទ្ធិរបស់គាត់ក្នុងការតតាំងក្តី។

សូមអញ្ជើញមេធាវី!

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន។ ខ្ញុំបាទដើម្បីធ្វើកំណត់ត្រានេះឲ្យបានត្រឹមត្រូវ នូវការលើក*ខ្លួត*អម្បាញ់មិញ ដែលខ្ញុំបានលើកឡើងនេះ ខ្ញុំបាទសូមជម្រាបជូនចំណងជើងអត្ថបទដែលមានឈ្មោះថា *"ឌីស៊ីសិន អន អែតមីសិន អោស អេវិតដេន"* (និយាយភាសាអង់គ្លេស) អង្គសវនាការលេខបី អង្គជំនុំជម្រះលេខបី ឬក៏សាលាដំបូងលេខបី ចុះថ្ងៃទី១៣ ខែ៧ ឆ្នាំ២០០៦ ត្រង់ទំព័រប្រាំមួយ និងទំព័រប្រាំពីរ។ សូមអរគុណ។

[១២:០៤:៤៨]

**ប្រធានអង្គជំនុំ៖**

លោក ខៀវ សំផន កាលពីចុងសវនាការកាលពីសប្តាហ៍មុន ខាងសហព្រះរាជអាជ្ញាអន្តរជាតិបានស្នើមកអង្គជំនុំជម្រះឲ្យសាកសួរទៅលោកនៅក្នុងការប្រកាន់ជំហររបស់លោក ក្នុងការរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ឬក៏ប្រើសិទ្ធិរបស់លោកក្នុងការឆ្លើយតបទៅនឹងកិច្ចពិភាក្សាដេញដោល ដែលនឹងធ្វើឡើងដោយនៃអង្គជំនុំជម្រះ និងភាគី ដែលសំណួរនោះ គឺបំណងសួរទៅដល់អង្គហេតុនូវវគ្គទីពីរ ដែលអង្គជំនុំជម្រះគ្រោងនឹងធ្វើបន្តពីអង្គហេតុវគ្គទីមួយ ស្តីពីប្រវត្តិសាស្ត្របក្សកុម្មុយនីស្តកម្ពុជា។ គឺអង្គហេតុទីពីរនោះ គឺអង្គហេតុស្តីពីរចនាសម្ព័ន្ធរដ្ឋបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ តើលោកប្រកាន់ជំហរយ៉ាងដូចម្តេចដែរ អំពីបញ្ហានេះ ក្រោយពីបានពិភាក្សា ពិគ្រោះយោបល់គ្នាជាមួយនឹងមេធាវីរបស់លោក?

សូមអញ្ជើញ!

[១២:០៦:០៦]

**លោក ខៀវ សំផន៖**

លោកប្រធាន លោកស្រី អស់លោកចៅក្រម។ លោកស្រី អស់លោកទាំងអស់ដែលមានមុខនៅទីនេះ។ សូមក្រាបថ្វាយបង្គំព្រះសង្ឃគ្រប់ព្រះអង្គ សូមបងប្អូនរួមជាតិជាទីគោរពស្នេហា។

ខ្ញុំសូមអរគុណលោកប្រធាន ដែលបានអនុញ្ញាតឲ្យខ្ញុំនិយាយ។ ខ្ញុំមានសំណូមពរនិយាយបន្តិចថែម អំពីសវនាការថ្ងៃព្រហស្បតិ៍មុន។ ខ្ញុំសង្កេតឃើញថា នៅមានអស់លោក អ្នកខ្លះមិនទាន់យល់ច្បាស់ អំពីគោលជំហររបស់ខ្ញុំ លើសសំណួរដែលអង្គជំនុំជម្រះ និងភាគីនានា ចង់សួរខ្ញុំនៅឡើយទេ។ កាលពីសវនាការថ្ងៃ១៣ ធ្នូ មុននេះ ខ្ញុំបានបញ្ជាក់ គោលជំហរខ្ញុំច្បាស់ហើយ។

[១២:០៧:៣៤]

ខ្ញុំយល់ឃើញថា គោលជំហរខ្ញុំនៅតែច្បាស់ដដែល។ ប៉ុន្តែខ្ញុំឃើញថា ខ្ញុំត្រូវបញ្ជាក់ឡើងវិញ ដើម្បីចៀសវាងកុំឲ្យមានការយល់ច្រឡំ។ ខ្ញុំបាននិយាយហើយ ខ្ញុំសូមនិយាយម្តងទៀត ថាខ្ញុំមានសំណូមពរចូលរួមយ៉ាងសកម្មក្នុងរឿងក្តីរបស់ខ្ញុំនេះ។ ប៉ុន្តែខ្ញុំមិនភ្លេចទេ ថានេះជារឿងក្តីកាត់ទោសខ្ញុំ។ សហព្រះរាជអាជ្ញាបានអះអាងថា ខ្ញុំបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរណាស់។ ចំណែកឯខ្ញុំៗ បដិសេធ។ គឺសហព្រះរាជអាជ្ញា ដែលត្រូវផ្តល់ភស្តុតាងគាំទ្រការអះអាង និងការចោទប្រកាន់របស់គាត់មកលើរូបខ្ញុំ ដើម្បីខ្ញុំអាចឆ្លើយការពារខ្លួន។ ដូច្នេះហើយបានជាខ្ញុំរង់ចាំពេលណាខ្ញុំទទួលភស្តុតាងសព្វគ្រប់ដែលត្រូវមាន ដែលត្រូវយកមកបង្ហាញខ្ញុំ ដើម្បីខ្ញុំពិនិត្យ មុននឹងខ្ញុំឆ្លើយជាយថាហេតុ ជំនួស ចំពោះសំណួរគ្រប់បែបយ៉ាងទាំងអស់។

[១២:០៩:១៧]

ជាក់ស្តែង ខ្ញុំមានសំណូមពរ សូមតុលាការផ្តល់ឱកាសឲ្យខ្ញុំធ្វើអត្ថាធិប្បាយ ហើយជម្រាបនូវទស្សនរបស់ខ្ញុំលើអង្គហេតុ ដែលមានលើកឡើងនៅក្នុងកថាខណ្ឌនៃដីកាដំណោះស្រាយ ដែលអង្គជំនុំជម្រះនឹងចង្អុលនៅពេលសវនាការតទៅមុខទៀតនេះ។ ដូចដែលតុលាការបានអនុញ្ញាតឲ្យខ្ញុំរួចមកហើយកាលពីថ្ងៃ១៣ ធ្នូ កន្លងទៅនេះ។ ជាការតបវិញ ខ្ញុំនឹងឆ្លើយតបជាយថាហេតុនឹងសំណួរ។ ជាសំណួរលើបញ្ហាផ្សេងៗដែលបានលើកឡើងក្តី ជាសំណួរលើឯកសារផ្សេងៗក្តី ប៉ុន្តែលុះត្រាណាតែភស្តុតាងផ្សេងៗត្រូវបានបង្ហាញអស់សព្វគ្រប់សិន ពីព្រោះឧទាហរណ៍ នៅពេលដែលការពិភាក្សាដេញដោលក្នុងផ្នែក

ទីមួយ លើកបរិបទប្រវត្តិសាស្ត្រ ជិតចប់ហើយក៏ដោយ មិនបានន័យថា ភស្តុតាងផ្សេងៗស្តីអំពីបរិបទប្រវត្តិសាស្ត្រ មិនត្រូវបានលើកឡើងថែមទៀតនៅពេលក្រោយៗនោះទេ។ បើតាមខ្ញុំយល់ សាក្សី និងអ្នកជំនាញការដែលនឹងមកឆ្លើយនៅពេលខាងមុខនេះ នឹងអាចត្រូវបានគេសួរលើបរិបទប្រវត្តិសាស្ត្រទៀត។ បើតាមខ្ញុំយល់ ឯកសារផ្សេងៗទៀតនឹងត្រូវបានបង្ហាញជាបន្តបន្ទាប់នៅពេលសវនាការខាងមុខនេះ ហើយនិងត្រូវបានជាកម្មវត្ថុ នៃការពិភាក្សាដេញដោលគ្នាទៀត។

(និយាយជាភាសាបារាំង៖) *"វ៉ែឡា ពួស៍រ ហ្សឺស្វ៍រអាត្រេ ស៊ី ហ្សឺស៊ី អូតូរីហ្សេ--* បើសិនជាមានការអនុញ្ញាតឲ្យខ្ញុំផ្តល់ធ្វើនូវការអធិប្បាយ ជាយថាហេតុមួយចំនួនលើកថាខណ្ឌ នៃដីកាដំណោះស្រាយជាបន្តបន្ទាប់នៅក្នុងដំណាក់កាលជំនុំជម្រះ ប៉ុន្តែខ្ញុំនឹងមិនឆ្លើយតបទៅនឹងសំណួរទោះបីជាសំណួរតាមលក្ខណៈណាក៏ដោយ មុននឹងពេលដែលយើងធ្វើការបញ្ចប់ក្នុងការបង្ហាញ នៃធាតុផ្សំនៃភស្តុតាង។ ម្យ៉ាងទៀតគឺថា នៅពេលដែលចប់ការជំនុំជម្រះហើយ"។ (បញ្ចប់ការនិយាយភាសាបារាំង)

សង្ឃឹមថា ឥឡូវនេះ ទាំងអស់គ្នាយល់គោលជំហររបស់ខ្ញុំច្បាស់ជាងមុនហើយ។

ខ្ញុំសូមអរគុណលោកប្រធាន លោកស្រី និងអស់លោកចៅក្រមទាំងអស់ចំពោះការយកចិត្តទុកដាក់របស់អស់លោក។ ខ្ញុំសូមចប់ត្រឹមហ្នឹង។

[១២:១៣:០៥]

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោក ខៀវ សំផន ដែលបានបង្ហាញនូវគោលជំហរច្បាស់លាស់ អំពីការចូលរួមក្នុងកិច្ចពិភាក្សាដេញដោលនៅក្នុងអង្គហេតុ ដែលមានការពាក់ព័ន្ធចោទប្រកាន់ចំពោះរូបលោក នៅក្នុងសំណុំរឿង០០២/០១ នេះ។ បញ្ហាទាំងអស់នេះមានកត់ត្រានៅក្នុងប្រតិចារឹកហើយ ហើយនិងភាគី និងអង្គជំនុំជម្រះនឹងយកបញ្ហាទាំងអស់នេះទៅពិនិត្យពិចារណា។ ហើយឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ចាប់ពីពេលនេះទៅ រហូតដល់ម៉ោងដប់មួយនឹងសាមសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ សូមអញ្ជើញ!

[១២:១៣:៥៨]

**លោក អេនគ្រូ អ៊ីនូហ្សី៖**

សូមអរគុណលោកប្រធាន។ ប្រសិនបើខ្ញុំអាចនោះ ខ្ញុំសូមលើកឡើងដោយសង្ខេបពីលោក នួន

ជា។ លោក នួន ជា សម្រេចបោះបង់សិទ្ធិមិនចូលរួមក្នុងសវនាការ អ៊ីចឹងបានន័យថា គាត់មិនចង់មកចូលរួមនៅក្នុងបន្ទប់សវនាការខាងក្រោមហ្នឹងទេ។ ដូច្នេះហើយ ខ្ញុំសូមបញ្ជាក់ឡើងវិញថា គាត់បោះបង់សិទ្ធិមិនចូលរួម ចង់នៅបន្ទប់ឃុំឃាំងរបស់គាត់ក្នុងពេញមួយសប្តាហ៍នេះតែម្តង។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញា!

**លោក វីល្លៀម ស្មីត៖**

សហព្រះរាជអាជ្ញាបានបញ្ជាក់ជំហររបស់យើងច្បាស់លាស់រួចមកហើយ ជូនអង្គជំនុំជម្រះសាលាដំបូងជនជាប់ចោទមានកាតព្វកិច្ច មានវត្តមានក្នុងសវនាការនេះ មិនថានៅក្នុងបន្ទប់នេះផ្ទាល់ ឬក៏នៅបន្ទប់រង់ចាំខាងក្រោម។ ដូច្នេះ ហើយយើងស្នើសុំឲ្យ អង្គជំនុំជម្រះច្រានចោលសំណើសុំពីខាងមេធាវីការពារក្តី។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១២:១៦:៤៨]

**ប្រធានអង្គជំនុំ៖**

ការដែលជនជាប់ចោទ នួន ជា តាមរយៈមេធាវីរបស់ខ្លួនស្នើសុំលះបង់សិទ្ធិមិនចូលរួមនៅក្នុងសវនាការនេះទាំងនៅក្នុងសាល-- បន្ទប់សវនាការផ្ទាល់ ក៏ដូចជានៅក្នុងបន្ទប់តាមដានសវនាការពីចម្ងាយពីប្រព័ន្ធសោតទស្សន៍ដោយសូមនៅឯមន្ទីរឃុំឃាំងនៃ អ.វ.ត.ក នោះ។ អង្គជំនុំជម្រះបដិសេធចោលនូវសំណើនេះ ហើយអង្គជំនុំជម្រះតម្កល់នូវសេចក្តីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូងដែលបានសម្រេចពីព្រឹកមិញរួចហើយ គឺគាត់អាចលះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់នៅបន្ទប់សវនាការនេះ ប៉ុន្តែជនជាប់ចោទត្រូវមកតាមដាននៅបន្ទប់ខាងក្រោម ដែលអង្គជំនុំជម្រះបានរៀបចំនូវប្រព័ន្ធសោតទស្សន៍ ដើម្បីគាត់មានការតាមដាននូវកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់នោះមក។ ហើយយើងបានបង្គាប់រួចហើយ ឲ្យផ្នែកសោតទស្សន៍បន្តប្រព័ន្ធសោតទស្សន៍រូបភាពសំឡេង ដើម្បីឲ្យគាត់មានឱកាសនៅក្នុងការតាមដាននូវកិច្ចដំណើរការសវនាការពីចម្ងាយ នោះគឺក្នុងពេញមួយសប្តាហ៍នេះ។ ដូច្នេះ អនុរក្សមន្ទីរឃុំឃាំងមិនបាច់នាំខ្លួនជនជាប់ចោទទាំងពីររូបនោះ ឡើងមកសាលសវនាការទេនៅរសៀលនេះ ឬក៏ពេញមួយសប្តាហ៍នេះ គឺនាំមកទីនោះគ្រាន់តែរាយការណ៍ អំពីព័ត៌មាននោះមកក្រឡាបញ្ជីសវនាការបានហើយ។

[១២:១៨:២៧]

អនុរក្សមន្ទីរឃុំឃាំងនាំ ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោម ហើយឲ្យនាំគាត់មកកាន់សាលសវនាការវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយ និងសាមសិបនាទី។

*(សវនាការសម្រាកពីម៉ោង ១២:១៩ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:២៩]

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ តទៅនេះអង្គជំនុំជម្រះនឹងស្ដាប់សេចក្ដីជំទាស់មេធាវីការពារក្ដីពាក់ព័ន្ធនឹងឯកសារ E3 មេធាវីការពារក្ដីមានពេលវេលាសរុបចំនួន ៣0នាទីសម្រាប់ការជំទាស់។ ប៉ុន្តែ អង្គជំនុំជម្រះសូមបញ្ជាក់ថា ក្រុមមេធាវីការពារក្ដីអាចបែងចែកពេលវេលារួម ៩0នាទីនេះ ទៅមេធាវីការពារក្ដីម្នាក់ៗតាមការគួរ។ តើមេធាវីអាចបញ្ជាក់បានទេថា មេធាវីបែងចែកពេលវេលា ៩0នាទីនេះយ៉ាងដូចម្ដេច? មេធាវី នួន ជា?

[១៣:៣៤:៤៧]

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំស្មានថា ខ្ញុំត្រូវការប្រហែលជា ២៥នាទីទេលោកប្រធាន សម្រាប់បទទឡ្ហីករណ៍របស់ខ្ញុំបាទ។ ៥នាទីទៀត ខ្ញុំនឹងជូនទៅភាគីការពារក្ដីណាមួយដែលចង់បានបាទ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ចុះលោកមេធាវីការពារក្ដី អៀង សារី?

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោក លោកស្រីចៅក្រម លោកប្រធាន ហើយនិងសមាជិកទាំងអស់ ហើយខ្ញុំអាចពិនិត្យមើលខ្លឹមសារប្រហែលជាសាបសិបនាទី ប្រសិនជាខ្ញុំត្រូវការ ខ្ញុំនឹងទទួលយកប្រាំនាទីដែលមេធាវី ផេសមិន នឹងវិភាគទានឲ្យ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណណាស់ អ៊ីចឹងឃើញថានៅសល់ប៉ុន្មានមេធាវីការពារ ខៀវ សំផន ហើយប្រហែលជា

ប្រហែលគ្នាងដែលទេ មិនខុសគ្នាប៉ុន្មានទេ។

អ៊ីចឹងជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅមេធាវីការពារក្តី នួន ជា ដើម្បីបង្ហាញអំពីសេចក្តីជំទាស់របស់ខ្លួនចំពោះឯកសារ E3។ សូមអញ្ជើញ!

[១៣:៣៦:០៥]

**លោក ហ្សាស្តើ ប៉ៅ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម! ហើយវត្តមានថ្ងៃនេះ ខ្ញុំសូមអរគុណណាស់ ខ្ញុំនឹងនិយាយអំពីការទទួលយកឯកសារ E13 (ស៊ីក) ប៉ុន្តែមុននឹងធ្វើដូច្នោះ ខ្ញុំនឹងបញ្ជាក់បញ្ហាមួយចំនួនអំពីសាក្សី សក្តានុពលដោយឈ្មោះមួយចំនួន ហើយខ្ញុំមើលប្រធានបទនេះ ជាមួយនឹងមន្ត្រីច្បាប់ជាន់ខ្ពស់នៃតុលាការ ហើយខ្ញុំនឹងសូមការអនុញ្ញាតដើម្បីបញ្ជាក់ឈ្មោះជាក់លាក់ពីរនាក់ ដែលថាលោកចៅក្រមក៏បានជ្រាបស្រាប់ហើយអំពីឈ្មោះពួកគាត់ដែលខ្ញុំនឹងលើកឡើង។ មុន ខ្ញុំសុំការណែនាំពីតុលាការមុននឹងខ្ញុំបន្ត។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៣៨:១៤]

**ប្រធានអង្គជំនុំ៖**

ក្រោយពីបានស្តាប់នូវសំណើសុំរបស់មេធាវីការពារក្តី នួន ជា ហើយក៏បានពិភាក្សានៅក្នុងចំណោមចៅក្រមនៃអង្គជំនុំជម្រះតុលាការដំបូង អង្គជំនុំជម្រះសូមជម្រាបដល់មេធាវីការពារក្តី នួន ជា ថា ជាទូទៅឈ្មោះសាក្សីដើមបណ្តឹងរដ្ឋប្បវេណី គឺមិនអនុញ្ញាតឱ្យប្រើឈ្មោះចំទេ គឺយើងបានមានបញ្ជីរួចហើយ គឺឱ្យប្រើរហស្សនាម។ ប៉ុន្តែដោយឡែកករណីនេះជា ករណីពិសេសដែលមានការពាក់ព័ន្ធទៅនឹងមជ្ឈមណ្ឌលឯកសារ ដែលមានការពាក់ព័ន្ធទៅនឹងការវាយតម្លៃផ្សេងៗ ពាក់ព័ន្ធនឹងឯកសារដែលមានយថាភាព ឬក៏ភាពអាចទទួលយកបាននៃឯកសារជាដើមនោះ គឺអង្គជំនុំជម្រះក្នុងករណីនេះអនុញ្ញាតជាពិសេស។

សូមអញ្ជើញ!

**លោក ហ្សាស្តើ ប៉ៅ៖**

សូមអរគុណប្រធានដែលបានបំភ្លឺដល់ខ្ញុំបាទ។ ថ្ងៃនេះយើងនឹងនិយាយមតិយោបល់មួយចំនួនអំពីភាពទទួលយកបាននៃឯកសារប្រភេទ E3។ ប៉ុន្តែដើម្បីឱ្យបំពេញតាមភាពពាក់ព័ន្ធជាបទដ្ឋានអប្បបរិមា

នោះ គឺយើងត្រូវ-- ជាកត្តាចាំបាច់ដែលយើងត្រូវស្តាប់សាក្សីមួយចំនួន។ ទីមួយ គឺលោក យុ ឆាំង ជាប្រធាននៃមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយក៏អង្គជំនុំជម្រះបានដឹងដែរថា បានកំណត់ថាឲ្យមានសាក្សីមកផ្តល់សក្ខីកម្មអំពីយថាភាពនៃឯកសាររបស់ ឌី.ស៊ី.ខេម នេះ ប៉ុន្តែជំហររបស់មេធាវីការពារក្តីក៏ចង់ឲ្យលោក យុ ឆាំង ខ្លួនឯងមកផ្តល់សក្ខីកម្ម។ បើសិនជាគាត់មិនមកធ្វើសក្ខីកម្មនោះទេ គឺជំហររបស់មេធាវីការពារក្តី ឯកសារទាំងអស់ដែលមកចេញពី ឌី.ស៊ី.ខេម នោះ គឺមិនអាចទទួលយកបានធ្វើជាភស្តុតាងនៅតុលាការនេះទេ។

ដូចដែលលោកចៅក្រមជ្រាបហើយ លោក យុ ឆាំង បានរៀបចំការងារមួយចំនួន ដែលតាំងពីឆ្នាំ១៩៩៥ ខែកក្កដា ជាពិសេស ហើយគាត់ដឹកនាំ ឌី.ស៊ី.ខេម នេះតាំងពីឆ្នាំ៩៧។ ការងារមួយចំនួនដែលថាជាពិសេសការងាររបស់គាត់ក្នុងការប្រមូលភស្តុតាងនោះ។

យុ ឆាំង បានបញ្ជាក់នៅក្នុងឱកាសមួយចំនួនថា មានតែគាត់ទេជាអ្នកបញ្ជាក់យថាភាពរបស់ឯកសារ ឌី.ស៊ី.ខេម ហើយជាបុគ្គលនោះ គាត់បង្ហាញយ៉ាងច្បាស់ថា នៅក្នុងឯកសារ D150 គាត់បាននិយាយថា ឯកសារ គ្រប់ឯកសារទាំងអស់ដែលដាក់ចូលមក ខ្ញុំពិនិត្យដោយបុគ្គល D209, 204 គាត់ក៏បានបញ្ជាក់ពីគំនិតដែរ។

[១៣:៤១:០៨]

សំណួរអ្វីខ្លះ ដែលអ្នកឯងសួរទៅអ្នកឲ្យឯកសារ? គាត់ឆ្លើយថា "ខ្ញុំសួរសំណួរដោយផ្ទាល់ខ្លួនទាក់ទងទៅនឹងកំណត់ត្រាឯកសារ។ ខ្ញុំបានឃើញ ហើយនិងគ្រប់គ្រងឯកសារទាំងអស់ក្នុងបណ្ណសាររបស់ ឌី.ស៊ី.ខេម ហើយខ្ញុំក៏បញ្ជាក់ពីការទទួលស្គាល់នោះដែរ"។ នេះជាមូលហេតុដែលយើងត្រូវតែស្តាប់សវនាការរបស់លោក ឆាំង យុ គឺមិនមានអ្នកណាផ្សេងខុសពីគាត់បានទេ។

រីឯការតាំងសំណួរទៅសាក្សីក៏សំខាន់ ប៉ុន្តែទោះជាក្នុងករណីណាក៏ដោយ ត្រូវតែ យុ ឆាំង មកទីនេះ។ ដោយសារថា គាត់ចូលពាក់ព័ន្ធយ៉ាងយូរនៅក្នុងការប្រមូលរៀបចំចងក្រងឯកសារនោះ គាត់បានចូលរួមក្នុងការទាក់ក្នុងបញ្ហាយថាភាពនៃឯកសារទាំងអស់ ដែលថាអាចនឹងកំណត់បានថាតើភស្តុតាងទាំងនោះអាចទទួលយកបាននៅទីនេះដែរឬទេ?

[១៣:៤២:០០]

រីឯភាគីផ្សេងៗទៀត គឺអាចនឹងសួរទៅ យុ ឆាំង អំពីបញ្ហានេះ។ ប៉ុន្តែ ទាក់ទងទៅនឹងយុត្តិសាស្ត្រនៃការប្រមូលឯកសារនេះ យើងត្រូវសួរ ថាតើគាត់បានផ្តល់វគ្គបណ្តុះបណ្តាលទេ ទាក់ទងទៅ

នឹងការប្រមូលឯកសារពីយថាភាពនេះ? ហើយយើងក៏សួរទៅគាត់ផងដែរ ថាតើវិធីសាស្ត្រគាត់ហ្នឹងមានអ្វីខ្លះ? បើសិនជាគាត់មិនបានប្រមូល ឬក៏បដិសេធនៅភស្តុតាងណាមួយដែលអ្នកផ្សេងឲ្យមកគាត់នោះ។

[១៣:៤២:២៦]

វាជាការពិតណាស់ដែលថា លោក ឆាំង យុ គឺថាទទួល ឬក៏ផ្តល់ការសម្ភាសជាច្រើនដងជាមួយការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យចៅក្រមស៊ើបអង្កេត ក៏ប៉ុន្តែមេធាវីការពារមិនដែលបានសួរសាក្សីដ៏សំខាន់នេះនៅឡើយទេ។ នេះហើយជាសិទ្ធិរបស់មេធាវីការពារក្នុងការចោទសួរសាក្សីដ៏សំខាន់ដូចលោក ឆាំង យុ នេះ។ ជាពិសេសទៅទៀតនៅក្នុងសេចក្តីថ្លែងការណ៍ទាំងអស់នោះ នៅក្នុងការិយាល័យសហព្រះរាជអាជ្ញា ហើយនៅសហចៅក្រមស៊ើបអង្កេតដែរនោះ ជាជាងផ្តល់ និងការបំភ្លឺទាំងមូលក្នុងការប្រមូលនូវព័ត៌មានទាំងអស់នោះ សេចក្តីថ្លែងការណ៍ទាំងអស់នោះបានលើកឡើងនូវជាបញ្ហាភស្តុតាងជាច្រើនទៀត ដែលមេធាវីការពារចង់បានការអនុញ្ញាត ដើម្បីពិនិត្យមើលបញ្ហាទាំងអស់នេះ នៅក្នុងតុលាការដោយចំហនៅក្នុងសវនាការ។

[១៣:៤៣:១៤]

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យមេធាវី គាត់បន្ថយល្បឿនបន្តិចបាទ ទាន!

**លោក ហ្សាស្តើ ប៉ោ៖**

ហើយទាក់ទងទៅនឹងបញ្ហានេះ ដែលលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍ទាំងអស់នោះ ដោយឆាំង យុ នោះ (ហើយខ្ញុំបានឃើញសញ្ញាថា ឲ្យពន្យឺតល្បឿនបន្តិច)។ អ៊ីចឹងខ្ញុំនឹងនិយាយឲ្យយឺតជាងនេះបាទ។ ទាក់ទងទៅនឹងការតាំងសំណួរ ហើយនិងពេលនិយាយពេលក្រោយទៀត។

ប៉ុន្តែបញ្ហាមួយដែលលើកឡើងនៅក្នុងការសួរសំណួរទៅ យុ ឆាំង ហ្នឹង ហើយយោងទៅរកឯកសារ D204/3 ហើយនៅក្នុងឯកសារនេះលោក យុ ឆាំង បាននិយាយថា បាននិយាយអំពីចំណារផ្ទាល់ដៃដែលបានធ្វើឡើងនៅក្នុងឯកសារមួយចំនួនដែលយកមកបានពីមន្ទីរឃុំឃាំងទួលស្លែង ហើយគាត់បានបញ្ជាក់។

[១៣:៤៤:០៤]

ខ្ញុំដកស្រង់៖ “ខ្ញុំសូមបញ្ជាក់ថា ចំណារផ្ទាល់ដៃតូចៗនៅលើឯកសារទួលស្លែងហ្នឹង មិនមែន

សរសេរដោយខ្មែរក្រហមទេ សរសេរឡើងដោយមន្ត្រីទួលស្លែង ដើម្បីកំណត់សម្គាល់លើរូបថតមួយចំនួន។ សំណួរ៖ ថាតើមានសំណួរណាដែលបញ្ជាក់ថា ជាចំណារផ្ទាល់ដៃរបស់ខ្មែរក្រហមទេ? ដោយបុគ្គលិកហ្នឹង លោក ឆាំង យុ ឆ្លើយថា៖ អត់ទេ។ សំណួរ៖ ថាតើលោកដឹងដូចម្តេចថា កំណត់ផ្ទាល់ដៃហ្នឹងធ្វើឡើងដោយខ្មែរក្រហម ឬក៏ដោយមន្ត្រីទួលស្លែង? យុ ឆាំង ឆ្លើយថា៖ ខ្ញុំអានច្រើនណាស់ ដូច្នេះខ្ញុំដឹង ហើយបុគ្គលិកអ្នកធ្វើទីនោះបានប្រាប់ខ្ញុំដែរ”។ ជាការជាក់ស្តែងណាស់យើងពិនិត្យមើលសំខាន់បើសិនជាមេធាវីការពារ ឧទាហរណ៍ថា ឌុច បានផ្តល់សក្ខីកម្មថា នួន ជា បានធ្វើកំណត់ចំណារផ្ទាល់ដៃមួយចំនួនទៅលើចម្លើយសារភាពនៅទួលស្លែង។ ហើយ យុ ឆាំង ក៏ពន្យល់ផងដែរថា មិនមែនជាខ្មែរក្រហមសុទ្ធតែអ្នកសរសេរទាំងអស់នេះទេ ក៏បុគ្គលិកទួលស្លែងដែលមានន័យថា អ្នកធ្វើការនៅសារមន្ទីរទួលស្លែងក្រោយពីខ្មែរក្រហមដួលរលំទៅ ហើយវៀតណាមចូលមកគ្រប់គ្រងទួលស្លែងនោះ ហើយអ្នកដែលធ្វើការក្រោយសម័យរបបខ្មែរក្រហមនោះក៏បានសរសេរ ឬក៏បានចំណាំអីនៅលើចំណារ នៅលើឯកសារ។ នេះហើយដែលលោក ឆាំង យុ គាត់បានផ្តល់កំណត់សម្គាល់ពីរឿងនេះដែលថា ចំណុចសំខាន់ដែលមេធាវីចង់សួរសំណួរទៅលោក ឆាំង យុ អំពីឯកសារទាំងឡាយនេះ។

ហើយក៏សំខាន់ដែរ ដែលថា លោកឆាំង យុ ខ្លួនបានចង្អុលបង្ហាញដែរថា វិធានការបន្ថែមទៀតក៏ត្រូវតែអនុវត្តដើម្បីបញ្ជាក់ពីយថាភាពនៃឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកឆាំង យុ បានសរសេរនៅឆ្នាំ២០០៥ ថា ឯកសារអំពីបទឧក្រិដ្ឋកម្ពុជាប្រជាធិបតេយ្យ ដែលមាននៅក្នុងសំណុំរឿង គឺ D111553 លោក យុ ឆាំង ក៏បាននិយាយដែរថា ការសរសេរវិភាគផ្ទាល់ដៃនេះ ជាឯកសារ ឌី.ស៊ី.ខេម ប៉ុន្តែមិនទាន់បានបញ្ជាក់យថាភាពទេ។

[១៣:៤៦:២៣]

លោក ឆាំង យុ ខ្លួនឯងនោះបានបញ្ជាក់ថា ការធ្វើតេស្តជាកោសល្យវិច័យនោះត្រូវតែធ្វើ ដើម្បីបញ្ជាក់អំពីយថាភាពនៃឯកសារទាំងនេះ។ ម្យ៉ាងវិញទៀត ការិយាល័យសហព្រះរាជអាជ្ញាមិនពិនិត្យឃើញថាមានការចាំបាច់ដើម្បីបញ្ជាក់យថាភាពនោះទេ។ ប៉ុន្តែប្រធាន ឌី.ស៊ី.ខេម ខ្លួនឯងគឺបញ្ជាក់ទស្សនៈដែលខុសពីព្រះរាជអាជ្ញាទៅវិញ។ ដូច្នេះមេធាវីការពារគប្បីតែទទួលបានការអនុញ្ញាតពីតុលាការ ដើម្បីសួរសំណួរទៅដល់ ឆាំង យុ ទៅតាមគោលបំណងនៃសវនាការនេះ។

នៅក្នុងចំណុចដែលខ្ញុំលើកឡើងនេះ ក៏បានបញ្ជាក់អំពីមូលហេតុដ៏សំខាន់ ដើម្បីគាំទ្រថាត្រូវតែកោះហៅ ឆាំង យុ មកធ្វើជាសាក្សី។ បើសិនជាគាត់មិនមកបានទេ គឺគាត់មិនមែនជាអ្នកប្រវត្តិសាស្ត្រ

ដែលមិនអព្យាក្រឹតនោះទេ គាត់ជាអ្នកប្រមូលឯកសារដែលមានគោលបំណងមួយ ដែលយើងយល់ថា គាត់មានលម្អៀងទៅខាងសហព្រះរាជអាជ្ញា ថាតើអង្គការរបស់គាត់ ហើយនិង ឆាំង យុ នោះ ថាតើគាត់ធ្វើដូចម្ដេចដើម្បីប្រមូលភស្ដុតាងកត់ត្រារបស់ឯកសារកម្ពុជាប្រជាធិបតេយ្យនោះ។

[១៣:៤៧:៣៦]

ប៉ុន្ដែយើងមិនរិះគន់ ឬក៏បន្ទោសលោក ឆាំង យុ អំពីវិធីសាស្ដ្របែបនោះទេ ក៏ប៉ុន្ដែលោក ឆាំង យុ នោះគឺថា យ៉ាងហោចណាស់គាត់ត្រូវបានលើកទឹកចិត្តដល់សហព្រះរាជអាជ្ញា ទៅតាមគោលបំណងនិងការងាររបស់គាត់នោះដែរ។ ប៉ុន្ដែលទ្ធផលនៃការងាររបស់គាត់ គប្បីតែពិចារណាដោយប្រុងប្រយ័ត្នបំផុត ប៉ុន្ដែយើងមិនត្រូវសន្និដ្ឋានថា ឯកសារហ្នឹងសុទ្ធតែអាចជឿទុកចិត្តបាននោះទេ ឬក៏ជាឯកសារដែលមានសុពលភាពយថាភាពនោះទេ។

មាត្រាមួយចំនួនដែលនិយាយអំពីចំណុចនេះ ហើយដែលអាចថា បង្ហាញពីវិធីសាស្ដ្ររបស់សហព្រះរាជអាជ្ញា ដែល ឆាំង យុ គាត់បានប្រើ។ អត្ថបទសារព័ត៌មាននេះនិយាយពីគំនិតមួយអំពីគម្រោងដែលថាជាគម្រោងផែនការចោទប្រកាន់លោក នួន ជា។ ប៉ុន្ដែនៅក្នុងនោះ មាត្រា២២៣ និយាយថា វាជាកត្តាចាំបាច់ ដែលថា ជនសង្ស័យរបស់កម្ពុជាប្រជាធិបតេយ្យដូចជា នួន ជា ត្រូវតែទទួលខុសត្រូវចំពោះបទឧក្រិដ្ឋឲ្យត្រឹមត្រូវតាមស្ដង់ដារ។ ទំព័រ២៥៤ គាត់និយាយថា ឯកសារជាភស្ដុតាងទាំងអស់នោះគឺត្រូវបានប្រើទាក់ទងទៅនឹងបទឧក្រិដ្ឋទូលំទូលាយ ហើយដែលប្រព្រឹត្តដោយជនជាប់ចោទទាំងអស់ ដែលរាប់ទាំង នួន ជា។ ឯកសារទាំងនោះ ក៏បង្ហាញអំពីបទឧក្រិដ្ឋជាក់លាក់ ហើយបង្ហាញអំពីការដឹង ហើយនិងភាពស្មុគស្មាញការអនុវត្តរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យរាប់ទាំង នួន ជា ផង។

[១៣:៤៩:១៩]

ហើយនៅក្នុងអត្ថបទនេះ ក៏បាននិយាយម្ដងហើយម្ដងទៀត បង្ហាញអំពីវិធីសាស្ដ្រដើម្បីជាយុត្តិ-សាស្ដ្រចោទប្រកាន់ នួន ជា ឲ្យជោគជ័យ ហើយសេចក្ដីរាយការណ៍នោះសន្និដ្ឋានថា ឯកសារនេះជាភស្ដុតាងក្នុងតុលាការ ដែលអាចបង្ហាញភស្ដុតាងថា ដែលថា នួន ជា ហើយនិងអ្នកផ្សេងទៀត ពិតជាប្រើអំណាចជាមេដឹកនាំដ៏ធំធេងនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ហើយអាចចាត់ទុកឯកសារនេះជា *"ដេហ្សូរ"* ជាភស្ដុតាងត្រឹមត្រូវតាមអង្គច្បាប់ ដើម្បីធ្វើការចោទប្រកាន់។ បន្ទាប់មក គឺនិយាយថា គឺជាភស្ដុតាងដែលបញ្ជាក់អំពីចេតនាឧក្រិដ្ឋ ជាកត្តាអត្តនោម័តិរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ នួន ជា ជាពិសេសជាភស្ដុតាងដ៏រឹងមាំ។

ម្តងទៀត យើងមិនចោទប្រកាន់អំពីវិធីសាស្ត្រ ជាការចោទប្រកាន់របស់ យុ ឆាំង ទេ ក៏ប៉ុន្តែការងាររបស់គាត់មានទំនងជាការងារដើម្បីការចោទប្រកាន់។ គាត់មិនមែនជាមនុស្សអធ្យាក្រឹត្យនៅក្នុងករណីនេះទេ ហើយដោយសារថាគាត់ធ្វើការដោយមានគោលបំណងដែលថាគាត់ធ្វើការក្នុងគោលបំណងចោទប្រកាន់អ្នកផ្សេងៗទៀត ដែលរាប់ទាំង នួន ជា នោះផងដែរ។ នេះហើយមានសេចក្តីសន្និដ្ឋានអំពីភាពលម្អៀងនៃការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

[១៣:៥០:៣៨]

អាស្រ័យហេតុនេះ លោក យុ ឆាំង ត្រូវតែអញ្ជើញមកបង្ហាញពន្យល់អំពីការលំហូរ ហើយនិងការកាន់កាប់ឯកសារពីកន្លែងមួយទៅកន្លែងជាដើម។ ហើយ យុ ឆាំង ក៏ត្រូវតែផ្តល់នូវព័ត៌មានបន្ថែមទៀត សរសេរអំពីការគ្រប់គ្រង ហើយអ្នកណាផ្សេងទៀតដែលជាអ្នកកាន់កាប់រក្សាទុកឯកសារនោះ។ ហើយ ឆាំង យុ ក៏ត្រូវតែមកបង្ហាញខ្លួន ដើម្បីឲ្យភាគីទាំងអស់សួរដេញដោល ដើម្បីឲ្យឆ្លើយពីបរិបទដ៏សំខាន់នេះ។

ប្រសិនបើគាត់មិនបានមកទេ អង្គជំនុំជម្រះគប្បីត្រូវតែកោះគាត់។ បើគាត់នៅតែមកទៀត គឺថាអ្វីៗដែលចេញមកពី ឌី.ស៊ី.ខេម មិនអាចនឹងចាត់ទុកថាជាភស្តុតាងយកមកដេញដោល ឬក៏យកមកប្រើជាមូលដ្ឋានរបស់តុលាការ ដើម្បីនឹងដេញដោលធ្វើជាភស្តុតាងនូវរឿងក្តីនោះឡើយ។

ឥឡូវនេះ ខ្ញុំសូមផ្តល់វេទិកាទៅដល់សហសេវិករបស់ខ្ញុំ គឺលោក ផេសមិន។

[១៣:៥១:៤២]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងផ្តល់នូវមតិយោបល់ខ្លីៗដែលទាក់ទងទៅនឹងឯកសារដែលដាក់មកដល់តុលាការកាលពីសប្តាហ៍មុន ដែលបង្ហាញនៅក្នុងដំណាក់កាលមួយចំនួននៅក្នុងការចោទសួររបស់សហព្រះរាជអាជ្ញាទៅលើកូនក្តីរបស់ខ្ញុំ។ យើងនៅតែសន្មតថា យើងនៅតែមានសិទ្ធិក្នុងការជំទាស់ភាពទទួលយកបាននៃឯកសារនេះ តាំងពីសប្តាហ៍កន្លងមកនេះក៏ដោយ។ លោកប្រធានបានអាននូវសេចក្តីសម្រេចមួយដែលទំនងជាបង្ហាញថា ឯកសារហ្នឹងត្រូវបានទទួលស្គាល់រួចហើយ យកធ្វើជាភស្តុតាង។ យើងសន្និដ្ឋានថា យើងនៅតែមានសិទ្ធិដើម្បីជំទាស់ បើសិនជាខ្ញុំបាទខុសមតិយោបល់របស់ខ្ញុំហើយនិងដោយសហសេវិករបស់ខ្ញុំ នឹងត្រូវបានគេចាត់ទុកថា ជាការជំទាស់ទៅនឹងយថាភាពនៃឯកសារនេះ។ ដូច្នេះហើយ ការជំទាស់ទាក់ទងទៅនឹងទម្ងន់នៃតម្លៃជាភស្តុតាងនៃឯកសារដែលនឹងត្រូវ

យកមកដេញដោលនៅពេលអនាគត។

[១៣:៥២:៥០]

យើងជំទាស់ជាពិសេស ហើយលោកចៅក្រមមិនភ្ញាក់ផ្អើលទេ គឺការទទួលយកនូវឯកសារថតចម្លងនៃឯកសារទង់បដិវត្តដែលបានបង្ហាញដោយសហព្រះរាជអាជ្ញាទៅកូនក្តីរបស់ខ្ញុំនោះ។ ហើយខ្ញុំក៏ចាំផងដែរថា ច្បាប់ចម្លងនៃទស្សនាវដ្តីទង់យុវជនបដិវត្តដែលបានបង្ហាញទៅកូនក្តីរបស់ខ្ញុំ ហើយនិងកំណត់សម្គាល់ដែលកត់ឡើងដោយលោក ខឹម ងុន សម្ភាសជាមួយ ខឹម ងុន។ ខ្ញុំមិនដឹងថា អានត្រូវឬក៏ខុសទេ ប៉ុន្តែបើសិនជាលោកប្រធានស្តាប់មិនច្បាស់ទេ គឺថាសុំប្រាប់ជម្រាបខ្ញុំផង។

ដូច្នេះ ខ្ញុំមានការពិបាក ដូចលោកប្រធានជ្រាបហើយឈ្មោះខ្មែរហ្នឹង។ ប៉ុន្តែឈ្មោះដែលកូនក្តីរបស់ខ្ញុំយោងទៅ ដែលជាចារកិច្ចរបស់លោក ហ៊ុន សែន ជាលេខកូដទី៩ នោះ។ បន្ទាប់ពីឆ្នាំ១៩៧៩ ហើយគាត់បានជួបជាមួយកូនក្តីរបស់ខ្ញុំពិភាក្សា ហើយគាត់ក៏បានកត់ត្រា។ កូនក្តីរបស់ខ្ញុំជំទាស់យថាភាពឯកសារទាំងអស់នោះ ដែលបានបង្ហាញមកគាត់។

[១៣:៥៤:០៣]

ដូច្នេះហើយ ភាពជឿជាក់បាននូវឯកសារទាំងអស់នោះ ដែលបញ្ជាក់នៅក្នុងវិធាន៨៧ គឺជាលក្ខខណ្ឌនៃភាពទទួលយកបាននៃឯកសារទាំងអស់នោះក្នុងតុលាការ។ ហើយគាត់ក៏បានផ្តល់មូលហេតុទាំងឡាយផងដែរ ចំពោះការជំទាស់របស់គាត់នោះ។ គាត់បាននិយាយថា ក្នុងករណីនោះ ទង់បដិវត្តគឺត្រូវបានសរសេរជាអក្សរផ្ទាល់ដៃ តែមិនមែនវាយអង្គុលីលេខទេ។ ហើយគេត្រូវបានបោះពុម្ពជាក្លូរ័រជាពណ៌ មិនមែនខ្មៅនិងសទេ ហើយថាទង់បដិវត្តហ្នឹង គឺត្រូវជំនួសដោយទង់មួយផ្សេងទៀត ទស្សនាវដ្តីផ្សេងទៀត។ ឥឡូវឈ្មោះអី ខ្ញុំភ្លេចខ្លួនឯងដែរ អ៎ គេហៅថា “ទង់ក្រហម” គឺទស្សនាវដ្តីទង់ក្រហមដែលជំនួសទង់បដិវត្ត ក្រោយឆ្នាំ១៩៧៥ ហើយគាត់បាននិយាយអំពីទម្រង់បែបបទពិសេសនៃទង់បដិវត្តនោះដែរ គេបោះពុម្ពជាកូនសៀវភៅទេ មិនមែនដូចជាឯកសារដែលបង្ហាញមកគាត់ពីសប្តាហ៍មុននោះទេ។

[១៣:៥៥:១២]

ទាក់ទងទៅនឹងការសម្ភាសន៍ ហើយមានកំណត់ហេតុដែលកត់ត្រាដោយចារកម្មរបស់លោក ហ៊ុន សែន លេខប្រាំបួននោះ គាត់ជំទាស់ទៅនឹងយថាភាពនៃឯកសារនោះ ពីព្រោះថាបុគ្គលនេះមិនគួរឱ្យទុកចិត្តបានក្នុងការផ្តល់នូវសេចក្តីថ្លែងការណ៍ត្រឹមត្រូវនៃការសម្ភាស ដែលបានពិភាក្សាជាមួយគ្នា

នោះទេ។ បុគ្គលនេះគឺជាចារកម្ម កូនក្តីរបស់ខ្ញុំមិនដឹងថាគាត់ជាអ្នកណាទេដំបូង រហូតដល់ក្រោយបានដឹង។ ដូច្នេះហើយគាត់មានកម្មវិធីពិសេសរបស់គាត់ ហើយមិនអាចគួរឲ្យទុកចិត្តបានទេ អ្វីដែលគាត់កត់ត្រា អ្វីដែលគាត់ផ្តល់កត់ត្រាពីការសម្ភាសជជែកពិភាក្សាជាមួយគាត់នោះ។

[១៣:៥៥:៥២]

ហើយឯកសារនេះទៀតសោត គាត់ក៏សំខាន់ដែរ គឺមិន-- ដោយហេតុថាសហព្រះរាជអាជ្ញាបានបង្ហាញមកកូនរបស់ក្តីខ្ញុំទេ។ ក៏ប៉ុន្តែវាសំខាន់ផងដែរ ដែលយើងពិនិត្យឃើញថាមិនអាចយកជាភស្តុតាងទេ។ ហើយប្រសិនជាតុលាការនឹងយកធ្វើបែបនោះ ថាកំណត់ជាតួនាទីជនជាប់ចោទដូចជាកូនក្តីខ្ញុំនេះដែលថាបានអនុវត្តនៅក្នុងអាជ្ញាយុកាល ឬក៏ក្នុងរយៈពេលនៃសវនាការវគ្គនេះចាប់ពីឆ្នាំ១៩៧៥ ដល់៧៦នោះ ហើយមានការចោទប្រកាន់ថា គាត់ជាអ្នកនិពន្ធរួមនៃទង់បដិវត្តនេះ ឬក៏ថាគាត់បានចូលរួមក្នុងការបង្កើតគោលនយោបាយដែលចុះផ្សាយនៅក្នុងទស្សនាវដ្តីនេះ។ ដូច្នេះហើយនេះជាភស្តុតាងដែលបង្ហាញអំពីតួនាទីរបស់កូនក្តីរបស់ខ្ញុំនៅក្នុងអង្គហេតុ ដែលកំណត់នៅក្នុងដីកាបញ្ជូនរឿងមកជម្រះ។ ដូច្នេះហើយយើងត្រូវកំណត់បទដ្ឋានអប្បបរមាដើម្បីកំណត់ថាទាបប៉ុនណា? ខ្ពស់ប៉ុនណា? ដើម្បីនឹងទទួលយកបាន។ ដើម្បី-- ដូច្នេះត្រូវអនុវត្តបទដ្ឋានអប្បបរមា ត្រូវយកមកប្រើប្រាស់ដើម្បីកំណត់ឯកសារនេះក្នុងបរិបទនៃរឿងកូនក្តីខ្ញុំនេះ កូនក្តីរបស់ខ្ញុំនេះ។

[១៣:៥៧:១៨]

ដោយហេតុនេះហើយ ខ្ញុំគាំទ្រមតិដែលលើកឡើងដោយសហសេវិករបស់ខ្ញុំនៅទីនេះ គឺថា យុ ឆាំង ជាប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា។ គាត់ក៏បានធ្វើយថាភាព ហើយនិងបញ្ជាក់ពីភាពអាចទទួលយកបានលើឯកសារមួយចំនួនដែលត្រូវប្រឆាំងនឹងកូនក្តីរបស់ខ្ញុំ ដែលរាប់បញ្ចូលទាំងទង់បដិវត្តដែលបង្ហាញកូនក្តីរបស់ខ្ញុំ។ រីឯការទទួលស្គាល់ឯកសារនេះ នៅតុលាការត្រូវតែបញ្ជាក់ចេញមជ្ឈ-មណ្ឌល ឌី.ស៊ី.ខេម នោះ ត្រូវតែមានការបញ្ជាក់ដោយ ឆាំង យុ។

[១៣:៥៨:០០]

ក្រៅពីនេះទៀត យើងគិតថាវាមានការសំខាន់ចាំបាច់បំផុតដែលយើងត្រូវស្តាប់ចម្លើយរបស់ ខឹម ងុន ជាចារកិច្ចលេខប្រាំបួន ហើយក៏ត្រូវសួរដេញដោលគាត់អំពីកំណត់ហេតុទាំងអម្បាលម៉ាននោះដែរ។ យើងគិតថា កំណត់ហេតុទាំងនោះមិនអាចឲ្យតុលាការទទួលយកប្រើជាភស្តុតាងបានទេ។ មិនមានភស្តុតាងអ្វីចេញពីកំណត់ហេតុនោះទេ ដរាបណាតែចារកម្មរូបនេះ ខឹម ងុន នេះ មកបង្ហាញខ្លួន ហើយ

នឹងសួរដេញដោលនៅតុលាការដោយភាគី ឬក៏គេហៅថា សួរដេញដោលពីភាគីទៅលើកំណត់ហេតុដែលគាត់កត់ពីការជជែកលេងជាមួយកូនក្តីរបស់ខ្ញុំនោះ។

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។

[១៣:៥៨:៥០]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។

ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាទៅមេធាវីការពារក្តី អៀង សារី។ សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

អរុណសួស្តីលោកប្រធាន លោក លោកស្រីចៅក្រម និងអស់លោក លោកស្រីនៅក្នុងបន្ទប់សវនាការ និងនៅជុំវិញបន្ទប់សវនាការនេះ។

ខ្ញុំសូមលើកឡើងដោយគាំទ្រទៅលើសេចក្តីសន្និដ្ឋានរបស់ខាងមេធាវីការពារក្តី នួន ជា ដែលទាមទារឲ្យលោក ឆាំង យុ មកផ្តល់ចម្លើយនៅក្នុងសវនាការនេះ។ ដោយសារគាត់ជាអ្នករក្សាឯកសារទាំងឡាយ ហើយដោយផ្អែកទៅលើការទទួលស្គាល់ដែលលើកឡើងដោយ គាត់ថា គាត់គឺជាភស្តុតាងមួយសំខាន់អាចផ្តល់ជាចម្លើយបាន។ ហើយគាត់អាចផ្តល់ជាចម្លើយជាក់លាក់មួយចំនួន ឬក៏អាចបញ្ជូនភ្នាក់ងាររបស់គាត់ជំនួស តំណាងដល់គាត់។ ប្រសិនបើមានអ្នកតំណាងមកចូលរួមនោះ គឺវាល្អហើយក៏ប៉ុន្តែវាជាការល្អប្រសិនបើលោក ឆាំង យុ នេះមកផ្តល់សក្ខីកម្ម ដោយាសារគាត់ដឹងនឹងជាភស្តុតាងមួយសម្រាប់យើង។ យើងខ្ញុំសូមលើកឡើងឆ្លើយតប ហេតុអ្វីបានជាសហព្រះរាជអាជ្ញាផ្អែកជាសំខាន់ទៅលើឯកសារ ឌី.ស៊ី.ខេម? ឯកសារ ឌី.ស៊ី.ខេម នេះគឺត្រូវបានផ្អែកដោយសហព្រះរាជអាជ្ញាដើម្បីធ្វើការងាររបស់ខ្លួន ហើយបានទទួលយកឯកសាររបស់ ឌី.ស៊ី.ខេម មកធ្វើជាមូលដ្ឋាន។

[១៤:០០:៣៤]

ដូច្នេះថាតើហេតុអ្វីសហព្រះរាជអាជ្ញាមិនបង្ហាញ ហើយមិនមានភស្តុតាង មិនយកភស្តុតាងឲ្យបានគ្រប់គ្រាន់ពីលោក ឆាំង យុ? ហេតុអ្វីបានជាសហព្រះរាជអាជ្ញាមិនយកចម្លើយពីលោក ឆាំង យុ ដើម្បីជាមូលដ្ឋាន ថាតើ ឌី.ស៊ី.ខេម ប្រមូលភស្តុតាងតាមរបៀបណា? មកពីកន្លែងណា? រក្សាទុកនៅកន្លែងណា? អ្នកណាជាអ្នកវិភាគទៅលើឯកសារទាំងអស់នោះ ហើយតើគេរៀបចំផែនការទៅលើទម្រង់បែបបទនៃការរក្សាឯកសារនោះយ៉ាងម៉េច? ហើយខ្លឹមសារដែលគាត់ដកស្រង់នោះ គឺវាត្រឹមត្រូវ

និងមិនលម្អៀងដែរឬទេ? ហើយតើឯកសារទាំងអស់នោះត្រូវបានរក្សាទុកយ៉ាងត្រឹមត្រូវនៅក្នុងខ្សែអាត់ក្នុងករណីដែលភស្តុតាងទាំងឡាយទាមទារឲ្យយកមកបង្ហាញ។ល។

[១៤:០១:៤១]

ប្រសិនសហព្រះរាជអាជ្ញាបានធ្វើការងារទាំងអស់នេះ ហើយប្រសិនចៅក្រមស៊ើបអង្កេតបានធ្វើដូចខ្ញុំលើកឡើងនេះ សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតមិនបានធ្វើទេ ទោះបីជាយើងខ្ញុំស្នើសុំក៏ដោយ។ ដូច្នេះហើយគឺលោក ឆាំង យុ គឺជាបុគ្គលដែលល្អបំផុត ដែលអាចមកផ្តល់ភស្តុតាងនៅទីនេះ។ យើងដឹងហើយថា បញ្ហានេះនឹងកើតឡើងដដែលៗពាក់ព័ន្ធទៅនឹងឯកសារទាំងឡាយដែលយកមកតែពីខាង ឌី.ស៊ី.ខេម។ ដូច្នេះហើយ ជាការល្អគឺយើងត្រូវមានសវនាការលម្អិតជាក់លាក់ជាពិសេសគឺស្តាប់ចម្លើយពីខាងអ្នកដែលរក្សាទុកឯកសារនេះផ្ទាល់តែម្តង ថាតើឯកសារទាំងឡាយប្រមូលយកមកយ៉ាងម៉េច រក្សាទុកដោយរបៀបណា?

[១៤:០២:៣៥]

ដូច្នេះប្រសិនបើយើងមានលោក ឆាំង យុ ចូលមកផ្តល់ជាចម្លើយនោះយើងនឹងមានភាពជឿជាក់ទុកចិត្តទៅលើឯកសារទាំងឡាយ ហើយឲ្យយើងអាចទុកចិត្តលើឯកសារទាំងអស់នោះយកមកប្រើនៅក្នុងសវនាការតុលាការរបស់យើង។ នៅពេលដែលខ្ញុំលើកឡើងដូច្នេះ លោក លោកស្រីបានជ្រាបហើយកាលពីពីរសប្តាហ៍មុន គឺយើងបានដាក់នូវការជំទាស់លម្អិតរបស់យើងក្នុងលក្ខណៈជាឧបសម្ព័ន្ធដែលមានឯកសារ៥០០០-- ជាង៥០០០ នៅក្នុងនោះគឺយើងកំណត់ទៅតាមប្រភេទរបស់វា ហើយយើងបានពន្យល់លម្អិតពាក់ព័ន្ធទៅនឹងឯកសារដែលគ្រោងយកមកប្រើប្រាស់នៅក្នុងដំណាក់កាលសវនាការវគ្គដំបូង។ ដូច្នេះ ខ្ញុំនឹងលើកឡើងអំពីប្រភេទឯកសារទាំងអស់នេះ៖

[១៤:០៣:៣៣]

ចំណុចទីមួយ សារព័ត៌មាន និងសេចក្តីប្រកាសជាសាធារណៈ៖ ឯកសារទាំងអស់នេះមានដូចជាសៀវភៅខ្មៅ និងរបាយការណ៍ *ហ្វីតស៍* ដូចដែលខ្ញុំបានជម្រាបពីកាលសប្តាហ៍មុនហើយ ដែលឯកសារទាំងឡាយគឺយើងត្រូវបានកំណត់ប្រភេទ ហើយថាតើវាលក្ខណៈលម្អិតយ៉ាងណា ដូចជាសេចក្តីថ្លែងការណ៍របស់លោក ប៉ុល ពត ហើយសេចក្តីថ្លែងការណ៍ ឬសុន្ទរកថានោះបានកត់ត្រាត្រឹមត្រូវដែរឬទេនៅក្នុងរបាយការណ៍នានា ក្នុងសារព័ត៌មាន។

ចំពោះឯកសារចាក់ផ្សាយដែលជាឯកសារស៊ើបការណ៍សម្ងាត់របស់សហរដ្ឋអាមេរិក នោះគឺជា

ឯកសារដែលបានបង្កើតឡើងមុនឆ្នាំ១៩៧៥ មិនផលិតនិងបង្កើតឡើងនៅក្នុងប្រទេសកម្ពុជាទេ គឺវារួមទាំងនៅក្នុងប្រទេសវៀតណាមផងដែរ។ ដូច្នេះយើងបានដឹងច្បាស់ថា ប្រធានាធិបតី *នីចសុន* និង *គីសស៊ីងហ្គឺ* គឺគាត់លើកឡើងថាគ្មានអ្វីកើតឡើងនៅក្នុងប្រទេសកម្ពុជានោះទេ គ្មានការទម្លាក់គ្រាប់បែកនោះឡើយ។ ដូច្នេះចំណុចទាំងអស់នេះ គឺវាមិនត្រឹមត្រូវនោះទេ។ ខាង ស៊ី.អាយ.អេ គឺពាក់ព័ន្ធនៅក្នុងប្រទេសនេះ រួមទាំងប្រទេសវៀតណាមផងដែរ។ ដូច្នេះប្រសិនបើយើងមិនមើលរបាយការណ៍ពីក្រុមភ្នាក់ងារនោះទេ គឺយើងមិនបានដឹងនោះទេ។ យើងត្រូវតែទទួលស្គាល់ថា ស៊ី.អាយ.អេ គឺគាត់ក៏មានភារកិច្ចនិងបានធ្វើការបំប្លែងព័ត៌មានផងដែរ។

ដូច្នេះជាជាងយើងផ្អែកទៅលើឯកសារទាំងអស់នេះ ដែលបានបង្កើតឡើងដោយ សេ.អ៊ី.អា ឬក៏ភ្នាក់ងារដទៃៗទៀត គឺយើងត្រូវតែមើលឲ្យបានច្បាស់លាស់។ លក្ខខណ្ឌចង្អុលបញ្ជាក់មួយចំនួន គឺវាបង្ហាញឲ្យយើងឃើញយ៉ាងច្បាស់ មិនត្រឹមតែខ្លឹមសារនៃឯកសារទាំងអស់នោះឡើយ។

[១៤:០៥:៤៧]

ដូច្នេះយើងត្រូវមើលឲ្យបានជាក់លាក់ សិទ្ធិមូលដ្ឋានមួយដែលលោក អៀង សារី ទទួលបាន និងជនជាប់ចោទដទៃទៀតទទួលបាននោះ គឺជាសិទ្ធិមួយដែលខ្ញុំនឹងលើកឡើង ហើយវាស្ថិតនៅក្នុងប្រភេទនៃសិទ្ធិនានា។ សិទ្ធិមួយនុំង គឺសិទ្ធិក្នុងការតទល់ជាមួយនឹងបុគ្គលដែលជាអ្នកផលិតឯកសារ។ ដូច្នេះជនជាប់ចោទ លោក អៀង សារី ត្រូវតែមានសិទ្ធិតទល់ជាមួយនឹងអ្នកដែលគាត់បានបង្កើតឯកសារ។ យើងត្រូវតែដឹងថា បុគ្គលណាជាអ្នកបង្កើតឯកសារ។ ដូច្នេះ យើងគួរតែយកបុគ្គលដែលធ្វើការងារនៅក្នុងភ្នាក់ងារ សេ.អ៊ី.អា នេះ ដើម្បីឲ្យគាត់បង្ហាញអំពីការដែលគេផលិតឯកសារ និងរៀបចំឯកសារនេះដោយរបៀបណា។ បើសិនមិនដូច្នោះទេ គឺវាគ្មានតម្លៃអ្វីនោះទេ។

[១៤:០៦:៤៥]

នៅក្នុងករណីដែលយើងយល់ឃើញថា ឯកសារទាំងអស់នេះ វាមានតម្លៃជាភស្តុតាងនោះ មានន័យថា ប្រសិនបើអង្គជំនុំជម្រះលើកឡើងថា វាជាភស្តុតាង ពាក្យចចាមអារ៉ាម ដែលយើងអាចទទួលយកបាន ដែលនៅក្នុងហ្នឹងភស្តុតាងទាំងអស់នេះយកចេញមកពីអត្ថបទសារព័ត៌មាន...។ល។ នោះប្រសិនបើយើងចាត់ទុកវាជាឯកសារដូច្នេះនោះ យើងខ្ញុំនឹងស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការពិចារណា ធ្វើយ៉ាងណារកលក្ខខណ្ឌចង្អុលបញ្ជាក់ឯករាជ្យមួយ ដែលវាបង្ហាញអំពីការទទួលយកឯកសារនេះបាន។ យើងឃើញមានភស្តុតាងដទៃទៀតដែលសហព្រះរាជអាជ្ញា និងភាគីដទៃទៀតបានបង្ហាញ ហើយវាមាន

តម្លៃសុពលភាពជាងរបាយការណ៍និងឯកសារសារព័ត៌មានជាសាធារណៈ។ ដូច្នេះ អង្គជំនុំជម្រះត្រូវការសម្រេច ថាតើគួរផ្តល់ទម្ងន់ប៉ុនណាទៅលើឯកសារទាំងអស់នេះ? ដោយយើងត្រូវចងចាំ និងគោរពទៅលើគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។

[១៤:០៧:៤៨]

ចំពោះអត្ថបទនិងសៀវភៅ វាជាប្រភេទនៃឯកសារដែលយើងសូមជំទាស់។ ប្រសិនបើយើងយកសៀវភៅ យកមកដាក់បញ្ចូលទទួលយកបាន ហើយមិនឲ្យមានអ្នកនិពន្ធយកមកបង្ហាញទៅលើបទពិសោធន៍ និងការរៀបចំរបស់គាត់នោះ ហើយប្រសិនបើយើងមិនឲ្យអ្នកជាអ្នកនិពន្ធមកបង្ហាញអំពីខ្លឹមសារសៀវភៅនេះ វាជាការរំលោភទៅសិទ្ធិជនជាប់ចោទ។ យើងខ្ញុំសូមបញ្ជាក់ថា ប្រសិនបើយើងចង់រកការពិតយោងតាមវិធាន៨៤(១) លោក អៀង សារី ត្រូវតែទទួលបានសិទ្ធិដាច់ខាតមួយក្នុងការតទល់ជាមួយនឹងអ្នកនិពន្ធនៃសៀវភៅនិងអត្ថបទ។

[១៤:០៨:៤៣]

ដូច្នេះសៀវភៅ និងអត្ថបទទាំងអស់នេះ ទោះបីជាអ្នកនិពន្ធដែលថាគាត់ជាអ្នកគួរឲ្យទុកចិត្តបានក៏ដោយ ក៏យើងត្រូវតែកោះហៅអ្នកនិពន្ធទាំងអស់នោះឲ្យមកចូលរួមផ្តល់បញ្ជាក់ឲ្យបានច្បាស់លាស់។ ដូច្នេះ ខ្ញុំមិនមែនថាយើងដកចេញអ្នកនិពន្ធណាមួយជាក់លាក់នោះទេ ពីព្រោះថា ពេលខ្លះយើងត្រូវគោរពទៅលើគោលការណ៍នៃភស្តុតាងពាក្យចចាមអារ៉ាម។

សៀវភៅនិងអត្ថបទទាំងឡាយ វាអាចជាភស្តុតាងបន្ថែមគាំទ្រ វាជាលក្ខខណ្ឌបញ្ជាក់មួយដាច់ដោយឡែក។ ប៉ុន្តែចំណុចនេះមិនមែនមានន័យថា វា-- សៀវភៅនោះ វាមានភាពខុសចំណុចខុសគ្នានៅក្នុងតែសៀវភៅតែមួយនោះទេ គឺយើងត្រូវតែផ្តល់តម្លៃខុសៗគ្នា។ យើងត្រូវពិនិត្យមើលថាតើអ្នកណាគេជាអ្នកបង្កើតគំនិតទស្សនៈនៅក្នុងសៀវភៅនេះ? ហើយចំណុចដែលគេធ្វើសេចក្តីសន្និដ្ឋានក្នុងសៀវភៅនោះ គេសន្និដ្ឋានតាមរបៀបណា? ហើយមានភស្តុតាងណាផ្សេងជាមូលដ្ឋានគាំទ្រដែរឬទេ?

[១៤:០៩:៥៧]

ដូច្នេះប្រសិនបើមិនដូច្នេះទេ គឺយើងនឹងឃើញក្នុងសវនាការរបស់យើង ភាគីលើកឡើងដដែលៗថា ចំណុចមួយនៅក្នុងសៀវភៅនេះគឺវាលើកឡើងមិនត្រឹមត្រូវ ហើយលើកឡើងម្តងហើយម្តងទៀតនៅក្នុងសៀវភៅដដែល។ យើងត្រូវចងចាំថា អ្នកនិពន្ធធ្វើយ៉ាងណាត្រូវតែជាអ្នកមួយមិនលម្អៀង។

[១៤:១០:២៣]

ប្រភេទឯកសារទីបី គឺការបោះពុម្ពផ្សាយនិងសេចក្តីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងនោះរួមទាំងទស្សនាវដ្តីផងដែរ។ យើងខ្ញុំសូមជំទាស់ចំពោះការទទួលយកការបោះពុម្ពផ្សាយ ដូចជា ទស្សនាវដ្តីនិងសេចក្តីសម្រេចនានា លើកលែងតែយើងអាចកំណត់លក្ខខណ្ឌនិងគុណសម្បត្តិរបស់វា លើកលែងតែសហព្រះរាជអាជ្ញាអាចបង្ហាញ អំពីយថាភាព ភាពអាចទុកចិត្តបាន ភាពពាក់ព័ន្ធទៅនឹងឯកសារនីមួយៗ ហើយអាចបង្ហាញថាតើនរណាគេជាអ្នកសរសេរខ្លឹមសារនៅក្នុងសៀវភៅ និងអត្ថបទទាំងអស់នៅក្នុងការចេញផ្សាយនិងសេចក្តីសម្រេចទាំងអស់នេះ។ យើងសូមលើកឡើងថា ចំណុចហ្នឹងមិនមែនថាយើងមិនអាចធ្វើទៅបាននោះទេ វាជាលក្ខខណ្ឌអប្បបរមាមួយ។ ដូច្នេះ វាគ្រាន់តែសៀវភៅការចេញផ្សាយមួយមានរូប*ឡូហ្គោ* មិនមែនថា វាមានយថាភាពនោះទេ។

[១៤:១១:៣០]

ខ្លឹមសារនៃឯកសារទស្សនាវដ្តី ឬក៏សេចក្តីប្រកាស សេចក្តីសម្រេចទាំងអស់នេះ គឺវាត្រូវតែបញ្ជាក់ថា បុគ្គលណាជាអ្នករៀបចំឡើង ដើម្បីធ្វើឲ្យយើងដឹងថាតើមានអ្វីខ្លះដែលបានសរសេរនៅក្នុងនេះ។ ដូច្នេះនិយាយដោយសាមញ្ញគឺថា យើងមិនអាចគ្រាន់តែនិយាយថា ទស្សនាវដ្តីនេះសរសេរដូច្នេះ ហើយមិនបានបង្ហាញថា បុគ្គលណាជាអ្នកសរសេរ ជាអ្នករៀបចំនោះទេ ការធ្វើដូច្នេះមិនត្រឹមត្រូវនោះឡើយ។ យើងខ្ញុំគ្រាន់តែស្នើសុំលក្ខខណ្ឌបង្ហាញអប្បបរមាឲ្យខាងសហព្រះរាជអាជ្ញា ជាអ្នកបង្ហាញតែប៉ុណ្ណោះ។ នៅក្នុងករណីដែលសេចក្តីសម្រេចនិងការបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជាទទួលយកបាននោះ ដូច្នេះហើយគឺយើងបាត់បង់នូវសិទ្ធិក្នុងការជំទាស់អ្នកដែលជាអ្នកសរសេរ និងរៀបចំឡើង។ យើងខ្ញុំសូមជំទាស់ ហើយលើកឡើងថា ប្រសិនបើធ្វើដូច្នេះគួរតែផ្តល់ទម្ងន់តិចតួចតែប៉ុណ្ណោះ លើកលែងតែឯកសារចេញផ្សាយនិងសេចក្តីសម្រេចទាំងអស់នេះ មានការគាំទ្រដោយលក្ខខណ្ឌបញ្ជាក់ផ្សេងទៀត។

[១៤:១២:៤៤]

យើងឃើញថា យើងមានការព្រួយបារម្ភមួយចំនួននៅក្នុងបន្ទប់សវនាការនេះ ដែលថាទីនេះគឺយើងព្យាយាមចង់ដកចេញនូវឯកសារទាំងអស់ ហើយរារាំងនូវសវនាការនេះ។ យើងត្រូវតែមានគោលការណ៍ណែនាំមួយឲ្យបានច្បាស់លាស់ទៅលើចំណុចនេះ។ យើងត្រូវតែមានការប្រុងប្រយ័ត្នឲ្យបានហ្មត់ចត់នៅពេលដែលយើងផ្តល់ទម្ងន់ទៅលើឯកសារនិងភស្តុតាង។

ចំពោះកំណត់ហេតុកិច្ចប្រជុំ៖ កំណត់ហេតុកិច្ចប្រជុំរបស់បក្សកុម្មុយនីស្តកម្ពុជា គឺយើងជំទាស់

ដូចគ្នាទៅនឹងឯកសារមុនៗ លើកលែងតែសហព្រះរាជអាជ្ញាអាចបង្ហាញអំពីយថាភាព ភាពអាចទុកចិត្តបាន និងភាពពាក់ព័ន្ធនៃឯកសារនីមួយៗ ដោយសហព្រះរាជអាជ្ញាត្រូវតែបង្ហាញថា តើអ្នកណាគេជាអ្នករៀបចំនូវខ្លឹមសារនៃឯកសារនេះ។

[១៤:១៣:៤៥]

យើងយល់ថា នៅពេលដែលយើងយកឯកសារនេះមកដាក់បញ្ចូលទទួលយកនោះ វាអាស្រ័យមកកាន់-- វាជាកាតព្វកិច្ចរបស់យើងក្នុងការបង្ហាញអង្គជំនុំជម្រះ ក្នុងការបង្ហាញភាពទុកចិត្តបានក្នុងការចោទសួរទៅលើខ្លឹមសារនៃឯកសារទាំងអស់នេះ។ ក៏ប៉ុន្តែប្រសិនបើយើងមិនមានលទ្ធភាពតទល់ជាមួយអ្នកដែលសរសេររៀបចំកំណត់ហេតុផងនោះ ថាតើយើងអាចធ្វើការតវ៉ាទៅលើខ្លឹមសារនៃកំណត់ហេតុនេះតាមរបៀបណា? យើងមិនដឹងថាតើកំណត់ហេតុនោះ រៀបចំក្នុងពេលប្រជុំតែម្តង ឬក៏រៀបចំក្រោយពេលប្រជុំ ហើយអ្នកណាគេខ្លះមានវត្តមាននៅពេលប្រជុំ? ហើយខ្លឹមសារដើមនៃការពិភាក្សាគ្នាក្នុងពេលប្រជុំនោះយ៉ាងម៉េច? សហព្រះរាជអាជ្ញា គឺគាត់មិនមានលទ្ធភាពក្នុងការបង្ហាញសាក្សីនោះទេក្នុងចំណុចនេះ ក្នុងការឆ្លើយតបទៅលើចំណុចដែលខ្ញុំបានលើកឡើង ក៏ប៉ុន្តែយ៉ាងហោចណាស់សហព្រះរាជអាជ្ញាក៏អាចផ្តល់ជាសាក្សីក្នុងពេលណាមួយ ដូចដែលយើងបានស្នើសុំកាលពីលើកមុន ដោយយើងដឹង ទោះបីជាយើងដឹងថា លោក លោកស្រីចៅក្រមជាអ្នកសម្រេចទៅលើលំដាប់លំដោយនៃសាក្សីក៏ដោយ។

[១៤:១៥:០៥]

ដូច្នេះ សហព្រះរាជអាជ្ញាគួរតែបង្ហាញសាក្សីមួយចំនួនមកបង្ហាញនៅលើឯកសារនេះ ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់តុលាការ។ គឺយើងធ្វើយ៉ាងណាឲ្យមានមូលដ្ឋានឲ្យបានជាក់លាក់។ វាមិនមែនជាកំហុសរបស់សហព្រះរាជអាជ្ញាក្នុងការដែលតម្រូវឲ្យសាក្សីមកមុននិងក្រោយនោះទេ។ ក៏ប៉ុន្តែយ៉ាងណាក៏ដោយសហព្រះរាជអាជ្ញាត្រូវតែគិតទៅលើការងារនេះ ហើយត្រូវដឹងថា តើខ្លួនចង់បង្កើតមូលដ្ឋានចំពោះសាក្សីនីមួយៗនេះតាមរបៀបណា?

ដូចដែលលោក លោកស្រីចៅក្រមបានបំពេញការងារនេះរួចមកហើយ គឺផ្តល់បញ្ជីនៃសាក្សីដើម្បីធ្វើជាមូលដ្ឋាននៅក្នុងពេលសវនាការ។ ដូច្នេះ សហព្រះរាជអាជ្ញាគួរតែធ្វើដូច្នេះ ជម្រាបមកកាន់យើងទាំងអស់គ្នាថា សាក្សីមួយចំនួនអាចចូលខ្លួននៅក្នុងពេលអនាគត។ នេះជារបៀបផ្តល់មូលដ្ឋានមួយ វាពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់សាក្សីផ្សេងៗទៀត។ ដូច្នេះនៅពេលដែលដាក់មកសាក្សីដូច្នេះ

យើងអាចសួរជាសំណួរទៅកាន់សាក្សីទាំងអស់នោះ។

[១៤:១៦:២៤]

ការធ្វើដូច្នេះគឺវាមានភាពជឿជាក់សម្រាប់ក្រុមមេធាវីការពារក្តី។ យើងចង់ឲ្យសហព្រះរាជអាជ្ញាដាក់ឈ្មោះនូវសាក្សីដែលខ្លួនយល់ថាអាចមកផ្តល់ជាមូលដ្ឋានសម្រាប់ការិយាល័យរបស់ខ្លួន។ ប្រសិនបើសហព្រះរាជអាជ្ញាប្រកាសនៅពេលណាមួយថា វាអាស្រ័យទៅនឹងភាពពាក់ព័ន្ធនៃសក្ខីកម្មរបស់សាក្សីដទៃៗទៀតនោះវាមិនអីនោះទេ។ បានន័យថា គាត់បានបង្កើតមូលដ្ឋាននេះរួចទៅហើយ។ យើងមិនជំទាស់ទេ ប្រសិនបើអនុវត្តនីតិវិធីដូច្នេះ។ យើងស្វាគមន៍ទៅលើការធ្វើដូច្នេះ។

[១៤:១៧:១៤]

យើងដឹងហើយថា សហព្រះរាជអាជ្ញាគាត់បានរៀបចំការងារចោទប្រកាន់របស់ខ្លួនជាច្រើនឆ្នាំមកហើយ។ ហើយគាត់គួរតែដឹងអំពីចំណុចនៃការងារទាំងអស់នេះ។ សហព្រះរាជអាជ្ញាមួយចំនួនគាត់មកពីខាងប្រព័ន្ធច្បាប់ខំមិនឡូ។ គាត់គួរតែដឹង។ យើងមិនជំទាស់ទៅលើឯកសារទេ តែយើងជំទាស់ទៅលើការបង្កើតមូលដ្ឋានក្នុងការបង្ហាញភស្តុតាង។ មិនថាយើងមកពីប្រព័ន្ធខំមិនឡូ ឬស៊ីវិល្ បនោះទេ យើងត្រូវតែធ្វើយ៉ាងណាបង្ហាញនូវយថាភាព ភាពអាចទុកចិត្តបាន និងភាពពាក់ព័ន្ធ។ ហើយយើងមិនមែនថា ទុកឲ្យចៅក្រមពិចារណានៅចុងក្រោយនៃដំណាក់កាលនៃសវនាការនោះទេ។ យើងត្រូវតែចាក់បញ្ចូលគ្រប់ឯកសារទាំងអស់ រួមទាំងសម្ភារៈផ្ទះបាយផងដែរ។ យើងមិនអាចធ្វើដូច្នេះនោះទេ។ ប្រសិនបើយើងដាក់ឯកសារនិងសាក្សី ជាពិសេសដាក់បន្ទុកមកលើជនជាប់ចោទនោះ គឺជនជាប់ចោទគួរតែមានសិទ្ធិដែលខ្លួនទទួលបាន ដែលសិទ្ធិនេះគឺថា ត្រូវតែបង្ហាញភស្តុតាងនិងឯកសារជូនគាត់ឲ្យបានគ្រប់គ្រាន់ ហើយធ្វើយ៉ាងណាឲ្យបង្ហាញទៅដល់សវនាការ ដើម្បីឲ្យសវនាការយល់ថាឯកសារនោះគឺមានយថាភាព និងអាចទុកចិត្តបាន។

[១៤:១៨:៣០]

សារទូរលេខ។ ខ្ញុំមានការជំទាស់ដូចតែមុនអ៊ីចឹង។ ខ្ញុំមិននិយាយឡើងវិញទេ។ គឺខ្ញុំមានការជំទាស់ដូចគ្នា។ សារទូរលេខរបស់បក្សកុម្មុយនីស្តកម្ពុជា យើងខ្ញុំគិត សូមលើកឡើងថា មិនអាចទទួលយកបានទេលើកលែងតែសហព្រះរាជអាជ្ញា អាចបង្ហាញពីយថាភាព ភាពទុកចិត្តបាន និងភាពពាក់ព័ន្ធនៃឯកសារនីមួយៗ ជាពិសេសនៅពេលដែលយើងមើលទៅលើសាទូលេខទាំងអស់នេះ ដែលនឹងបង្ហាញជូនយើង។ សហព្រះរាជអាជ្ញាតាមរយៈសាក្សីនីមួយៗ និងជាក់លាក់ នឹងធ្វើការបង្ហាញសាលាដំបូងថា

តើសាទូរលេខនេះ បង្កើតតាមរបៀបណា? ហើយបញ្ជូនពីលើមកក្រោម ពីក្រោមទៅលើតាមរបៀបណា?

ផ្អែកតាមការបង្ហាញដូច្នេះ គឺអង្គជំនុំជម្រះអាចសម្រេចបាន។ ដូច្នេះ នៅក្នុងករណីណាក៏ដោយប្រសិនបើបង្ហាញដូច្នេះនោះ អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការទទួលយកសាទូរលេខទាំងអស់នេះ ហើយនៅចុងក្រោយនឹងអាចសម្រេចបានទៅលើកត្តាមួយចំនួនដែលថា អាចផ្តល់ទម្ងន់ទៅលើសារទូរលេខទាំងអស់នេះ។ ដូច្នេះដើម្បីសន្សំពេលវេលា ខ្ញុំមិននិយាយឡើងវិញនោះទេ។

[១៤:១៩:៤៦]

ចំពោះចម្លើយរបស់ជនសង្ស័យម្តង។ ខ្ញុំ-- ពេលដែលខ្ញុំផ្អាកនេះមិនមែនថា ខ្ញុំទុកពេលគិតនោះទេ។ នៅពេលដែលយើងនិយាយអំពីជនសង្ស័យផ្តល់ចម្លើយ នៅពេលដែលយើងនិយាយអំពីចម្លើយ គឺចម្លើយដែលផ្តល់ជូនសហចៅក្រមស៊ើបអង្កេត។ ដូច្នេះថាតើយើងកំណត់វាថាជាចម្លើយនេះ គឺយ៉ាងម៉េច? បានន័យថាចម្លើយ ដែលគេប្រមូលបាន សេចក្តីប្រកាសដែលគេមូលបានក្នុងពេលថ្លែងសេចក្តីសារព័ត៌មាន ឬនៅក្នុងរបាយការណ៍ ឬក៏ការលើកឡើងទៅដល់អ្នកសារព័ត៌មាន ឬក៏សរសេរនៅក្នុងសៀវភៅ។ ដូច្នេះចំពោះសេចក្តីប្រកាស ឬចម្លើយរបស់ជនសង្ស័យទាំងអស់នេះ វាជាប្រភេទឯកសារមួយទូលំទូលាយណាស់។

[១៤:២០:៣៦]

យើងសូមឲ្យបញ្ចូលផងដែរ ដរាបណាវាបានធ្វើឡើងស្របតាមវិធាន៨៧(៣)(គ) លោក អៀង សារី ក្នុងករណីនេះ គួរតែមានសិទ្ធិក្នុងការតទល់ជាមួយនឹងអ្នកនិពន្ធឯកសារទាំងអស់នេះ។ ឧទាហរណ៍ ប្រសិនបើលោក ហេដឌ័រ ជាមួយនឹង អេលីហ្សាប៊ែត បេកឃ័រ ជួបសម្ភាសជាមួយនឹងលោក អៀង សារី នោះ សេចក្តីប្រកាសមុនពេលដែលគេប្រើប្រាស់នៅក្នុងតុលាការនេះ គឺសេចក្តីប្រកាសទាំងអស់នោះ គួរតែយើងហៅលោក ហេដឌ័រ ហើយនិង អេលីហ្សាប៊ែត បេកឃ័រ មកផ្តល់ជាចម្លើយ។

[១៤:២១:២៨]

ដរាបណា សេចក្តីប្រកាសនេះជាឯកសារដើម ដូចជាថាសំណួរចម្លើយៗឲ្យឃើញទាំងអស់គ្នា គឺភាពអាចទុកចិត្តបាននៃឯកសារនោះ គឺយើងអាចទទួលយកបាន។ ឧទាហរណ៍ យើងមិនដឹងថា តើសំណួរដែលគេសួរនោះ អ្នកសារព័ត៌មានសួរនោះ វាជាសំណួរដឹកមុខ នាំមុខ ឬវាសំណួរសួរឆ្លើយ? ដូច្នេះនៅពេលដែលយើងមើលទៅលើវិធីសាស្ត្រសួររបស់លោក ហេដឌ័រ គឺលោក ហេដឌ័រ នោះ គាត់

ពន្យល់សិននូវអ្វីដែលគាត់យល់ បន្ទាប់មកគាត់ស្នើសុំឲ្យអ្នកដែលគាត់សម្ភាសនោះគឺឆ្លើយ។ ដូច្នេះ វាហាក់ដូចជាគាត់នឹងបង្ហាញមតិទស្សនៈរបស់គាត់ ហើយឲ្យជនម្នាក់គាត់ឆ្លើយតបទៅលើមតិទស្សនៈរបស់គាត់។

ដូច្នេះប្រសិនបើយើងឃើញសេចក្តីប្រកាស យកសេចក្តីប្រកាសទាំងអស់នេះ យើងមកប្រើប្រាស់ យើងគួរតែអញ្ជើញអ្នកនិពន្ធនោះមកផ្តល់ចម្លើយឲ្យយើងបានដឹង។ ដូច្នេះ អ្វីដែលគេមិនសរសេរចូលនៅក្នុងសេចក្តីប្រកាស ពេលខ្លះទៅវាអាស្រ័យទៅលើបរិបទ។ អត្ថបទសារព័ត៌មាន នៅពេលដែលយើងមានអត្ថបទមួយនោះ វាមិនមានន័យថា វាត្រូវនឹងពិតប្រាកដគ្រប់បែបយ៉ាងនោះទេ។

[១៤:២២:៤២]

យើងខ្ញុំសូមលើកឡើងសន្និដ្ឋានថា យើងគួរតែយក អញ្ជើញអ្នកនិពន្ធនោះ អ្នកនិពន្ធនូវសេចក្តីប្រកាសទាំងអស់នេះមកសួរដេញដោល។ ចំពោះសេចក្តីប្រកាស សេចក្តីដកស្រង់ ដែលយើងហៅថាវាស្ថិតនៅក្នុងចង្កោមនៃសេចក្តីប្រកាសរបស់ជនសង្ស័យនេះ គួរតែដកចេញដូចគ្នា។ លើកលែងតែលក្ខខណ្ឌនៃភាពអាចទទួលយកបាន វាមាន។ ដូច្នេះបានន័យថា លើកលែងតែយើងអញ្ជើញអ្នកនិពន្ធនេះមកផ្តល់ជាចម្លើយជូនយើង។ ប្រសិនបើអ្នកនិពន្ធនោះ គាត់មិនបានថតសំឡេងនៅពេលនោះ មិនមានកំណត់ហេតុនៅពេលដែលគាត់សួរនោះ មិនអីទេ។ ដូច្នេះចំណុចនេះវាមិនមានន័យថាយើងមិនអាចអញ្ជើញអ្នកនិពន្ធអ្នកទាំងអស់នេះមកទីនេះ ដើម្បីសួរដេញដោលនោះទេ។

[១៤:២៣:៤០]

អង្គជំនុំជម្រះជាអ្នកសម្រេចថាតើទម្ងន់ប៉ុនណា គួរតែផ្តល់ឲ្យសេចក្តីប្រកាស ឬក៏ចម្លើយរបស់ជនសង្ស័យទាំងអស់នេះ ដែលយើងនឹងយកមកបកស្រាយចំពោះជនជាប់ចោទ។

យើងត្រូវតែធ្វើការពិនិត្យអំពីលទ្ធភាពរបស់ជនជាប់ចោទក្នុងការតវ៉ាទៅលើសេចក្តីប្រកាសទាំងអស់នេះផង។

ឧទាហរណ៍ ចំពោះអ្នកប្រវត្តិសាស្ត្រនិងអ្នកនិពន្ធនោះ មិនថាគាត់ជាបុគ្គល អ៊ិច ឬបុគ្គល វ៉ាយនោះទេ គឺយើងគួរតែអញ្ជើញគាត់មក។ ទោះបីជាគាត់មិនមានការកត់ថតខ្សែអាត់ក៏ដោយ យើងអាចអញ្ជើញគាត់មកបាន ឲ្យផ្តល់ចម្លើយ ក្រោយមកអង្គជំនុំជម្រះជាអ្នកផ្តល់ទម្ងន់ទៅលើឯកសារ និងសេចក្តីប្រកាសទាំងអស់នេះ។ ដូចដែលខ្ញុំបានលើកឡើងអ៊ីចឹង យើងត្រូវតែមានលក្ខខណ្ឌចង្អុលបញ្ជាក់ឯករាជ្យមួយគាំទ្រនូវការទទួលយកសេចក្តីប្រកាសទាំងអស់នេះ ហើយធ្វើយ៉ាងណាអាចផ្ទៀងផ្ទាត់បាន

ហើយយើងនឹងអាចសម្រេចថាតើវាជាព័ត៌មានដែលគ្រាន់តែគេនិយាយឲ្យជនជាប់ចោទឆ្លើយតែប៉ុណ្ណោះ ឬយ៉ាងណា?

[១៤:២៤:៥១]

ចំពោះកំណត់ហេតុសួរចម្លើយ ស្ដាប់ចម្លើយរបស់ អូ.ស៊ី.អាយ.ជេ ក៏ ចៅក្រមស៊ើបអង្កេតវិញ គឺថាយើងគួរតែធ្វើយ៉ាងណាឲ្យកោះហៅបុគ្គលដែលផ្ដល់ចម្លើយនេះមកតទល់។ ដូច្នេះ ចំណុចនេះ គឺខ្ញុំនឹកឃើញអំពីករណីចម្លើយរបស់ ឌុច។ ចម្លើយដែលពាក់ព័ន្ធនឹង ឌុច មិនអាចយកមកទទួលយកជាភស្ដុតាងនោះបានទេ លើកលែងតែយើងឲ្យ ឌុច គាត់មកផ្ដល់ចម្លើយនៅទីនេះដោយឯករាជ្យ។ យើងដឹងហើយថា ជនជាប់ចោទគាត់-- ទោះបីជាយើងបានសម្រេចរួចហើយក៏ដោយទៅលើពិរុទ្ធភាពរបស់គាត់ យើងអាចអញ្ជើញគាត់មកទីនេះ ឲ្យគាត់ធ្វើជាសាក្សី ហើយឲ្យគាត់ហ្នឹងស្បថ ដើម្បីផ្ដល់ចម្លើយទៅដល់យើង។ ដូច្នេះ ដោយសារតែ ឌុច នេះគាត់មានវត្តមាន គាត់អាចមកផ្ដល់សក្ខីកម្មបាន មិនថាចម្លើយនេះផ្ដល់ជូនទៅសហចៅក្រមស៊ើបអង្កេត ឬក៏សំណួរចម្លើយដែលគាត់ផ្ដល់ជូនសហចៅក្រមស៊ើបអង្កេត ឬក៏សក្ខីកម្មដែលគាត់ឆ្លើយក៏ដោយ យើងត្រូវតែកោះអញ្ជើញ ឌុច នេះឲ្យមកផ្ដល់សក្ខីកម្ម។

[១៤:២៦:០៧]

យើងខ្ញុំសូមសន្និដ្ឋាននិងលើកឡើងថា ភស្ដុតាងដែលវាល្អបំផុតនោះ គឺចេញពីមាត់ ឌុច។ ដូច្នេះ យើងអញ្ជើញគាត់មក ឲ្យគាត់លើកឡើងថា តើគាត់ឯកភាពទេទៅលើចំណុចហ្នឹង? ហើយឲ្យគាត់ធ្វើអត្ថាធិប្បាយនិងរៀបរាប់ ដើម្បីឲ្យយើងអាចយកចម្លើយទាំងឡាយដែលគាត់បាននិយាយកាលពីអតីតកាលនោះ យកមកប្រើប្រាស់បាន។ ហើយប្រសិនបើ នៅពេលដែលយើងសួរដេញដោលគាត់នោះថាតើចម្លើយរបស់គាត់នោះ វាអាចមានសុពលភាពដែរឬទេ? ដូច្នេះ យើងខ្ញុំសន្និដ្ឋានសាជាថ្មី ត្រូវតែកោះអញ្ជើញ ឌុច មកផ្ដល់សក្ខីកម្មនៅទីនេះ បើមិនដូច្នោះទេ យើងមិនអាចទទួលយកចម្លើយ និងសេចក្ដីប្រកាសរបស់គាត់ធ្វើជាភស្ដុតាងនោះទេ។

[១៤:២៧:០៣]

ចំពោះកំណត់ហេតុស្ដាប់ចម្លើយទៅលើសាក្សី ខ្ញុំលើកឡើងសាជាថ្មីម្ដងទៀត ទោះបីលើកឡើងរួចហើយក៏ដោយ។ យើងឃើញមានការធ្វើសេចក្ដីសង្ខេបទៅលើកំណត់ហេតុសួរចម្លើយដោយអ្នកស៊ើបអង្កេត។ នៅទីនេះយើងមិនដូចប្រទេសបារាំងទេ មិនដែល-- នៅប្រទេសបារាំងគេមានមន្ត្រីនគរបាលយុត្តិធម៌ដែលបានបណ្ដុះបណ្ដាលយ៉ាងត្រឹមត្រូវ គេមានគំរូអត្ថបទ គំរូទម្រង់បែបបទដែលអាចប្រើប្រាស់

បាន។ នៅក្នុងប្រទេសនេះ យើងមានទម្រង់បែបបទផ្សេង វីធីសាស្ត្រផ្សេងក្នុងការស្តាប់ចម្លើយ ខុសពីទីកន្លែងផ្សេង។ ដូច្នេះ តម្លៃប្រតិចារឹក ឬក៏កំណត់ហេតុស្តាប់ចម្លើយនោះ គឺយ៉ាងម៉េច?

[១៤:២៧:៥៤]

សេចក្តីសង្ខេបទៅលើកំណត់ហេតុស្តាប់ចម្លើយ វាមិនឆ្លុះបញ្ចាំងទាំងស្រុងទៅលើចម្លើយរបស់សាក្សីនោះទេ។ ទោះបីជាខ្ញុំមិនធ្វើការនៅក្នុងប្រព័ន្ធស៊ីវិលឡក៏ដោយ។ ពេលខ្លះទៅនៅក្នុងប្រព័ន្ធច្បាប់ខំមិនឡូនោះ មេធាវីគេអាចក្រោកឈរឡើងថា គាត់មិនយល់ទេ មិនដឹងថាតើការដែលគេលើកឡើងសេចក្តីសង្ខេបនេះគឺយ៉ាងម៉េចនោះឡើយ។ យើងមិនមែនថា យើងកោះហៅអញ្ជើញសហចៅក្រមស៊ើបអង្កេតមកផ្តល់ចម្លើយថា តើគាត់នោះធ្វើសេចក្តីសង្ខេបយ៉ាងម៉េចនោះទេ? វាអាចមានករណីមួយចំនួនដែលថា នៅពេលដែលការថតខ្សែអាត់នោះ នៅពេលដែលចៅក្រមស៊ើបអង្កេតគាត់ស្តាប់ចម្លើយសាក្សីនោះ ពេលខ្លះទៅគាត់អាចយកសេចក្តីរៀបរាប់ទាំងស្រុករបស់សាក្សី ឬក៏គាត់ធ្វើជាលក្ខណៈសង្ខេបទៅលើភាពជាក់លាក់របស់សាក្សី។

[១៤:២៨:០៧]

ដូច្នេះមិនមែនថា នៅពេលដែលយើងមានខ្សែអាត់នោះ ឯកសារភស្តុតាងទាំងអស់ កំណត់ហេតុទាំងអស់នេះ វាល្អឥតខ្ចោះនោះទេ។ ហើយយើងមិនមែនថា សុំឲ្យយកប្រតិ-- កំណត់ហេតុខ្សែអាត់យកមកបង្ហាញឲ្យយើងគ្រប់ករណីទាំងអស់នោះទេ ប៉ុន្តែយើងគួរតែទុកលទ្ធភាពនេះ។ ដូច្នេះមិនមែនថាចៅក្រមណាមួយមានលទ្ធភាពល្អជាងចៅក្រមណាមួយនោះទៀតនោះឡើយ។ ដូច្នេះហើយសេចក្តីសង្ខេបនេះវាមិនមានតម្លៃពិតប្រាកដជាក់លាក់ទៅដូចកំណត់ហេតុដើមនោះឡើយ។ ដូច្នេះប្រសិនបើសាក្សីគាត់មិនអាចមកផ្តល់ចម្លើយបញ្ជាក់ឲ្យយើងបាននោះ ដើម្បីជាប្រយោជន៍នៃយុត្តិធម៌សាក្សីទាំងអស់នោះ យើងខ្ញុំសូមលើកឡើងថា យើងគួរតែយកកំណត់ហេតុដើមមិនមែនយកសេចក្តីសង្ខេបមកដាក់ចូលជាឯកសារនោះទេ។ ខ្ញុំជឿជាក់ថាខ្ញុំលើកឡើងចំណុចនេះយ៉ាងជាក់លាក់រួចហើយ មិនមែនថាខ្ញុំលើកឡើងដោយច្បោលទេ។

[១៤:៣០:២៥]

ចម្លើយអំពីប្រវត្តិរូបរបស់សាក្សីដែលគាត់ស្លាប់ទៅហើយ។ ចម្លើយ ឬក៏ប្រវត្តិរបស់គាត់ដែលអ្នកម្ចាស់ស្លាប់ទៅហើយ យើងក៏ជំទាស់រាល់ប្រវត្តិរូប ហើយសេចក្តីថ្លែងការណ៍ទាំងអស់នោះដែលបានធ្វើឡើង ដោយហេតុថាយើងមិនស្ថិតនៅក្នុងស្ថានភាពមួយដែលថា ក្នុងនាមលោក អៀង សារី យើង

អាចនឹងសួរដេញដោលបុគ្គលនោះបានទៀតទេ។ ហើយខ្ញុំជឿថាបញ្ហាទាំងអស់នេះ គឺពិតជានឹងកើតមានឡើង។ លោក លោកស្រីចៅក្រម នៅក្នុងរឿងក្តី០០១ យើងពិនិត្យមើលចំណុចនេះពីព្រឹកមិញនេះ ខ្ញុំនឹងមិននិយាយលម្អិតឡើងវិញនោះទេ។

អ.វ.ត.ក គឺបានកត់សម្គាល់ កត់ត្រាទុកនូវកំណត់ហេតុនៃនីតិវិធីកំណត់ត្រានៃសវនាការដេញដោលតទល់នោះ គឺការបង្ហាញខ្លួនជាបឋមក្តី សំណើសុំឱ្យមានកិច្ចស៊ើបសួរបន្ថែមដោយភាគី។ យើងសូមស្នើថាប្រភេទឯកសារទាំងអស់នេះ គឺមិនមានសារៈសំខាន់នោះទេ ដោយហេតុថា ខ្ញុំ យើងទាំងអស់គ្នាក្នុងនាមលោក អៀង សារី បានដាក់នូវសំណើសុំកិច្ចស៊ើបសួរបន្ថែម។ នៅក្នុងនោះយើងបានដាក់បញ្ចូលនូវបរិបទ ដែលបរិបទទាំងអស់នោះដែលថាយើងត្រូវធ្វើសំណើ ថាហេតុអីដែលយើងស្នើសុំដែលវាមានទិដ្ឋភាពប្រវត្តិសាស្ត្រដែលអ្នកទាំងអស់នោះ គឺថាឯកសារទាំងអស់នោះមិនមែនជាភស្តុតាងនោះទេ នេះជាជំហររបស់យើងៗ បានស្នើទៅចៅក្រមអង្កេត។ ឥឡូវនេះ វាត្រឡប់មកយើងវិញទៅដល់សហព្រះរាជអាជ្ញា ថា អូ៎នែ! នេះហើយជាភស្តុតាង។ ប៉ុន្តែយើងត្រូវចាំថា យើងនៅក្នុងដំណាក់កាលស៊ើបអង្កេតនៅឡើយកាលណោះ ហើយយើងបានស្នើសុំឱ្យមានកិច្ចស៊ើបសួរបន្ថែម ដោយសហចៅក្រមស៊ើបអង្កេត ដោយហេតុថាយើងមេធាវីការពារក្តីនេះមិនត្រូវបានអនុញ្ញាតឱ្យធ្វើការស៊ើបអង្កេតណាមួយនោះទេ។

[១៤:៣២:២៦]

ហើយយើងក៏ទទួលស្គាល់ថាដោយជាក់ស្តែងនោះគឺថាមិនមានទម្ងន់ណាមួយទេ ត្រូវតែឱ្យទម្ងន់ *ហេវ្វី* គឺថាមិនអាចទទួលយកបាននោះទេឯកសារទាំងអស់នោះ។ ដោយសារឯកសារដំណាក់កាលស៊ើបអង្កេត គឺថាសហព្រះរាជអាជ្ញាត្រូវពឹងផ្អែកលើឯកសារមួយចំនួនដែលមានតម្លៃ ដោយថាឯកសារទាំងនោះគឺមិនបានស្របទៅនឹងវិធាន៨៧(៣)(ក)នោះទេ។ មានវីដេអូរបស់ ប៊ី.ប៊ី.ស៊ី D299.1.46 នេះជាវីដេអូមួយដែលគេអះអាងថា ដែលថាគេសម្ភាសលោក នួន ជា ដែលថានៅក្នុងនោះយើងមិនមានបទសម្ភាសន៍ទាំងមូលនោះទេ ហើយយើងក៏មិនមានខ្មែរជាសម្តីដើមនោះដែរ ដែលបញ្ជាក់ថាគាត់និយាយពិតប្រាកដនូវអ្វីនោះទេ ប៉ុន្តែយើងបានជាភាសាមួយដែលគេបកប្រែពីភាសាដើម។

[១៤:៣៣:៣២]

ហើយតាមពិតយើងខ្ញុំស្នើតុលាការថា ភស្តុតាងបែបនេះ ជាវីដេអូមួយនេះ គឺមិនត្រូវបានទទួលស្គាល់ដោយតុលាការនោះទេ ពីព្រោះថាយើងមិនអាចស្វែងបរិបទថា តើវាត្រឹមត្រូវប៉ុនណានោះទេ?

ថាតើការសម្ភាសនោះវាត្រឹមត្រូវ ដែរឬទេនោះទេ? នៅអតិបរមានោះ គឺថាតុលាការត្រូវតែធ្វើសវនាការលោក នួន ជា នៅឱ្យគាត់ឆ្លើយជាភាសារបស់គាត់ផ្ទាល់ ដោយថាគាត់នៅទីនេះ។ ពេលនោះទើបតុលាការមានជំហរត្រឹមត្រូវ ថាតើបទសម្ភាសន៍ទាំងមូលនោះយ៉ាងដូចម្ដេច? ឬក៏គេស្រង់តែចំណុចខ្លះនេះបទសម្ភាសន៍នោះ ឬក៏ជាលក្ខណៈដែលហៅថាជា *ម៉ុងតា* ជាសេចក្ដីសន្និដ្ឋានបង្កើតនូវសេចក្ដីអត្ថាធិប្បាយដែលបុគ្គល ដែលថាជាអ្នកធ្វើវីដេអូនោះ។

[១៤:៣៤:២៤]

លោក អៀង សារី គាត់មានប្រវត្តិរូបរបស់គាត់ D199/26.1.8 ជាថ្មីម្ដងទៀតសហព្រះរាជអាជ្ញានឹងត្រូវនាំមកនូវភស្តុតាងបន្ថែមទៀតដែលថា តើប្រវត្តិរូបនេះធ្វើដោយរបៀបណា? នៅពេលណា? នៅក្នុងកាលៈទេសៈណាមួយ ដែលថារកឃើញនៅកន្លែងណា? ថាតើគួរទុកចិត្តប៉ុន្មាន?... ។ល។

ដូច្នេះដោយហេតុថា វាមានចំណាងជើងមួយចំនួនថាប្រវត្តិរូបរបស់ អៀង សារី មិនមែនមានន័យថា ជាការពិតរបស់លោក អៀង សារី នោះទេ ដែលថាតុលាការត្រូវតែទទួលនោះទេ។ នៅទីបំផុតលោក លោកស្រីចៅក្រម ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះការចាប់អារម្មណ៍នៅលើទឡ្ហីករណ៍របស់ខ្ញុំហើយខ្ញុំពិនិត្យមើលថា ខ្ញុំលើសពេលបន្តិច។ ដូច្នេះខ្ញុំចូលទៅដល់ឯកសារថ្មីៗ។

[១៤:៣៥:២១]

ចំណុចមួយជាឧទាហរណ៍នោះគឺ *អ៊ី មូរាស៊ីម៉ា* គឺដែលគេសរសេរថា "នួន ជា-- *យ៉ាំង* នួន ជា"។ ឯកសារដែលបានលើកឡើងដោយ *អ៊ី មូរាស៊ីម៉ា* នោះ ថាដែលលើកឡើងពីប្រវត្តិរបស់ នួន ជា ជាប្រវត្តិសាស្ត្រនោះ។ និយាយពីវ័យកុមារ វ័យក្មេងរបស់ នួន ជា ឯកសារនេះមិនមាននៅក្នុងឯកសារ *ហ្សាយឡែប* របស់តុលាការទេ ហើយយើងមិនអាចរកអត្តសញ្ញាណទៅទៀតផង ហើយក៏មានលេខ ERN ទៅទៀត។ ហើយយើងមិនដឹងថា តើត្រឹមត្រូវ ឬមិនត្រឹមត្រូវ? បើសិនជាតុលាការយល់ថានេះមិនត្រូវសូមអភ័យទោសបើសិនជាយល់ថា ខ្ញុំធ្វើឱ្យខាតពេលបន្តិចនោះ ប៉ុន្តែខ្ញុំរកហើយមិនឃើញមានទេនៅក្នុង *ហ្សាយឡែប*។ ខ្ញុំមិនអាចផ្ដល់យោបល់ទៅលើឯកសារនេះបានទេ ដោយសារថាយើងមិនអាចបើកមើលបាន។

[១៤:៣៦:១៨]

ហេតុដូច្នេះហើយសូមតុលាការជ្រាបជាចុងក្រោយថា យើងស្នើថា ឯកសារប្រភេទនេះ គឺស្ថិតនៅក្នុងប្រភេទមួយចំនួនដែលយើងជំទាស់ពីខាងដើម ដែលហើយអ្នកតាក់តែងម្ចាស់ឯកសារត្រូវតែបាន

អញ្ជើញមក ដើម្បីឲ្យតុលាការនិងភាគីបានដេញដោល។

លោក លោកស្រីចៅក្រមជ្រាបហើយ យើងបានដាក់ជូននូវសំណើមួយចំនួនដែលទាក់ទងទៅនឹងភាពទទួលយកបាននូវឯកសារ។ ដោយសារថាពេលវេលារបស់ខ្ញុំវាអស់ហើយ ដូច្នេះខ្ញុំមិននិយាយលម្អិតទេ។ ដូច្នេះមតិយោបល់ដែលខ្ញុំបានដាក់ជូនដោយសេចក្ដីយោងនោះគឺថា រាល់កត្តាអង្គច្បាប់ និងអង្គហេតុដែលបានលើកឡើង ដែលទាក់ទងទៅនឹងការទទួលយកនៃភស្តុតាងតុលាការនេះ ត្រូវតែពិចារណាឲ្យល្អិតល្អន់។ ហើយក៏សូមអរគុណអង្គជំនុំជម្រះ លោក លោកស្រីចៅក្រមដែលបានផ្ដល់ពេលឲ្យខ្ញុំបាទ។ សូមអរគុណ។

[១៤:៣៧:១៩]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ឥឡូវដល់ពេលសមល្មមនឹងសម្រាប់ហើយ ហើយអង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរសវនាការ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:១៧ នាទី ដល់ម៉ោង ១៥:០៥ នាទី)*

[១៥:០៥:២៩]

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ!

សូមអញ្ជើញមេធាវី!

**លោក អេនឌ្រូ អ៊ីនួហ្វ៊ី៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំគ្រាន់តែចង់ជម្រាបអង្គជំនុំជម្រះថា យើងទទួលការជូនដំណឹងមកថា លោក នួន ជា នេះកំពុងតែគេងនៅក្នុងបន្ទប់ខាងក្រោមនោះ។ ដូច្នេះហើយប្រសិនបើគាត់គេងកំពុងតែសម្រាន្ត អ៊ីចឹងគឺហាក់ដូចជាគាត់ហ្នឹងមិនបានចូលរួមពីចម្ងាយនៅក្នុងសវនាការយើងទេ។ ដូច្នេះខ្ញុំសូមថា គួរតែអនុញ្ញាតឲ្យគាត់នោះទៅមន្ទីរឃុំឃាំងទៅ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញា!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ដូចលោក លោកស្រីចៅក្រមបានជ្រាបហើយនៅក្នុងមន្ទីរឃុំឃាំង គឺមិនមានវីដេអូ ដើម្បីបញ្ចាំងសម្រាប់ជនជាប់ចោទឲ្យតាមដានសវនាការនោះទេ ហើយក៏មិនអាចឲ្យគាត់តាមដានមើលអេក្រង់ទូរទស្សន៍ ឬទូរស័ព្ទផងដែរ។ មិនថា លោក នួន ជា សម្រាន្តនៅទីនោះ ឬក៏មិនសម្រាន្តនោះទេ គឺវាអាស្រ័យទៅគាត់ គឺគាត់តម្រូវឲ្យចូលរួម និងមានវត្តមាននៅក្នុងសវនាការនៅក្នុងពេលនេះ លើកលែងតែមានកាលៈទេសៈពិសេសណាមួយ ដែលទាមទារឲ្យគាត់ធ្វើក្រៅពីនេះ។

[១៥:០៧:២២]

ដូច្នេះនៅក្នុងចំណុចនេះគឺថា វាជាឱកាសសម្រាប់គាត់ ឲ្យគាត់តាមដាននីតិវិធីពីចម្ងាយ ហើយនៅពេលដែលគាត់ក្រោកពីសម្រាន្តវិញ អាចគាត់នៅតាមដានដដែល។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណសហព្រះរាជអាជ្ញា។ អង្គជំនុំជម្រះកត់សម្គាល់ថា អ្វីដែលលើកឡើងដោយសហមេធាវីការពារក្តី នួន ជា ហាក់ដូចជាដដែលៗ។ ដូច្នេះអង្គជំនុំជម្រះមិនសម្រេចអ្វីទេ ក្រៅពីតម្កល់នូវសេចក្តីសម្រេចរបស់ខ្លួន ដែលបានសម្រេចរួចហើយ។ នេះជាវិធានការរបស់តុលាការតម្រូវឲ្យជនជាប់ចោទចូលរួមនៅក្នុងកិច្ចដំណើរការសវនាការ តាមនីតិវិធីដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង។ យើងមិនអនុញ្ញាតឲ្យនិយាយអ្វីទៀតទេ។

សូមប្រគល់វេទិកាទៅមេធាវីការពារក្តី ខៀវ សំផន។

[១៥:០៨:៣៦]

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ។ សូមគោរពអង្គសវនាការ។

ខ្ញុំបាទសូមធ្វើសេចក្តីថ្លែងទាក់ទងទៅនឹងការទទួលយកនូវភស្តុតាងដូចតទៅ៖ កាលពីព្រឹកមិញខ្ញុំបានបញ្ជាក់ថា យើងទាមទារឲ្យមានការដេញដោលជាក់លាក់ និងតទល់គ្នានៅចំពោះមុខអង្គជំនុំជម្រះលើឯកសារនីមួយៗឲ្យបានច្បាស់លាស់។ ហើយខ្ញុំបាទក៏បានបង្ហាញពីជំហរថា នឹងធ្វើការជំទាស់រាល់ការសន្មតជាមុន អំពីភាពទទួលយកបាន រួមទាំងឯកសារដែលយោងនៅក្នុងកំណត់សម្គាល់ចុងទំព័រនៃ

ដីកាដំណោះស្រាយនោះផងដែរ។ នៅរសៀលនេះ យើងត្រូវបានស្នើឲ្យធ្វើការកត់សម្គាល់លើឯកសារយោង ដែលមានកំណត់សម្គាល់ចុងទំព័រនៃដីកាដំណោះស្រាយ និងកថាខណ្ឌទាំងឡាយដែលពាក់ព័ន្ធទៅនឹងសាវតារប្រវត្តិសាស្ត្រ។

[១៥:០៩:៥៤]

ដូច្នេះ សវនាការនេះគឺជាឱកាសមួយសម្រាប់ខ្ញុំក្នុងការបំភ្លឺ និងបង្ហាញថា ការអះអាង ទាំងនេះសុទ្ធតែមានហេតុផលត្រឹមត្រូវ។ ខ្ញុំបាទសូមបំភ្លឺការអះអាងរបស់ខ្ញុំ ដោយសូមលើកជាឧទាហរណ៍ អំពីបញ្ហាដែលយើងបានជួបប្រទះ ពេលដែលយើងពិនិត្យទៅលើឯកសារទាំងឡាយដែលមាននៅក្នុងកំណត់សម្គាល់ចុងទំព័រនៃដីកាដំណោះស្រាយជាទូទៅ ហើយយើងក៏ឃើញក្នុងផ្នែកដែលពាក់ព័ន្ធនឹងសវនាការប្រវត្តិសាស្ត្រដូចតទៅ៖

ចំណុចទីមួយ ឯកសារមួយចំនួន មិនទាំងមាននៅក្នុងសំណុំរឿងស៊ើបអង្កេតផង។ ឧទាហរណ៍ កំណត់សម្គាល់ជើងទំព័រលេខ៣៦, ៥៥ កំណត់សម្គាល់ជើងទំព័រលេខ៤១, ២០ និងមួយផ្នែកនៃជើងទំព័រលេខ៣៣ ជាដើម។

ចំណុចទីពីរ យើងខ្ញុំកត់សម្គាល់ឃើញថា ចំពោះឯកសារដែលមានស្រាប់នៅក្នុងសំណុំរឿង ឯកសារយោងនោះមិនគួរឲ្យជឿជាក់បាន។ ឧទាហរណ៍ ឯកសារយោងមិនត្រូវគ្នាទាល់តែសោះនឹងអ្វីដែលសរសេរក្នុងកថាខណ្ឌ គឺថាឯកសារយោងនិយាយផ្សេង គាត់សង្ខេបនៅក្នុងកថាខណ្ឌនោះ មានន័យផ្សេង។ ឧទាហរណ៍ ឯកសារ D288/4.23.1 កំណត់សម្គាល់ជើងទំព័រលេខ៣៦, ៥៨ និងកំណត់សម្គាល់ជើងទំព័រលេខ៥៦, ៥៩។

ឯកសារជាភាសាបារាំង ជួនកាលទៅត្រូវគ្នាជាមួយនឹងឯកសារជាភាសាអង់គ្លេស ក៏ប៉ុន្តែអត់ត្រូវគ្នាជាមួយនឹងឯកសារជាភាសាខ្មែរ។ ប៉ុន្តែឯកសារតែមួយកត់សម្គាល់តែមួយ ខ្លឹមសារខុសគ្នា។ ឧទាហរណ៍ នៅក្នុងឯកសារ D288/4.25/1 ត្រង់កំណត់សម្គាល់ជើងទំព័រលេខ៣៦,៥៩ និងកំណត់សម្គាល់ជើងទំព័រលេខ៣៦, ៦៣។

[១៥:១៣:០៣]

ចំណុចមួយទៀត ឯកសារមួយចំនួនមិនមានចុះកាលបរិច្ឆេទទេ និងមានការចង្អុលបង្ហាញដែលគិតថាវាជាឯកសារពីសម័យកម្ពុជាប្រជាធិបតេយ្យនោះ។ តែគ្មានអ្វីបញ្ជាក់ឯកសារនេះគឺថា វាចេញភាសាដើមជាភាសាខ្មែរ ប៉ុន្តែត្រូវបានបកប្រែជាភាសាអង់គ្លេស។ ហើយឯកសារនោះអាចបកប្រែ

ដោយអ្នកបកប្រែនៅតុលាការយើងនេះ ឬក៏អ្នកបកប្រែផ្សេងទៀត។ ឧទាហរណ៍ ឯកសារ D366/7.1.559 ត្រង់កំណត់សម្គាល់ជើងទំព័រលេខ២៥ ជាដើម។

ខ្ញុំសូមបញ្ជាក់ជូនត្រង់នេះថា ឯកសារដែលមានជាភាសាដើម មានជាភាសាខ្មែរ ក៏ប៉ុន្តែតាមភាពពិតភាសាខ្មែរនោះពុំមាននៅក្នុងសំណុំរឿងទេ បែរជាមានតែភាសាអង់គ្លេស។ ហើយដល់តែពេលដើម្បីឱ្យបានទៅជាភាសាខ្មែរវិញ ត្រូវបកពីយកអង់គ្លេសហ្នឹងបកជាខ្មែរវិញ។ អ៊ីចឹង អាភាពដើមនៃឯកសារជាភាសាខ្មែរនោះគឺអត់មាន។

[១៤:១៤:៤៤]

ចំណុចទីបួន ឯកសារមួយចំនួនមិនពាក់ព័ន្ធ និងមិនមែនជាភស្តុតាងទេ។ ឧទាហរណ៍ ឯកសារដែលមានលេខ D160 និង D160/2 ត្រង់កំណត់សម្គាល់ជើងទំព័រលេខ២៦ និងឯកសារD84/1 ត្រង់កំណត់សម្គាល់ជើងទំព័រលេខ៤៦,៣៧។

ឥឡូវនេះ ចំពោះកំណត់សម្គាល់ចុងទំព័រ ដែលពាក់ព័ន្ធនឹងបរិបទប្រវត្តិសាស្ត្រជាទូទៅ ឯកសារដែលមាននៅកន្លែងនេះ គឺច្រើនបែបច្រើនយ៉ាងណាស់ យើងខ្ញុំសូមបែងចែកជាបីប្រភេទ ជាលក្ខណៈបំព្រួញ។ ប្រភេទទីមួយ គឺទាក់ទងទៅនឹងឯកសារបច្ចុប្បន្នភាពនៃកម្ពុជាប្រជាធិបតេយ្យ ដែលជាឯកសារពាក់ព័ន្ធពីឆ្នាំ១៩៧០ រហូតដល់ឆ្នាំ១៩៧៩ ដែលជាឯកសាររបស់ បក្សកុម្មុយនីស្តកម្ពុជា ឬក៏ឯកសាររបស់រណសិរ្សរួបរួមជាតិ ឬក៏រាជរដ្ឋាភិបាលរួបរួមជាតិ ដែលត្រូវបានប្រមូលក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំនោះ។

[១៥:១៦:៣២]

ប្រភេទឯកសារទីពីរ គឺជាឯកសារសាធារណៈ។ ឯកសារនេះរួមមានអត្ថបទសារព័ត៌មាន អត្ថបទសម្ភាសផ្សេងៗក្នុងអំឡុងពេល និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ មានសៀវភៅ និងអត្ថបទសរសេរដោយអ្នកស្រាវជ្រាវពីបណ្ដាសកលវិទ្យាល័យនានាជាដើម។

ឯកសារទីបី ប្រភេទឯកសារទីបី គឺជាឯកសារតុលាការ។ កំណត់ហេតុស្ដាប់ចម្លើយ មានដូចជាកំណត់ហេតុស្ដាប់ចម្លើយសាក្សីក្នុងពេលស៊ើបអង្កេត ប្រតិចារឹក សក្ខីកម្ម ឬក៏សក្ខីកម្មដែលធ្វើឡើងសាក្សីក្នុងពេលសវនាការនៅក្នុងសំណុំរឿង០០១ ជាដើម។

តទៅនេះ ខ្ញុំបាទសូមពន្យល់ពីចំណាត់ថ្នាក់ឯកសារនីមួយៗដែលយើងខ្ញុំស្នើឡើងឱ្យពិស្ដារថែមទៀត។

ឯកសារដែលទាក់ទងទៅនឹងបច្ចុប្បន្នភាពនៃរបបកម្ពុជាប្រជាធិបតេយ្យ។

ក) ទីមួយ ចំណុច(ក) ការខ្វះខាតព័ត៌មានទាក់ទងទៅនឹងរបៀបរបបរក្សាទុកឯកសារក្រោយព្រឹត្តិការណ៍នេះ។ ឯកសារសម័យថ្មីទាំងអស់នេះគឺ បានរកឃើញនិងមានបញ្ចូលនៅក្នុងកំណត់ជើងទំព័រនៃដីកាដំណោះស្រាយ ដែលបានមកពីមជ្ឈមណ្ឌលឯកសារ ឌី.ស៊ី.ខេម។

ចំពោះឯកសារខ្លះ ខាងមេធាវីការពារមិនមានព័ត៌មានទាក់ទិនទៅនឹងរបៀបដែលមជ្ឈមណ្ឌលឯកសារ ឌី.ស៊ី.ខេម នេះប្រមូលចងក្រង នោះទាល់តែសោះ។

[១៥:១៨:៥៤]

ឧទាហរណ៍ ឯកសារ D313/1.2.258, ឯកសារ D366/7.1.559, ឯកសារ RI20.31, ឯកសារD366/7.1.7។ ជួនកាលឯកសារទាំងនោះមិនមានទាំងចុះកាលបរិច្ឆេទទៀតផង។ ឧទាហរណ៍ ឯកសារ D366/7.1.559 ជាដើម។ សម្រាប់ឯកសារដទៃទៀត កំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់លោក ឆាំង យុ ព្រមទាំងវេបសាយនៃមជ្ឈមណ្ឌលឯកសារ (ឌី.ស៊ី.ខេម) អាចឲ្យយើងទទួលបានការចង្អុលបង្ហាញខ្លះៗអំពីប្រភពឯកសារ។ ប៉ុន្តែព័ត៌មានទាំងនោះនៅមានខ្វះចន្លោះដដែល។ ឧទាហរណ៍ ឯកសារដែលបានមកពី *ស្វីដឌីស ខូឡិចស៊ិន* (*Swedish Collection*) សម្រងឯកសាររបស់ប្រទេសស៊ុយអែត យើងមានព្រឹត្តិប័ត្រព័ត៌មានបីទទួលបានពី ហ្វាំង (FUNK) រណសិរ្សរួបរួមជាតិ។

អ៊ីចឹងសូមសួរថា តើកម្រងឯកសារស៊ុយអែតនេះត្រូវបានចងក្រងយ៉ាងដូចម្តេច? ដោយរបៀបណា? ដោយអ្នកណា? តើឯកសារទាំងនោះត្រូវបានប្រមូលតាមរយៈអង្គការស្ថាប័ន បុគ្គល បុគ្គលណាខ្លះនៅពេលណា? តើឯកសារទាំងអស់នោះត្រូវបានរក្សាទុកក្នុងលក្ខខណ្ឌដូចម្តេចរហូតដល់ពេលបញ្ជូនមកកាន់មជ្ឈមណ្ឌលឯកសារ (ឌី.ស៊ី.ខេម) នេះ?

[១៥:២១:៥៧]

ឯកសារដែលបានមកពីបណ្ណសារដ្ឋាននៃគុកទួលស្លែង យើងមានទស្សនាវដ្តីទង់បដិវត្តចំនួនប្រាំលេខ និងសេចក្តីណែនាំរបស់បក្សកុម្មុយនីស្តចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៦។ ទស្សនាវដ្តីទាំងប្រាំលេខនេះ ខ្ញុំបាទសុំមិនអានឯកសារនោះទេ។

សេចក្តីណែនាំរបស់បក្សកម្មុយនីស្តកម្ពុជាចំនួនមួយច្បាប់នោះ មានលេខឯកសារ D366/7.1 .61 ខាងមេធាវីការពារក្តីសូមឲ្យ-- សុំទទួលបាន-- សុំទទួល-- សុំអាចទទួលបានព័ត៌មានឲ្យបានច្រើនថែមទៀត លើព័ត៌មានដែលទទួលបានពីបណ្ណសារដ្ឋាននៃគុកទួលស្លែង។ តើឯកសារទាំងអស់នោះស្ថិត

នៅទួលស្លែងពីឆ្នាំ១៩៧៩ ហើយស្ថិតនៅក្នុងទីនោះរហូតដល់ពេលមជ្ឈមណ្ឌលឯកសារ ឌី.ស៊ី.ខេម ទៅប្រមូលយកទុក ឬមួយយ៉ាងណា?

[១៥:២៣:៣៨]

ប្រសិនបើដូច្នេះ ហេតុដូចម្ដេចបានជាឯកសារដែលលើកឡើងខាងលើនេះបែរជាថិតនៅក្នុងបណ្ណសារដ្ឋាននៃគុកទួលស្លែងទៅវិញ? បានន័យថា ចង់បញ្ជាក់ថា តើគុកទួលស្លែងបានទទួលឯកសារនេះដោយរបៀបណាដែរ? ឬមួយក៏ឯកសារទាំងអស់នោះបានមកពីប្រភពណាវិញ? តើនៅពេលដែលឯកសារទាំងអស់នោះត្រូវបានបញ្ជូនទៅកាន់បណ្ណសារដ្ឋាននៃគុកទួលស្លែងនោះនៅពេលណាដែរ? ហើយអ្នកណាជាអ្នកបញ្ជូនឯកសារទាំងអស់នោះទៅកាន់ទីនោះ?

[១៥:២៤:៣០]

មួយប្រភេទទៀតទាក់ទងទៅនឹងឯកសារដែលបាន-- ដែលចេញមកពីប្រភពក្រសួងមហាផ្ទៃ។ លោក ឆាំង យុ បានបង្ហាញជូនសហចៅក្រមស៊ើបអង្កេតថា ឯកសារសំខាន់មួយចំនួនធំត្រូវបានខាងវៀតណាមប្រមូលទុកមុននឹងដាក់នៅក្រសួងមហាផ្ទៃ។ តើគេមានដឹងទេថា ឯកសារណាខ្លះ? តើមានដឹងទេថា វៀតណាមបានប្រមូលយកឯកសារនៅទីណា? ដោយប្រមូលពីកន្លែងណា? លោក ឆាំង យុ គាត់បានចង្អុលបង្ហាញថា ខ្មែរយើងបានជួយពួកវៀតណាមក្នុងការប្រមូលឯកសារទាំងនោះទុក។ លោកបានស្នើសុំឲ្យដាក់ឈ្មោះ ជាភាសា-- ដាក់ឈ្មោះខ្មែរទាំងអស់ បានន័យថា ដាក់ឈ្មោះឯកសារជាខ្មែរទាំងអស់។ ក្រុមមេធាវីការពារមិនបានទទួលព័ត៌មានណាមួយអំពីរឿងរ៉ាវបន្តទៅទៀតលើការស្នើសុំនោះឡើយ។ យើងខ្ញុំយល់ថា ការកោះហៅជនទាំងនោះឲ្យមកបង្ហាញមុខ ចំពោះមុខអង្គជំនុំជម្រះ ពិតជាមានប្រយោជន៍ ដល់ការបង្ហាញពីភាពគួរឲ្យជឿជាក់បានលើឯកសារទាំងអស់នេះ។

[១៥:២៦:១៥]

ប្រភេទឯកសារមួយក្រុមទៀត គឺឯកសារដែលសប្បុរសជនប្រគល់ជូនមជ្ឈមណ្ឌលឯកសារ ឌី.ស៊ី.ខេម។ យើងមានសេចក្ដីណែនាំ យើងមានឃើញសេចក្ដីណែនាំរបស់បក្សកុម្មុយនីស្ដកម្ពុជាមួយច្បាប់ និងសេចក្ដីសម្រេចរបស់គណៈកម្មាធិការមជ្ឈិមរបស់បក្សកុម្មុយនីស្ដកម្ពុជាមួយច្បាប់ ដែលត្រូវបានគេប្រគល់ជូនទៅឲ្យមជ្ឈមណ្ឌលឯកសារ ឌី.ស៊ី.ខេម។ ទាក់ទងទៅនឹងសេចក្ដីណែនាំរបស់បក្សកុម្មុយនីស្ដកម្ពុជា លោក ឆាំង យុ បានជម្រាបជូនសហចៅក្រមស៊ើបអង្កេតថា លោក បែ៊ន ឃៀរណាន *(Kiernan Ben)* បានផ្ដល់ឯកសារនេះជូនមជ្ឈមណ្ឌលឯកសារ ឌី.ស៊ី.ខេម នៅក្នុងអំឡុងឆ្នាំ១៩៨៥។

ក៏ប៉ុន្តែមេធាវីការពារក្តីមិនមានព័ត៌មានទាក់ទងទៅនឹងរបៀបដែលលោក ប៉ែន យៀរណាន បានប្រមូលឯកសារនោះឡើយ។

[១៥:២៧:២៧]

ចំណែកឯសេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិម ក្រុមមេធាវីការពារសង្កេតឃើញថាមានព័ត៌មានផ្ទុយគ្នា។

ចំណុច(ខ) ទាក់ទងនឹងក្រុមមេធាវីការពារក្តីសង្កេតឃើញថា ជួនកាលមានព័ត៌មានផ្ទុយគ្នា។ ឧទាហរណ៍ ចំពោះចំណុចដែលទាក់ទងទៅនឹងសេចក្តីណែនាំ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ នៅក្នុងឯកសារ RI6.3។ ឯកសារនេះ ប្រហែលជាត្រូវបានផ្តល់ទៅឱ្យលោកសាស្ត្រាចារ្យ ប៉ែន យៀរណាន ដោយលោក ខៀវ កាញ៉ារិទ្ធ។ លោកសាស្ត្រាចារ្យ ប៉ែន យៀរណាន បានបញ្ជាក់ជូនសហចៅក្រមស៊ើបអង្កេតថា នៅឆ្នាំ១៩៨០ ឬឆ្នាំ១៩៨១ លោក ខៀវ កាញ៉ារិទ្ធ បានឱ្យឯកសារច្បាប់ដើមទៅគាត់ ហើយគាត់បានថតចម្លងរួចក៏សងទៅគាត់វិញ។ តាមរយៈលិខិតចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១០ លោក ប៉ែន យៀរណាន បានជម្រាបទៅសហចៅក្រមស៊ើបអង្កេតថា លោកឃើញឯកសារនេះ ក្នុងពេលទន្ទឹមគ្នានឹងការរកឃើញកំណត់ហេតុអង្គប្រជុំនៃគណៈអចិន្ត្រៃយ៍នៅក្នុងគណៈរដ្ឋមន្ត្រីនៃរបបខ្មែរក្រហម និងនៅក្នុងសមាជិករដ្ឋាភិបាលខ្មែរក្រហម (សូមទោស) នៅក្នុងផ្ទះសមាជិករដ្ឋាភិបាលខ្មែរក្រហម នៅតាមវិថីកម្ពុជាក្រោម។

[១៥:២៩:១២]

ប៉ុន្តែនៅក្នុងអត្ថបទមួយ សរសេរដោយលោក ចន ឆរឆីអារី *(John Ciorciari)* និងលោក ឆាំង យុ ក្រោមចំណងជើងថា "*ដកខ្យូមិនធីង ឌី ក្រាមស៍ អហ្វ ឌី ម៉ូក្រាទិចកម្ពុជា* (Documenting of the Democritic of Kampuchea)" អ្នកនិពន្ធបានបង្ហាញថា ឯកសារទាំងនោះត្រូវបានបញ្ជូនទៅឱ្យលោក ខៀវ កាញ៉ារិទ្ធ តាមរយៈអ្នកតំណាងការិយាល័យរណសិរ្សសាធារណរដ្ឋប្រជាមានិតកម្ពុជា បន្ទាប់ពីតុលាការប្រជាជនបដិវត្តន៍ឆ្នាំ១៩៧៩ បានកាត់ក្តីរួច។ ចំណែកឯកន្លែងផ្ទុកឯកសារច្បាប់ដើមទាំងនោះ គឺលោក ខៀវ កាញ៉ារិទ្ធ បានបញ្ជាក់តាមរយៈលិខិតមួយចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០ ថាលោកមិនអាចធានាបាននូវការរក្សាទុកឯកសារទាំងនោះទេ។ ប៉ុន្តែបញ្ជាក់ថាឯកសារទាំងអស់ដែលផ្ញើជូនលោក ប៉ែន យៀរណាន សុទ្ធតែឯកសារថតចម្លងតាមច្បាប់ដើមទាំងអស់។

[១៥:៣០:៤៣]

ដោយយល់ឃើញថាសារៈសំខាន់នៃឯកសារទាំងអស់នោះ មាននៅក្នុងសំណុំរឿង០០២ មេធាវីការពារក្តីគិតថាចាំបាច់ត្រូវតែបំភ្លឺឲ្យបានច្បាស់ពីព័ត៌មានទាំងអស់នេះ និងកោះហៅឲ្យមកបង្ហាញចំពោះមុខអង្គជំនុំជម្រះចំពោះជនដែលបានផ្តល់ព័ត៌មានដល់ក្រុមមេធាវីការពារក្តី។ មួយទាក់ទងទៅនឹងកាលៈទេសៈនៃការងារឃើញឯកសារ។ ទីពីរទាក់ទងនឹងកាលៈទេសៈនៃការបាត់បង់ឯកសារ។

ចំណុច(គ) ការទទួលបាននូវឯកសារសម្ងាត់បំផុត នេះជាសិទ្ធិរបស់មេធាវីការពារ ខាងមេធាវីការពារដែលស្នើសុំអាចទទួលយកមកពិនិត្យនូវឯកសារសម្ងាត់បំផុត ដែលចំណាត់ថ្នាក់ដោយតុលាការនេះ។

[១៥:៣១:៥៦]

លោកសហចៅក្រមស៊ើបអង្កេតបានធ្វើការស៊ើបសួរទាក់ទិនទៅនឹងរបៀបរបបរក្សាឯកសារមួយចំនួន។ ប៉ុន្តែកិច្ចស៊ើបសួរមួយចំនួន និងលិខិតឆ្លើយឆ្លងជាច្រើន ជាពិសេសលិខិតឆ្លើយឆ្លងជាមួយលោក ប៉ែន ឃៀវណាន ត្រូវបានចាត់ថ្នាក់ជាឯកសារសម្ងាត់បំផុត។ មានឯកសារ D269/4 ទាក់ទងទៅនឹង--ដែលទាក់ទងទៅនឹងលិខិតឆ្លើយឆ្លងរបស់លោក ប៉ែន ឃៀវណាន ជាមួយនឹងសហព្រះរាជអាជ្ញា។

នៅខែកញ្ញា និងខែតុលា ឆ្នាំ២០១១ ខាងមេធាវីការពារក្តីបានលើកឡើងពីបញ្ហានៃការទទួលយកនូវឯកសារសម្ងាត់បំផុតដែលមាននៅក្នុងសំណុំរឿង។ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១១ អង្គជំនុំជម្រះបានផ្តល់ចម្លើយតាមរយៈអនុស្សរណៈថា អង្គជំនុំជម្រះកំពុងពិនិត្យឯកសារទាំងនោះ ហើយថាភាគីនឹងទទួលបានការជូនដំណឹងនៅពេលចៅក្រមអនុវត្តកិច្ចការនេះចប់សព្វគ្រប់។

[១៥:៣៣:២៩]

ប្រភេទឯកសារទីពីរ គឺឯកសារសាធារណៈដែលខ្ញុំបាទបានលើកជូនអម្បាញ់មិញនេះ គឺមានដូចតទៅ៖

ចំណុច(ក)ទាក់ទងសៀវភៅនិងអត្ថបទសរសេរដោយអ្នកស្រាវជ្រាវនៃគ្រឹះស្ថានសិក្សាជាដើម។

ទីមួយ យើងខ្ញុំមានបំណងបញ្ជាក់ថា ការដែលចេះតែទទួលយកអត្ថបទណាក៏បានក្នុងពេលណាក៏បាន ពិតជាមិនអាចទទួលយកបានទេ។ មានតែទំព័រមួយចំនួន ឬសម្រង់ឃ្លាណាមួយដែលមានកំណត់យ៉ាងច្បាស់លាស់ប៉ុណ្ណោះ ទើបអាចចាត់ទុកថាអាចទទួលយកបាន។ សូមរំឭកថានៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះបានវាយតម្លៃថា សៀវភៅមិនមែនភស្តុតាងតាមន័យដូចមានចែងក្នុងវិធាន៨៧(២)

នោះឡើយ។ សៀវភៅ មិនមែនជាភស្តុតាងទេ។

[១៥:៣៤:៣០]

ម្យ៉ាងទៀត ដោយសារតែមូលហេតុដូចបានបង្ហាញជូនពីមុនមកនេះ ឯកសារថ្មីក្រោយព្រឹត្តិការណ៍ខ្មែរក្រហម យើងខ្ញុំគិតថាសៀវភៅមិនអាចសន្មតថាទទួលយកបានឡើយនៅក្នុងដំណាក់កាលនេះ។ តើមកពីមូលហេតុអ្វី? គឺប្រាកដជាមកពីស្នាដៃទាំងអស់នោះផ្អែកទៅលើឯកសារ ដែលមិនគួរឲ្យជឿបាន។ ដូចគ្នានេះដែរ ចំពោះអត្ថបទដែលសរសេរដោយអ្នកស្រាវជ្រាវនៅគ្រឹះស្ថានសិក្សា។ ហេតុដូច្នេះទើបយើងខ្ញុំជំទាស់មិនទទួលយកឯកសារទាំងអស់នោះ ដរាបណាអ្នកនិពន្ធមិនបានបង្ហាញមុខនៅសវនាការ។ អ្វីដែលយើងចង់បាន គឺថាមនុស្សទាំងនោះបង្ហាញពីប្រភពឯកសារ និងបង្ហាញពីវិធីសាស្ត្រនៃការបកស្រាយរបស់ខ្លួននៅពេលដែលខ្លួនប្រមូលឯកសារ។

យើងខ្ញុំសូមវាយតម្លៃថា ដើម្បីឲ្យឯកសារមួយអាចទទួលយកបាន អង្គជំនុំជម្រះនឹងភាគីត្រូវមានរាល់ព័ត៌មាន ដែលអាចឲ្យយើងកំណត់។ ទីមួយ ទាក់ទងទៅនឹងអត្តសញ្ញាណនៃរាល់ឯកសារ ដែលសំអាង។ ទីពីរ បញ្ជាក់ពីយថាភាពនៃឯកសារសំអាងនោះ ទោះបីជាតាមរយៈការផ្តល់ឯកសារបន្ថែមក្តី ឬសក្ខីកម្មបន្ថែមក៏ដោយ។

[១៥:៣៦:១៧]

ទាក់ទងទៅនឹងវិធីសាស្ត្របកស្រាយឯកសារ ជាពិសេសនៅពេលដែលវិធីសាស្ត្រនោះផ្អែកទៅលើឯកសារមួយចំនួនផ្សេងទៀត ឬសក្ខីកម្ម។ នៅក្នុងករណីនេះមេធាវីស្នើសុំព័ត៌មានដូចគ្នានេះដែរ ដូចមានចែងនៅក្នុងចំណុចមួយ និងចំណុចពីរ។ ដោយសារមូលហេតុទាំងអស់នេះ យើងខ្ញុំសូមជំទាស់ទៅនឹងការដែលប្រកាសទទួលយកស្នាដៃ ឬអត្ថបទសរសេរដោយអ្នកស្រាវជ្រាវពីសាកលវិទ្យាល័យ ឬពីគ្រឹះស្ថានសិក្សានានា ដែលបានចុះនៅក្នុងកំណត់ជើងទំព័រនៃដីកាដំណោះស្រាយ ដែលអ្នកនិពន្ធទាំងអស់នោះ៖

១) ត្រូវបានកោះហៅ ឲ្យបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ។ តើអ្នកនិពន្ធទាំងនោះនឹងមិនមកបង្ហាញមុខដោយផ្ទាល់នៅក្នុងសវនាការទេ?

២) មិនត្រូវបានកោះហៅ ឲ្យមកបង្ហាញខ្លួន ស្នាដៃ អត្ថបទទាំងនោះ លើកលែងតែពីតួនាទី និងមុខងាររបស់ជនជាប់ចោទ គឺថាកូនក្តីរបស់ខ្ញុំបាទមានសិទ្ធិតទល់ជាមួយនឹងអ្នកនិពន្ធទាំងអស់នោះដោយអនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង។

ចំណុច(ខ) ទាក់ទងនឹងអត្ថបទសារព័ត៌មាន។ យើងខ្ញុំជំទាស់ទៅនឹងការដែលប្រកាសទទួលយកអត្ថបទសារព័ត៌មាន ដែលមានចុះនៅក្នុងកំណត់ជើងទំព័រនៃដីកាដំណោះស្រាយ ដែលអ្នកសរសេរអត្ថបទទាំងនោះមិនត្រូវបានកោះហៅឲ្យមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ។ ឧទហរណ៍ មាននៅក្នុងឯកសារ D366/7.1.278។

[១៥:៣៨:៤៥]

ចំណុចមួយទៀត ទាក់ទងនឹងអត្ថបទសារព័ត៌មាននេះដែរ គឺព្រឹត្តិប័ត្រ *“ហ្វ័ររ៉េន ប្រូឃើស អ៊ីមហ្វ័រម៉េស៊ិន ស៊ើវីស”* របស់ អេស.ប៊ី.អាយ.អេស ដូចលោកមេធាវី ម៉ៃខល កាណាវាស បានលើកមុនហ្នឹង។ បើតាមសហព្រះរាជអាជ្ញា ព្រឹត្តិបត្រទាំងអស់នោះសុទ្ធតែត្រូវបានបង្កើតឡើងដោយ ពួក ស៊ី.អាយ.អេ ដើម្បីបម្រើរដ្ឋាភិបាលអាមេរិកាំង។ ហើយមានអត្ថបទបកប្រែរបាយការណ៍ ដែលប្រមូលបានពីស្ថានីយពិសេសរបស់ ស៊ី.អាយ.អេ ទទួលបន្ទុកតាមដានប្រព័ន្ធផ្សព្វផ្សាយទៅកាន់សាធារណជនលើពិភពលោក។

ព្រឹត្តបត្រដែលមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធប៉ះពាល់អ្នកទាំងអស់គ្នានៅប្រទេសកម្ពុជា ហើយស្ថិតនៅក្នុងចន្លោះពេលពីថ្ងៃទី០២ ខែមករា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៧៩ គឺចន្លោះពេលដែល ស៊ី.អាយ.អេ បានប្រមូលឯកសារទាំងអស់នោះ ដើម្បីផ្សព្វផ្សាយលើពិភពលោក។ នៅក្នុងចន្លោះ-- នៅក្នុងនោះរួមមានបញ្ចូលទាំងការបកប្រែឯកសារទំនាក់ទំនងផ្លូវការ ដែលប្រកាសតាមវិទ្យុ ដោយរាជរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ មានរដ្ឋាភិបាល--។ បាទ គឺរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។

[១៥:៤០:៤៥]

សហព្រះរាជអាជ្ញា បានបែងចែកប្រភពឯកសារជាពីរ។ មួយគឺ សារទូរលេខនៃទីភ្នាក់ងារសារព័ត៌មានអន្តរជាតិ ជាពិសេស ឧទាហរណ៍ដូច *រ៉យទ័រ* និង អេ.អេហ្វ.ភី យើងខ្ញុំជំទាស់ទៅនឹងឯកសារទាំងនេះ ដោយសារតែមានមូលហេតុដូចគ្នាទៅនឹងអត្ថបទសារព័ត៌មានដូច្នោះដែរ ពីព្រោះវាជាឯកសារដែលយកទៅដើម្បីផ្សព្វផ្សាយ តាមស្ថានីយវិទ្យុលើពិភពលោក។

ទីពីរ របាយការណ៍ដែលសឹងតែធ្វើឡើងជារៀងរាល់ខែ តាមការផ្សព្វផ្សាយតាមវិទ្យុជាផ្លូវការនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ យើងខ្ញុំសូមជំទាស់នឹងឯកសារនេះផងដែរ ដោយហេតុថា យើងខ្ញុំមិនបានទទួលខ្សែអាត់សំឡេង ឬឯកសារច្បាប់ដើមជាលាយលក្ខណ៍អក្សរ អំពីរបាយការណ៍ដែលធ្វើឡើងដោយទីភ្នាក់ងារ ស៊ី.អាយ.អេ នោះទេ។

សាក្សីម្នាក់ដែលត្រូវបានយកចម្លើយនៅដំណាក់កាលស៊ើបអង្កេត បានទទួលស្គាល់ថា គាត់ធ្លាប់ស្តាប់វិទ្យុផ្សាយសំឡេងរបស់កម្ពុជាប្រជាធិបតេយ្យ តែគាត់មិនយល់អ្វីទាល់តែសោះ ព្រោះពាក្យពេចន៍ត្រូវបានផ្លាស់ប្តូរទាំងស្រុង។ ពាក្យពេចន៍ភាសាដែលប្រើក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង គឺពុំមានលក្ខណៈដូចជាភាសាខ្មែរទាំងស្រុងទេ ដោយសារការប្រើពាក្យខ្លះ ជាពាក្យបដិវត្តន៍។ វាមានតែសំអាងលើខ្សែអាត់សំឡេងនោះហើយ ទើបគាត់អាចទទួលយកព័ត៌មានគ្រប់គ្រាន់ដើម្បីបង្កើតជាសំណុំឯកសារបាន។

[១៥:៤២:៣៤]

ចំណែកឯឯកសារ អេស.វី.អាយ.អេស នេះវិញ គឺមិនមានឯកសារដើមជាភាសាខ្មែរទេ។ អង្គជំនុំជម្រះក៏មិនមានគម្រោងកោះហៅអ្នកបកប្រែ ឬបុគ្គលិក ស៊ី.អាយ.អេ នោះមកបំភ្លឺដែរ។

ចំណុច(គ) ទាក់ទងទៅនឹងបទសម្ភាសន៍។ យើងខ្ញុំសូមជំទាស់ទៅនឹងការប្រកាសទទួលយកសេចក្តីប្រកាសរបស់ជនជាប់ចោទ ឬអ្នកផ្សេងទៀត ដោយគ្មានការថតសំឡេងដែលរាយការណ៍ដោយអត្ថបទសារព័ត៌មាន។ គ្មានឯកសារណាមួយ ដែលត្រូវបានយកមកកត់ត្រាឡើងវិញទាំងអស់ចំពោះការសួរឆ្លើយនៅក្នុងពេលសម្ភាសន៍ឡើយ ជួនកាលគ្រាន់តែជាសេចក្តីសង្ខេប នៃកំណត់ហេតុរបស់អ្នកធ្វើសម្ភាសន៍ ដោយមនុស្សទីបីណាម្នាក់ ហើយជួនកាលជននោះមិនទាំងមានវត្តមាននៅពេលសម្ភាសន៍នោះទៀតផង។

[១៥:៤៣:៤៦]

មិនមានឯកសារណា ដែលអាចកំណត់ថា តើធ្វើបទសម្ភាសន៍នៅពេលណា ជាមួយនឹងវត្តមានរបស់អ្នកណាខ្លះ អស់រយៈពេលប៉ុន្មាន ឬមួយថ្ងៃ ឬច្រើនថ្ងៃ ក្នុងបរិបទកាលៈទេសៈអី ឬជួនកាលអត្តសញ្ញាណរបស់អ្នកធ្វើបទសម្ភាសន៍នោះទៀតក៏គ្មានដែរ។ នៅពេលដែលគេមិនស្គាល់អ្នកធ្វើសម្ភាសឯកសារនោះគួរតែត្រូវប្រកាសថា មិនអាចទទួលយកបានឡើយ។ ចំពោះអ្នកផ្សេងទៀត យើងខ្ញុំសូមទាមទារឲ្យមានការកោះហៅ អ្នកដែលធ្វើសម្ភាសន៍នោះមកចូលក្នុងសវនាការនេះផងដែរ។

ប្រភេទឯកសារទីបី គឺឯកសារតុលាការ ក្នុងឯកសារតុលាការនេះមានកំណត់ហេតុ ស្តាប់ចម្លើយសាក្សីក្នុងពេលស៊ើបអង្កេត ប្រតិចារឹកសវនាការនៅក្នុងសំណុំរឿង០០១។ នៅកំណត់សម្គាល់ចុងទំព័រនៃដីកាដំណោះស្រាយ ចំពោះផ្នែកដែលពាក់ព័ន្ធទៅនឹងសារតារប្រវត្តិសាស្ត្រ យើងឃើញមានកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលត្រូវបានកោះហៅឲ្យមកបង្ហាញខ្លួននៅចំពោះមុខតុលាការ។ ព្រម

ទាំងប្រតិចារឹក, សក្ខីកម្ម, សាក្សីនៅក្នុងសំណុំរឿង០០១ និងកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលមិនត្រូវបានកោះហៅនោះផងដែរ។

យើងសូមជំទាស់នូវកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបានលើកឡើងនៅកំណត់សម្គាល់ចុងទំព័រនៃដីកាដំណោះស្រាយ ចំពោះសាក្សីណាដែលត្រូវបានកោះហៅឲ្យមកបង្ហាញខ្លួនតែពួកគេមិនបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។

យើងខ្ញុំសូមជំទាស់លើប្រតិចារឹក, សក្ខីកម្ម, សាក្សី ក្នុងសំណុំរឿង០០១ និងកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលមិនត្រូវបានកោះហៅឲ្យមកបង្ហាញខ្លួន ឬដែល/និង មកបង្ហាញខ្លួនតែម្តងនោះ។

ខ្ញុំសូមរំឭកនៃដល់អង្គជំនុំជម្រះថា យើងមិនអាចៗយកឯកសារមួយ យកមកចោទដោយយោងទៅតាមស្មារតីនៃវិធាន៨៧(៣)(ឃ) នេះវិធានផ្ទៃក្នុងបានឡើយដរាបណាកូនក្តីខ្ញុំបាទមិនបានការធានានូវសិទ្ធិរបស់គាត់ដែលមានចែងនៅក្នុងវិធាន៨៤(១) នៃវិធានផ្ទៃក្នុង។ ក្នុងការទទួលបានការតទល់គ្នាជាមួយម្ចាស់សក្ខីកម្ម ឬក៏ម្ចាស់នៃសេចក្តីថ្លែងការណ៍នោះ នៃអ្នកដែលថ្លែងការណ៍នោះ។

ខ្ញុំសូមរំឭកផងដែរថា យើងខ្ញុំបានលើករួចហើយ អំពីបញ្ហានេះកាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ នៅក្នុងឯកសារ E96/4 ដែលថាជួនកាលវាអាចទៅរួចចំពោះភាពដែលអាចទទួលយកបាននៃសេចក្តីប្រកាសពីមុនមកនោះ ជំនួសឲ្យសក្ខីកម្មដោយផ្ទាល់មាត់ ដោយពុំមានការសួរតទល់ណាមួយ។ ប៉ុន្តែវាគ្រាន់តែជាករណីពិសេសតែប៉ុណ្ណោះ និងបានតែក្នុងករណីដោយឡែកណាមួយ និងត្រូវគោរពតាមលក្ខខណ្ឌដ៏តឹងរ៉ឹងទៀតផង។

[១៥:៤៧:៣៨]

យើងធ្លាប់បាននិយាយកាលពីពេលនោះថា បញ្ហាទាំងនេះនឹងត្រូវលើកនៅពេលជាក់ស្តែង។ ក្នុងឯកសារដែលជាសក្ខីកម្មនេះមានច្រើន ដែលខ្ញុំបាទសូមលើកសម្គាល់ខ្លះ ឧទាហរណ៍ នៅក្នុងឯកសារ D91/10, ឯកសារ D107/3, ឯកសារ D107/2, ឯកសារ D91/3, ឯកសារ D91/25, ឯកសារ D167, ឯកសារ D147, ឯកសារ D201/8, ឯកសារ D91/4, ឯកសារ D91/9, ឯកសារ D125/160, ឯកសារ D200/3, ឯកសារ D200/9, ឯកសារ D200/5, ឯកសារ D141/1, ឯកសារ D199/20 ជាដើម។

[១៥:៤៩:២៧]

ដូច្នេះ ឯកសារទាំងអស់នេះបានបញ្ជាក់ពីចំណុចខ្វះខាត ដែលយើងមិនអាចទទួលយកបាន។

យើងបាននិយាយយ៉ាងដូច្នេះនៅថ្ងៃនេះ ខ្ញុំសូមនិយាយសាឡើងវិញពីការចាំបាច់ នៃការដេញដោលលើឯកសារ ហើយត្រូវធ្វើឡើងតាមភាពជាក់ស្តែង គឺក្នុងឯកសារនីមួយៗទៅតាមភាពជាក់លាក់នៃឯកសារមួយម្តងៗ ដោយវិធីតទល់គ្នា និងជាបន្តបន្ទាប់នៅក្នុងពេលសវនាការអង្គហេតុនេះ។ វាជាឯកសារដែលបាន ដែលមានក្នុងកំណត់ជើងទំព័រនៃដីកាដំណោះស្រាយទាក់ទងទៅនឹងបរិបទប្រវត្តិសាស្ត្រ ក្នុងដីកាដំណោះស្រាយ ឬនៅក្នុងបញ្ជីរបស់ភាគីណាមួយ។ មិនមានឯកសារណាមួយដែលមិនត្រូវយកមកពិនិត្យបែបនេះ ហើយអាចត្រូវចាត់ទុកថាមានតម្លៃនោះឡើយ។ បើថាឯកសារដូចលោកប្រធានបានអានវិធាន៨៨ វិធាន៧៨(២) គឺថាភស្តុតាងទាំងអស់ត្រូវតែបានដាក់ដើម្បីឲ្យភាគីដេញដោលមុននឹងអាច-- បាទវិធាន៨៧(២) ដែលវិធានទាំងអស់ត្រូវតែ អំឯកសារទាំងអស់ត្រូវតែដាក់ដើម្បីឲ្យភាគីអាចដេញដោលមុននឹងយកមកធ្វើការអះអាងក្នុងសេចក្តីសម្រេច។

[១៥:៥១:៤៤]

អ៊ីចឹង ខ្ញុំបាទសូមបញ្ជាក់សាឡើងវិញថា ភាគី-- សាក្សី ឬក៏បុគ្គលដែលជាប់ពាក់ព័ន្ធក្នុងការផ្តល់ឯកសារត្រូវតែមកបញ្ជាក់ ឆ្លើយបញ្ជាក់ចំពោះការប្រមូលនូវឯកសារនោះ ជាពិសេសក្នុងករណីមជ្ឈមណ្ឌលឯកសារ ដែលមានលោក ឆាំង យុ ជាអ្នកដឹកនាំ។ លោកត្រូវតែមកបំភ្លឺ ដើម្បីឲ្យភាគីអាចធ្វើការដេញដោល ដើម្បីស្វែងរកពីភាគពាក់ព័ន្ធ និងភាពដែលគួរឲ្យជឿបាននៃការប្រមូលឯកសារនោះ។

ដោយឡែកក្នុងករណីឯកសារនេះ ប្រហែលជាលោក ឆាំង យុ មិនមែនជាអ្នកទទួលខុសត្រូវគ្រប់ឯកសារទាំងអស់ទេ។ អាចមានមន្ត្រីរបស់លោក ជាអ្នកទទួលបន្ទុក ដូច្នេះមន្ត្រីនោះក៏គួរត្រូវបានកោះហៅដើម្បីមកបំភ្លឺនៃការទទួលបាននូវឯកសារទាំងអស់នោះ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវ ភាពគួរឲ្យជឿបាននិងនៃឯកសារនោះផងដែរ។ សូមអរគុណ។

[១៥:៥២:៥៨]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ដែលបានបង្ហាញនូវការជំទាស់។ ឥឡូវនេះពេលវេលាសមល្មមនឹងសម្រាកហើយ ប៉ុន្តែមុននឹងសម្រាក អង្គជំនុំជម្រះសូមជម្រាបជូនទៅសហព្រះរាជអាជ្ញាថា សហព្រះរាជអាជ្ញាមានពេលវេលាមួយម៉ោងក្នុងការ ដើម្បីធ្វើការឆ្លើយតបទៅនឹងការជំទាស់របស់មេធាវីទាំងបីក្រុមដែលបានបង្ហាញរួចហើយនេះ។ ហើយចំណែកឯមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានពេល១៥នាទីសម្រាប់ការឆ្លើយតបនេះដែរ ដោយសារពេលវេលាដែលបានគ្រោងទុកនេះ យើងបានប្រើអស់នៅ

ថ្ងៃនេះ ហើយមិនមានពេលសម្រាប់បន្តឲ្យចប់ទេ។ អ៊ីចឹងកិច្ចការនេះ យើងនឹងលើកទៅបន្តធ្វើនៅព្រឹកថ្ងៃស្អែក នៅពេលដែលយើងចូលមកវិញ គឺចាប់ផ្តើមពីចំណុចនេះ មុននឹងឈានចូលដល់បញ្ហានានាដែលយើងនឹងត្រូវដំណើរការសម្រាប់ផែនការថ្ងៃ១៧ ខែមករា ឆ្នាំ២០១២។

[១៥:៥៤:០៥]

ដូច្នេះសូមភាគីជ្រាប ឥឡូវនេះដល់ពេលម៉ោងសមល្មមនឹងសម្រាកហើយ។ ដូច្នេះអង្គជំនុំជម្រះប្រកាសសុំផ្អាកកិច្ចដំណើរការសម្រាប់សវនាការថ្ងៃនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែកចាប់វេលាម៉ោងប្រាំបួនព្រឹក។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៥៤:៥៤]

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ ហើយនិងឲ្យនាំពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន ដោយលោក នួន ជា ហើយនិង អៀង សារី ទុកនៅបន្ទប់ខាងក្រោម ដើម្បីឲ្យគាត់បន្តការតាមដានដំណើរការសវនាការតាម-- ពីចម្ងាយតាមមធ្យោបាយសោតទស្សន៍ ហើយចំណែកឯលោក ខៀវ សំផន សូមនាំគាត់មកកាន់សាលសវនាការដោយផ្ទាល់។

សូមសម្រាកចុះ៕

*(ចៅក្រមចាកចេញពីបន្ទប់សវនាការ)*

*(សវនាការផ្អាកនៅម៉ោង ១៥:៥៥នាទី)*